**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការកំណត់ទោសដោយចៅក្រម

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០២២ ដល់ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ផល អៀងលី**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ចាំង ស៊ីណាត**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការកំណត់ទោសដោយចៅក្រម

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០២២ ដល់ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០២២

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ផល អៀងលី**

សាស្ត្រាចារ្យណែនាំ
លោកស្រី **ចាំង ស៊ីណាត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨
ឆ្នាំសរសេរសារណា ២០២២

# **សេចក្តីថ្លែងអំណរគុណ**

ខ្ញុំបាទឈ្មោះ **ផល វៀងលី** ជានិស្សិតជំនាន់ទី២២ ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមថ្លែងក្តីដឹងគុណ និងសំដែងភាពកតញ្ញូចំពោះអ្នកមានគុណទាំងពីរៈ

-លោកឪពុក **ផុន សុផល** និងអ្នកម្តាយ **ព្រិល ពុំ**

កូនសូមលំអោនកាយគោរពលោកទាំងពីរជាអ្នកមានគុណរបស់កូន។ កូនសូមថ្លែងអំណរអរគុណលោកទាំងពីរដែលបានផ្តល់កំណើតដល់កូន ព្រមទាំងបីបាច់ថែរក្សាកូនរហូតដល់មានថ្ងៃនេះ លោកទាំងពីរបានលះបង់គ្រប់យ៉ាងដែលមិនអាចកាត់ថ្លៃបាន។ ទោះបីការសិក្សារបស់កូនមានការលំបាក តែមិនស្ទើការខិតខំពុះពារគ្រប់ឧបសគ្គ ចិញ្ចឹមថែរក្សា អប់រំទូន្មានកូនរហូតដល់ថ្ងៃនេះ។លោកទាំងពីរជាតែងតែផ្តល់នូវអ្វីគ្រប់យ៉ាងមិនថាកូនមានបញ្ហាអ្វីអ្នកទាំងពីរតែងតែទំនុកបម្រុងដល់កូនតាំងពីឈានជើងចូលសិក្សាតាំងពី មត្តេយ្យរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ។ កូនសូមសំដែងការដឹងគុណចំពោះការលះបង់ដ៏ធំធេងរបស់លោកទាំងពីរចំពោះកូន។ ចំពោះគុណដ៏ធំធេងមួយនេះ ទោះបីជាកូនសងក៏មិនគ្រប់ដែរ ប៉ុន្តែកូននឹងចងចាំចំពោះគុណដ៏ធំធេងរបស់លោកទាំងពីរជាដរាបរៀងទៅលុះថ្ងៃកូនសូន្យ។

សូមថ្លែងអំណរអរគុណដល់ឯកឧត្តមសាកលវិទ្យាធិការ **លុយ ចន្ទ្នា** ព្រមទាំង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងលោកគ្រូ អ្នកគ្រូទាំងអស់ដែលបានចំណាយពេលវេលាដល់មានតម្លៃក្នុងការបង្ហាត់បង្រៀនចែករំលែកចំណេះដឹង ដែលចម្លងរូបខ្ញុំទៅថ្ងៃខាងមុខឱ្យមានអនាគតដល់ថ្លៃថ្លាមួយ។

សូមគោរពនិងថ្លែងអំណរអរគុណដល់លោកស្រីសាស្ត្រាចារ្យ **ចាំងស៊ីណាត** ដែលជាសាស្ត្រាចារ្យណែនាំដល់រូបខ្ញុំក្នុងការរៀបចំឯកសារសារណាលើប្រធានបទ **ការកំណត់ទោសដោយចៅក្រម** ដែលបានចំណាយពេលវេលាដល់មានតម្លៃក្នុងការបង្រៀន ផ្តល់យោលបល់ និងផ្តល់អនុសាសន៍ដ៏ល្អដើម្បីឱ្យសារណាមួយនេះកាន់តែល្អ។បន្ថែមពីនេះទៀត ក៏បានបង្រៀនដល់ខ្ញុំដោយយកចិត្តទុកតាំងពីខ្ញុំមិនទាន់មានចំណេះវិជ្ជាខាងច្បាប់សោះឡើយ។ ចំណុចរបត់នៃការសិក្សារបស់ខ្ញុំបានផ្លាស់ប្តូរការសិក្សា ទាំងរបៀបសិក្សា គន្លឹះសិក្សាព្រមទាំងវិធីសាស្ត្រផ្សេងៗទៀតក្នុងវិស័យច្បាប់។

ជាចុងក្រោយ ខ្ញុំបាទសូមបួងសួងដល់ទេវតា និងវត្ថុស័ក្តសិទ្ធក្នុងលោកនេះឱ្យជួយតាមថែរក្សា លោកអ្នកមានគុណ ឯកឧត្តម សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងបុគ្គលិក នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឱ្យជួបតែសំណាងល្អ សុខភាពល្អ និងជួបពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ សូមអរគុណ។

# អារម្ភកថា

ប្រទេសកម្ពុជាមានប្រវត្តិសាស្ត្រទាំងភាពរុងរឿង និងភាពដុនដាបហើយបានឆ្លងកាត់ការផ្លាស់ប្តូរទាំងរបបនយោបាយនិងប្រព័ន្ធច្បាប់ជាច្រើនលើកច្រើនសារ ក្នុងរយៈកាលក្នុងទសវត្សឆ្នាំ១៩៦០ជាង ពោលគឺក្រោយសម័យសង្គមរាស្ត្រនិយមទើបមានភាពរុងរឿងត្រឹមមួយរយៈពេលខ្លីតែប៉ុណ្ណោះ។ ក្រោយពីរដ្ឋប្រហារក្នុងឆ្នាំ១៩៧០មក ប្រទេសកម្ពុជាកាន់តែដុនដាបរហូតដល់ចំណុចសូន្យក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ក្រោយពីឆ្លងកាត់សង្គ្រាមស៊ីវិល ទើបក្នុងឆ្នាំ១៩៩១ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ប្រទេសកម្ពុជាបានកសាងខ្លួនយ៉ាងឆាប់រហ័ស និងមានមុខមាត់លើឆាកអន្តរជាតិក៏ព្រោះតែប្រទេសកម្ពុជាស្ថិតក្រោមម្លប់សន្តិភាព។យោងតាមសេចក្តីសម្រេចចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ១៩៩២ បានអនុម័តច្បាប់ព្រហ្មទណ្ឌសម្រាប់ដាក់ឱ្យ អនុវត្តក្នុងរយៈពេលអន្តរកាល គឺដើម្បីថែរក្សា សន្តិសុខសណ្តាប់ធ្នាប់សង្គម មិនឱ្យមានការប្រព្រឹត្តបទល្មើសផ្សេងៗ។ ប្រទេសកម្ពុជាបានស្តារឡើងវិញនូវស្ថេរភាពនយោបាយ និងអភិវឌ្ឍគ្រប់វិស័យនាំឱ្យមានការសម្រេចការកសាងជាច្រើនរហូតដល់សព្វថ្ងៃនេះ ជាពិសេសគឺវិស័យយុត្តាធិការ រហូតដល់ប្រសូតចេញក្រមព្រហ្មទណ្ឌថ្មី គឺជាសមិទ្ធផលដ៏ល្អមួយដែលត្រូវបានប្រកាសប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលបានកែសម្រួលកាន់តែប្រសើរជាងច្បាប់ព្រហ្មទណ្ឌអន្តរកាល។

ក្រមព្រហ្មទណ្ឌថ្មីនេះ ជាអត្ថបទច្បាប់មួយដែលមានការបែងចែកជារចនាសម្ព័ន្ធត្រឹមត្រូវ ធានាបាននូវសង្គតិភាព ភាពរលូននិងស៊ីសង្វាក់គ្នា ហើយមានលក្ខណៈគោរពសិទ្ធិ និងអនុគ្រោះច្រើនដល់ជនល្មើសដើម្បីធ្វើយ៉ាងណាកែប្រែជនល្មើស និងធ្វើសមាហរកម្មជនល្មើសឱ្យចូលរួមរស់នៅក្នុងសង្គមវិញបាន ថែមទាំងបានជួយឱ្យប្រជាពលរដ្ឋ បានយល់ដឹងកាន់តែច្បាស់ អំពីសិទ្ធិនិងព្រំដែននៃការអនុវត្តសិទ្ធិរបស់ខ្លួន ជាពិសេសយល់ដឹងអំពីអំពើដែលត្រូវ បានហាមឃាត់ និងផ្តន្ទាទោសជាបទល្មើសព្រហ្មទណ្ឌ។

ចំពោះខ្ញុំបានជ្រើសរើសប្រធានបទស្តីពី **ការកំណត់ទោសដោយចៅក្រម** មកធ្វើការបកស្រាយ និងសរសេរជាសារណា គឺដើម្បីស្វែងយល់ឱ្យកាន់តែស៊ីជម្រៅអំពីគោលការណ៍ក្នុងការប្រកាសទោសដោយចៅក្រមក្នុងការប្រកាសទោសដោយផ្អែកលើច្បាប់ និងការប្រើប្រាស់សិទ្ធិស្វ័យសម្រេចក្នុងការផ្តន្ទាទោសដល់ជនជាប់ចោទ។ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយណាស់ដោយទទួលបានការណែនាំ បង្ហាត់បង្ហាញ ពីលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** លើការសិក្សាស្រាវជ្រាវប្រធានបទ។ជាមួយគ្នានេះ ខ្ញុំសង្ឃឹមមុតមាំថា មិត្តអ្នកអាន និងនិស្សិតជំនាន់ក្រោយអាចយកសារណានេះទុកជាការសិក្សាបន្ថែម។ ទន្ទឹមនឹងនេះ ខ្ញុំសង្ឃឹមថានឹងមានការយោគយល់ពីមិត្តអ្នកអាន នូវចំណុចខ្វះខាត ខុសឆ្គងពាក្យពេចន៍ និងខ្លឹមសារនៅត្រង់ចំណុចណាមួយនៃសារណានេះ។

# មាតិកា

ទំព័រ

សេចក្តីផ្តើម ........ ១
១.លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
២.ចំណោទបញ្ហា ........ ២
៣.គោលបំណងនៃការសិក្សាស្រាវជ្រាវ ........ ៣
៤.ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ ........ ៣
៥.វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣
៦.សារៈសំខាន់នៃការស្រាវជ្រាវ ........ ៤
៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤


## ជំពូកទី១

## ការកំណត់ទោសជាទូទៅដោយចៅក្រម

១.១.ការព្យួរទោស ........ ៥
១.១.១.ការព្យួរទោសធម្មតា ........ ៥
១.១.១.១.លក្ខខណ្ឌនៃការព្យួរទោសធម្មតា ........ ៦
១.១.១.២.អានុភាពនៃការព្យួរទោសធម្មតា ........ ៨
១.១.២.ការព្យួរទោសសាកល្បង ........ ១០
១.១.២.១លក្ខខណ្ឌនៃការព្យួរទោសសាកល្បង ........ ១១
១.១.២.២.វិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែករបស់ទណ្ឌិត ........ ១១
១.១.២.៣.ការដកហូតការព្យួរទោសសាកល្បង ........ ១២
១.២.ការបែងចែកទោសជាប្រភាគ ........ ១៤
១.៣.របបពាក់កណ្តាលសេរីភាព ........ ១៥


## ជំពូកទី២

## ការកំណត់ទោសដោយ ចៅក្រម ក្នុងករណីបទល្មើសត្រួតគ្នា

២.១.ការកំណត់អំពីស្ថានភាពនៃបទល្មើសត្រួតគ្នា ........ ១៧
២.១.១.សញ្ញាណនៃបទល្មើសត្រួតគ្នា ........ ១៧
២.១.២.សញ្ញាណទ្រឹស្តីទាក់ទងនឹងទោសក្នុងករណីបទល្មើសត្រួតគ្នា ........ ១៩

**២.២.ការចោទប្រកាន់តែមួយ** ........ ២០
**២.២.១.ការប្រកាសទោសត្រួតគ្នា ក្នុងករណីដែលមានទោសប្រភេទខុសគ្នា** ........ ២១
**២.២.២.ការអនុវត្តវិធានស្រូបទោស** ........ ២២
**២.៣.ការចោទប្រកាន់ដាច់ពីគ្នា** ........ ២៤
**២.៣.១.ការអនុវត្តទោសត្រួតគ្នា** ........ ២៤
**២.៣.២.ការប្រកាសការស្រូបទោស** ........ ២៦
**២.៤.ការអនុវត្តវិធានបូកទោស** ........ ២៩
**២.៤.១.ការបូកទោសបញ្ចូលគ្នាចំពោះបទលហុច្រើន** ........ ២៩
**២.៤.២.ករណីរត់ចេញពីពន្ធនាគារ** ........ ៣០

**ជំពូកទី៣**

**ការកំណត់ទោស ដោយ ចៅក្រម ក្នុងករណីមានស្ថានទម្ងន់ទោស ឬស្ថានសម្រាលទោស**

**៣.១ស្ថានទម្ងន់ទោស** ........ ៣១
**៣.១.១ ស្ថានទម្ងន់ទោសទូទៅ** ........ ៣២
៣.១.១.១ ករណីនៃការមិនរាងចាល ........ ៣៣
៣.១.១.២ អានុភាពនៃការមិនរាងចាល ........ ៣៨
**៣.១.២. ស្ថានទម្ងន់ទោសដោយឡែក** ........ ៣៩
៣.១.២.១.ស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ........ ៣៩
៣.១.២.២.ស្ថានទម្ងន់ទោសទាក់ទងនឹងចារី ........ ៤០
៣.១.២.៣.ស្ថានទម្ងន់ទោសទាក់ទងនឹងអំពើជាសត្យានុម័តនៃបទល្មើស ........ ៤០
៣.១.២.៤.ស្ថានទម្ងន់ទោសដោយសារពហុបទល្មើស ........ ៤២
៣.១.២.៥.ស្ថានទម្ងន់ទោសផ្សេងៗទៀត ........ ៤៣
**៣.២.ស្ថានសម្រាលទោស** ........ ៤៤
**៣.២.១. ស្ថានសម្រាលទោសទូទៅ** ........ ៤៤
៣.២.១.១.កាលៈទេសៈនៃបទល្មើស ........ ៤៥
៣.២.១.២.បុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ ........ ៤៥
**៣.២.២.ស្ថានសម្រាលទោសដោយឡែក** ........ ៥១
**សេចក្ដីសន្និដ្ឋាន** ........ ៥៣

**អនុសាសន៍**....................................................................................................................... ៥៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ក្រោយពីប្រទេសកម្ពុជា មានសន្តិភាពពេញលេញដោយក្នុងរដ្ឋធម្មនុញ្ញប្រទេសកម្ពុជាបានជ្រើសរើសយករបបប្រជាធិបតេយ្យសេរីពហុបក្ស ដោយមានការបែងចែកអំណាចជាបីធំៗដាច់ចេញពីគ្នាដែលសម្រាប់ដឹកនាំរដ្ឋ គឺអង្គនីតិបញ្ញត្តិ អង្គនីតិប្រតិបត្តិ និងតុលាការ។ផ្អែកតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងយ៉ាងច្បាស់ពីអំណាចតុលាការការគ្រប់គ្រងទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាល។ ដោយផ្អែកលើរដ្ឋធម្មនុញ្ញបានបង្ហាញថាគឺមានតែអំណាចតុលាការទេ ដែលមានសិទ្ធិអំណាចនៅក្នុងការសម្រេចសេចក្តីរាល់វិវាទដែលកើតឡើង។ស្ថាប័នតុលាការត្រូវបានធ្វើឡើងក្នុងនាមប្រជារាស្ត្រខ្មែរ ដោយផ្អែកតាមច្បាប់ជាធរមាន ក្នុងការសម្រេចសេចក្តីនេះមានតែចៅក្រមទេ ដែលមានសិទ្ធិក្នុងការសម្រេចដោយគោរពតាមច្បាប់ អស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។

ជាគោលការណ៍មានតែតុលាការព្រហ្មទណ្ឌ គឺទទួលបន្ទុកក្នុងការដោះស្រាយនិងមានសិទ្ធិក្នុងការសម្រេចសេចក្តីទៅលើតែរឿងក្តីព្រហ្មទណ្ឌតែប៉ុណ្ណោះពោលការសម្រេចសេចក្តីរបស់តុលាការព្រហ្មទណ្ឌគឺជាការកំណត់ជោគវាសនាទាំងបុគ្គលនិងនីតិបុគ្គលនៅក្នុងសង្គម ចំពោះបុគ្គលការទទួលខុសត្រូវព្រហ្មទណ្ឌតាមបទល្មើសដែលខ្លួនប្រព្រឹត្ត និងត្រូវអនុវត្តទោសក្នុងពន្ធនាគារគឺដូចបាត់បង់ស្ទើរតែទាំងស្រុងនូវសេរីភាពដែលជាមូលដ្ឋាននៃសិទ្ធិរស់នៅជាចាំបាច់។

តាមរយៈក្រមព្រហ្មទណ្ឌថ្មីនេះគឺមានមុខងារដ៏ចម្បងគឺ ការបង្ក្រាប រាល់អំពើផ្ទុយច្បាប់ បង្ការមិនឱ្យប្រព្រឹត្តបទល្មើសក៏ព្រោះតែជនទាំងនោះភ័យខ្លាចរអារនឹងទោសទណ្ឌកម្មព្រហ្មទណ្ឌហើយ លែងហ៊ានប្រព្រឹត្តបទល្មើសទៀត និងអប់រំឱ្យទណ្ឌិតអាចចូលចុះក្នុងសង្គមវិញបាន។ ពិតណាស់ក្រមព្រហ្មទណ្ឌ មានលក្ខណៈគោរពសិទ្ធិ និងផ្តល់ក្តីអនុគ្រោះជាច្រើនដល់ចារី និងជាពិសេសទណ្ឌិតក្រោយអនុវត្តទោសរួចក្នុងពន្ធនាគារចេញមករស់នៅក្នុងសង្គមវិញបាន។ បន្ថែមពីនេះទៀតក្នុងការសម្រេចសេចក្តីរបស់តុលាការព្រហ្មទណ្ឌគឺ អនុវត្តតាមគោលការណ៍ឯកត្តកម្មនៃទោស ក្នុងការប្រកាសទោសលើជនជាប់ចោទ។ជាមួយគ្នានេះ ក្នុងការសម្រេចរបស់តុលាការគឺមានការកំណត់អំពីស្ថានទម្ងន់ទោស ក្នុងករណីប្រសិនបើជនដែលបានអនុវត្តទោសរួចហើយបែរជាមិនរាងចាលក្នុងការប្រព្រឹត្តបទល្មើសម្តងទៀត។ ចំពោះស្ថានសម្រាលទោសវិញក្នុងក្រមព្រហ្មទណ្ឌមិនត្រឹមមានតែសម្រាលទោសដល់ជនជាប់ចោទជាអនីតិជនទេថែមទាំងមានករណីផ្តល់ស្ថានសម្រាលដល់នីតិជនផងដែរ។ ទន្ទឹមនឹងនេះផងដែរ យើងពិនិត្យឃើញថា ក្រោយពេលក្រមព្រហ្មទណ្ឌបានដាក់ឱ្យអនុវត្តរួចហើយគឺសង្គមជាតិមានសុខសន្តិភាព ការរីកចំរើន ជឿនលឿនលើគ្រប់វិស័យមិនថាវិស័យយុត្តាធិការប៉ុណ្ណោះទេ។

## ២.ចំណោទបញ្ហា

ដោយសារតែទណ្ឌកម្មព្រហ្មទណ្ឌពិតជាប៉ះពាល់ដល់ សិទ្ធិសេរីភាពជាមូលដ្ឋានរបស់បុគ្គលក្នុងសង្គម និងប៉ះពាល់ដល់កត្តិយសទាំងគ្រួសារផងដែរ។ដូច្នេះរាល់ការអនុវត្តនីតិវិធីច្បាប់ចំពោះ ជនជាប់ចោទពិតជាមានសារៈសំខាន់ណាស់ ដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទ ដែលត្រូវបានចោទប្រកាន់ ហើយឈានដល់ការសម្រេចសេចក្តីដោយតុលាការព្រហ្មទណ្ឌនូវទណ្ឌកម្មណាមួយ។ ហេតុដូចនេះហើយទណ្ឌកម្មព្រហ្មទណ្ឌ អាចនាំឱ្យ មាននូវទោសទណ្ឌកម្មចំពោះអ្នកដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌទៅនឹងអ្វីដែលបានប្បញ្ញត្តិយ៉ាងជាក់លាក់ដោយច្បាប់ព្រហ្មទណ្ឌ ទាំងនេះហើយរាល់ការសម្រេចរបស់តុលាការព្រហ្មទណ្ឌ គឺមានលក្ខណៈដាច់ខាត តឹងរឹង នៅក្នុងការប្រកាសទោសចំពោះជនជាប់ចោទឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ។ក្នុងនោះដែរ ក្នុងក្រមព្រហ្មទណ្ឌបានពិនិត្យឃើញថាមានតុលាការអាចសម្រេចការព្យួរទោសឱ្យទណ្ឌិតបាន ទោះបីជាទណ្ឌិតបានប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមក៏ដោយ។ចំណុចនេះហើយដែលក្រមព្រហ្មទណ្ឌបានបន្ធូរបន្ថយទោសទណ្ឌកម្មចំពោះបុគ្គលក្នុងសង្គមរបស់យើង។

ហេតុដូចនេះ នៅក្នុងសារណានេះ ខ្ញុំបានលើកឡើងយកប្រធានបទអំពី ការកំណត់ទោសដោយចៅក្រមយកមកសរសេរជាសារណា គឺដើម្បីឱ្យសិស្សនិស្សិតច្បាប់ ឱ្យយល់ពីអ្វីជាមូលដ្ឋានក្នុងការប្រកាសទោសនេះ? តើមានវិធានបទប្បញ្ញត្តិអ្វីខ្លះទើប តុលាការអាចប្រកាសទោសបានតាមឆន្ទានុសិទ្ធិដែលក្រមព្រហ្មទណ្ឌបានប្រគល់ឱ្យ? ហើយតើផលប្រយោជន៍ក្នុងការប្រកាសទោសបានផ្តល់ប្រយោជន៍ឱ្យដល់ជនជាប់ចោទនិងទណ្ឌិតអ្វីខ្លះ?

ដោយជាហេតុថា គឺមានតែតុលាការព្រហ្មទណ្ឌតែប៉ុណ្ណោះគឺជាអ្នកមានសិទ្ធិសម្រេចជោគវាសនាទៅលើបុគ្គលនិងនីតិបុគ្គលក្នុងសង្គម ដែលបានប្រព្រឹត្តនូវអំពើណាមួយដែលប្បញ្ញត្តិយ៉ាងជាក់លាក់ក្នុងច្បាប់ព្រហ្មទណ្ឌ។នៅក្នុងការសម្រេចសេចក្តី អំពីបុគ្គល ដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌក្នុងទោសប្រភេទណាមួយ គឺមានស្ថានភាពជាច្រើនដែលត្រូវបានតុលាការយកមកពិចារណា ពោលគឺដូចជា ស្ថានទម្ងន់ទោស ស្ថានសម្រាលទោស ការព្យួរទាំងមូល ឬមួយផ្នែក ការបែងចែកទោសជាប្រភាគ និងរបបពាក់កណ្តាលសេរីភាព ឬខជាមួយនឹងកត្តាជាច្រើនទៀតដូចជា ស្ថានភាពគ្រួសារ ពេលវេលា ស្ថានភាពហិរញ្ញវត្ថុ ការប្រព្រឹត្តបទល្មើស និងបុគ្គលិកលក្ខណៈរបស់ជនល្មើសមុនពេលប្រព្រឹត្តបទល្មើសនីមួយ។ដោយសារស្ថានភាពនេះហើយ ដែលធ្វើឱ្យតុលាការយកមកពិចារណាទៅលើការវិនិច្ឆ័យ និង វិធានការដោយប្រើផ្សេងៗដែល ក្រមព្រហ្មទណ្ឌបានផ្តល់សិទ្ធិឱ្យក្នុងការសម្រេចសេចក្តីរបស់តុលាការទៅលើបុគ្គលក្នុងសង្គម។

## ៣.គោលបំណងនៃការសិក្សាស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវ និងការរៀបចំតាក់តែងឯកសារដែលជាសារណានេះឡើង គឺមានគោលបំណងនិងគោលដៅសិក្សាស្រាវជ្រាវ ដូចអ្វីដែលបានបរិយាយដូចខាងលើនេះ គឺដើម្បីការពង្រឹងនិងពង្រីកនូវសមត្ថភាពបន្ថែមចំពោះចំណេះដឹងនិស្សិតបញ្ញាវ័ន្ត ដើម្បីបន្ថែមនូវចំណេះដឹងខាងបញ្ញា ហើយក៏ជាទុនមួយជាឯកសារដល់និស្សិតបញ្ញាវ័ន្តជំនាន់ក្រោយៗទៀត ធ្វើការស្វែងយល់និងជាចំណេះដឹងមួយផ្នែក ឱ្យយល់នូវខ្លឹមសារគោលគំនិត អ្វីទៅជាការកំណត់ទោសរបស់ចៅក្រម ? អ្វីទៅជាឆន្ទានុសិទ្ធិរបស់ចៅក្រមក្នុងការសម្រេចសេចក្ដីដែលក្រមព្រហ្មទណ្ឌបានផ្ដល់សិទ្ធិក្នុងការសម្រេចតាមផ្លូវច្បាប់? បន្ថែមពីនេះទៀត និស្សិតក៏អាចយល់ដឹងនិងស្វែងយល់ផងដែរនូវរបបនៃការប្រកាសទោសចំពោះទណ្ឌិត ការសម្រេចសេចក្ដីរបស់តុលាការក្នុងករណីមានបទល្មើសត្រួតគ្នាការផ្ដល់ស្ថានទម្ងន់ទោស និងស្ថានសម្រាលទោសដល់ជនជាប់ចោទ ។

## ៤.ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

ជាការឆ្លើយតបទៅនឹងប្រធានបទសារណាមួយនេះដែលបានលើកឡើងក្នុងចំណោទបញ្ហាខាងលើ ខ្ញុំបាទបានខិតខំធ្វើការស្រាវជ្រាវទៅលើឯកសារជាមូលដ្ឋាន គឺក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ និងបទប្បញ្ញត្តិពិសេសជាច្រើនទៀតដែលជាមូលដ្ឋានមួយផ្នែកដែលបានលើកឡើងនៅក្នុងឯកសារពិគ្រោះ ដើម្បីសរសេរនូវសារណានេះឡើងបានចែងចេញជា៣ជំពូក។

នៅក្នុងសារណានេះ ខ្ញុំសរសេរអំពីការស្ថានភាពទាំងឡាយណាដែលពាក់ព័ន្ធជាមូលដ្ឋានក្នុងការកំណត់ទោសដោយចៅក្រម ដែលជាផ្នែកមួយនៃក្រមព្រហ្មទណ្ឌ។ បន្ថែមពីនេះទៀតខ្ញុំក៏បានលើកឡើងបន្ថែមនូវវិធានការរបស់តុលាការក្នុងការកំណត់ទោសដោយផ្អែកលើការអនុវត្តសេចក្ដីសម្រេចរបស់តុលាការ។

## ៥.វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសរសេរសារណានេះ ខ្ញុំបានធ្វើការអានជាច្រើនដង ច្រើនលើកនូវគោលគំនិតនៃបទប្បញ្ញត្តិនីមួយៗនិងវិភាគ។ចំពោះការសិក្សាស្រាវជ្រាវបានធ្វើឡើងតាមរយៈវិធីសាស្ត្រដូចខាងក្រោម៖

វិធីសាស្ត្រក្នុងការប្រមូលឯកសារ គឺបានប្រមូលនៅបណ្ណាល័យនីតិសាស្ត្ររបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគេហទំព័ររបស់បណ្ណាល័យនីតិសាស្ត្ររបស់សាកលវិទ្យាល័យ ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ព្រមទាំងឯកសារជាច្រើនទៀតនៅតាមគ្រឹះស្ថានអប់រំមួយចំនួនក្នុងវិស័យច្បាប់។

បន្ថែមពីនេះទៀត គឺប្រមូលតាមព័ត៌មានតាមរយៈការសិក្សាតាមបណ្ដាគេហទំព័រមួយចំនួន ដែលបានផ្សព្វផ្សាយកន្លងមក។

## ៦.សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះសារណានេះអាចឱ្យសិស្សនិស្សិតច្បាប់ និងមិត្តអ្នកអានទទួលបានគំនិតនិងទុកជាជំនួយស្មារតីដល់ការសិក្សាស្រាវជ្រាវ និងចង់ពង្រឹងចំណេះដឹងខាងវិស័យព្រហ្មទណ្ឌ ដើម្បីយល់កាន់តែស៊ីជម្រៅក្នុងច្បាប់ព្រហ្មទណ្ឌ និងច្បាប់ពិសេសផងដែរ មានន័យថាក្នុងសារណានេះពីការកំណត់ទោសដោយចៅក្រមក្នុងការកំណត់ទោស ការផ្តន្ទាទោសក្នុងកម្រិតអតិបរមានៃទោស និងក្នុងកម្រិតអប្បបរមានៃទោស។បន្ថែមទាំងយល់ដឹងពីការកំណត់ស្ថានទម្ងន់ទោស ការផ្តល់ស្ថានសម្រាលទោស ជាពិសេសសិទ្ធិស្វ័យសម្រេចរបស់តុលាការក្នុងការផ្តន្ទាទោស។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងគម្រោងប្លង់នៃសារណាបញ្ចប់ការសិក្សា លើប្រធានបទស្តីពី ការកំណត់ទោសដោយចៅក្រម នេះខ្ញុំបានបែងចែកចេញជា ៣ ជំពូក ដូចខាងក្រោមនេះ៖

-**ជំពូកទី១** ការកំណត់ទោសជាទូទៅដោយចៅក្រម

-**ជំពូកទី២** ការកំណត់ទោសដោយ ចៅក្រម ក្នុងករណីបទល្មើសត្រួតគ្នា

-**ជំពូកទី៣** ការកំណត់ទោស ដោយ ចៅក្រម ក្នុងករណីមានស្ថានទម្ងន់ទោស ឬស្ថានសម្រាលទោស

# ជំពូកទី១

# ការកំណត់ទោសជាទូទៅដោយចៅក្រម

# ជំពូកទី១
# ការកំណត់ទោសជាទូទៅដោយចៅក្រម

យោងតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ ចៅក្រមអាចកំណត់វិធានការមួយចំនួនផ្សេងទៀត ដើម្បីកំណត់ទោសដែលចៅក្រមត្រូវផ្តន្ទាទោសទៅលើ ចារីដែលបានប្រព្រឹត្តបទល្មើសនៅក្នុងលក្ខខណ្ឌកំណត់ដោយច្បាប់។ចំពោះវិធានការទាំងនោះរួមមានការព្យួរទោស (**១.១**)ការបែងចែងទោសជាប្រភាគ(**១.២**) និង របបពាក់កណ្តាលសេរីភាព(**១.៣**)។

## ១.១.ការព្យួរទោស

ការព្យួរទោសមានន័យថា ការប្រកាសការព្យួរទោសការអនុវត្តគឺការព្យួរនូវមូលទោសទាំងស្រុង ឬមួយផ្នែកនៃមូលទោស។ក៏ប៉ុន្តែ តុលាការមិនអាចព្យួរទៅលើទោសបន្ថែម ឬទោសជំនួសបានទេ។ការព្យួរទោសក៏ជាការលើកចោលដោយមានលក្ខខណ្ឌនូវការអនុវត្តមូលទោសដែលបានប្រកាសដោយតុលាការ។

យោងតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌបានកំណត់ចាប់ពីមាត្រា ១០៤ ដល់មាត្រា ១២៣ ពីការបែងចែកការព្យួរទោសជាពីរប្រភេទ គឺការព្យួរទោសធម្មតា(**១.១.១**) និងការព្យួរទោសសាកល្បង(**១.១.២**)។

### ១.១.១.ការព្យួរទោសធម្មតា

ការព្យួរទោសធម្មតា គឺជាការព្យួរទោសដែលមិនមានដាក់ឱ្យចារីស្ថិតនៅក្រោមការត្រួតពិនិត្យ និងគោរពនូវកាតព្វកិច្ចដោយឡែក ឬច្រើននោះទេ។ [1] ការព្យួរទោសធម្មតា គឺជាវិធានការមួយដែលពុំបានបង្កើតសិទ្ធិសម្រាប់ចារីឡើយគ្រាន់តែជាការអនុគ្រោះដែលតុលាការមានសិទ្ធិអំណាច តាមច្បាប់ផ្តល់ឱ្យក្នុងការអនុញ្ញាតឱ្យព្យួរទោស ឬ មិនគួរឱ្យព្យួរទោសក៏ព្រោះតែការសម្រេចនេះជាឆន្ទានុសិទ្ធិរបស់តុលាការក្នុងការសម្រេច។កាលណាតុលាការសម្រេចឱ្យមានការព្យួរទោសធម្មតា មានន័យថាជនជាប់ចោទត្រូវទទួលរងនូវមូលទោសចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត ក៏ប៉ុន្តែមូលទោសនេះត្រូវបានព្យួរទុកមិនអនុវត្តទាំងមូល ឬមួយផ្នែក។ផ្ទុយមកវិញទោះបីជាមានគ្រប់លក្ខខណ្ឌដែលច្បាប់ចែងក៏ដោយក៏មិនមែនមានន័យថា តុលាការមានករណីយកិច្ចត្រូវតែប្រកាសការព្យួរទោសជាប្រយោជន៍ដល់ជនជាប់ចោទនោះទេ។[2]

យោងតាមក្រមព្រហ្មទណ្ឌ បានកំណត់អំពីលក្ខខណ្ឌដែលតុលាការអនុញ្ញាតក្នុងការដាក់ឱ្យលក្ខខណ្ឌនៃការព្យួរទោសធម្មតា(**១.១.១.១**)ដែលនឹងត្រូវមានអានុភាពលើកចោលនូវការអនុវត្តទោស(**១.១.១.២**)។

---

[1] យោងតាមមាត្រា ១០៦ ដល់ មាត្រា ១១៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[2] សៀវភៅសិក្សានីតិព្រហ្មទណ្ឌទូទៅ ដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ទំព័រ៤៩៧

### ១.១.១.១.លក្ខខណ្ឌនៃការព្យួរទោសធម្មតា

ដើម្បីអនុញ្ញាតយល់ព្រមឱ្យមានការព្យួរទោសធម្មតា តុលាការត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់អំពីលក្ខខណ្ឌផ្សេងៗ ដែលក្រមព្រហ្មទណ្ឌបានកំណត់ឱ្យគ្រប់ជ្រុងជ្រោយជាមុនសិន។ មុនដំបូងតុលាការត្រូវពិនិត្យលើលក្ខខណ្ឌទាក់ទងនឹងទោសដែលត្រូវព្យួរ និងបន្ទាប់មកពិនិត្យទៅលើ លក្ខខណ្ឌអំពីប្រវត្តិនៃការផ្តន្ទាទោសជនជាប់ចោទនាពេលកន្លងមក។[3]

ក.លក្ខខណ្ឌទាក់ទងនឹងទោសដែលត្រូវព្យួរ

ការព្យួរទោសធម្មតាមិនអាចអនុវត្តទៅលើគ្រប់ប្រភេទនៃទោសបានទេ។[4]នៅក្នុងលក្ខខណ្ឌនេះតុលាការអាចប្រកាសព្យួរទោសនេះបាននៅពេលទោសដាក់ពន្ធនាគារមានរយៈពេលតិចជាង ឬស្មើ៥ឆ្នាំ ឬក៏ទោសប្រកាសជាទោសពិន័យជាប្រាក់តែប៉ុណ្ណោះសម្រាប់បទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលតុលាការអាចត្រូវបានពិចារណាយល់ព្រមឱ្យព្យួរទោសធម្មតាបាន។ ក្នុងការព្យួរទោសធម្មតានេះដែរ ក្នុងក្រមព្រហ្មទណ្ឌតម្រូវឱ្យយកទោសប្រកាស មកធ្វើជាមូលដ្ឋានក្នុងការកំណត់ក្នុងការព្យួរទោសធម្មតា។ឧបមាថា ប្រសិនបើតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន៧ឆ្នាំ ដោយសារតែជនជាប់ចោទបានប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈគឺជាបទឧក្រិដ្ឋ តាមមាត្រា២៣៩នៃក្រមព្រហ្មទណ្ឌ។ ចំពោះទោសប្រកាសនេះមានចំនួនលើសពីលក្ខខណ្ឌនៃការព្យួរទោសធម្មតាទោសនេះមិនអាចអនុញ្ញាតឱ្យព្យួរបានឡើយ។ ផ្ទុយមកវិញក្នុងករណីប្រសិនបើ តុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារចំនួន ៥ឆ្នាំ តាមមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌគឺជាបទឧក្រិដ្ឋ ទោសនេះតុលាការអាចសម្រេចឱ្យព្យួរបានធម្មតា។បន្ថែមពីនេះទៀត ក្នុងករណីជនជាប់ចោទបានប្រព្រឹត្តបទលហុវិញ ក្រមព្រហ្មទណ្ឌមិនបានប្បញ្ញត្តិបញ្ជាក់ពីចិរវេលាជាក់លាក់នៃទោសប្រកាសដែលជា លក្ខខណ្ឌនៃការអនុញ្ញាតការព្យួរទោសធម្មតា មាននន័យថាក្នុងករណីជនជាប់ចោទបានប្រព្រឹត្តបទលហុ ការព្យួរទោសធម្មតាអាចអនុវត្តបានទាំងទោសដាក់ពន្ធនាគារនិងទោសពិន័យជាប្រាក់។[5]

ខ.លក្ខខណ្ឌទាក់ទងនឹងប្រវត្តិនៃការផ្តន្ទាទោស

នៅក្នុងករណីនេះជនជាប់ចោទ គឺតុលាការមិនអនុញ្ញាតចំពោះជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើសម្តងហើយម្តងទៀតឡើយ។ហេតុដូច្នេះ ការប្រកាសពីការព្យួរទោសធម្មតា តម្រូវឱ្យមានការត្រួតពិនិត្យអំពីប្រវត្តិរបស់ជនជាប់ចោទ តាមរយៈបញ្ជីថ្កោលទោស បន្ថែមពីនេះទៀតក្រមព្រហ្មទណ្ឌបានផ្តល់សារៈសំខាន់ជាពិសេស ដល់ប្រវត្តិនៃការផ្តន្ទាទោសលើជនជាប់ចោទនេះ។ ចំពោះបទឧក្រិដ្ឋ ឬ បទមជ្ឈិម តុលាការអាចសម្រេច

---

[3] សៀវភៅសិក្សានីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ២០២២ ដោយលោកសាស្ត្រាចារ្យ នុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ទំព័រ ៤៩៩

[4] យោងតាមមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[5] យោងតាមមាត្រា ១១៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ផ្ដល់ការព្យួរទោសធម្មតាបានក្នុង លក្ខខណ្ឌទាក់ទងនឹងការផ្ដន្ទាទោសពីមុន ក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ ការព្យួរទោសធម្មតាអាចត្រូវផ្ដល់ឱ្យបាន ប្រសិនបើជនជាប់ចោទមិនទាន់មានការផ្ដន្ទាទោសជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ៥ឆ្នាំ មុនអំពើល្មើស។[6] ចំណែកចំពោះបទលហុ ក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសធម្មតាអាចត្រូវបានប្រកាស ប្រសិនបើជនជាប់ចោទ មិនទាន់ត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារជាស្ថាពរនៅឡើយ នៅក្នុងរយៈពេល ១ឆ្នាំ មុនបទល្មើសនេះ។[7]បន្ថែមពីនេះទៀត បទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌមិនបានចែងបញ្ជាក់ពីការផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារ ដែលជាលក្ខខណ្ឌចាំបាច់នៃការព្យួរទោសធម្មតានេះឡើយ ពោលត្រូវតែជាការផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារដោយពិតប្រាកដ ឬមួយត្រឹមតែជាការផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារដោយមានការព្យួរទោសក៏បានដែរនោះឡើយ។ហេតុនេះហើយ គឺមានន័យថា ប្រសិនបើជនជាប់ចោទធ្លាប់ត្រូវបានតុលាការសម្រេចផ្ដន្ទាទោសដោយមានការព្យួរទោសក៏ពិតមែន ក៏ស្ថានភាពនេះក៏ត្រូវតែយកមកពិចារណាក្នុងលក្ខខណ្ឌនៃការព្យួរទោសដែរ។

ឧទាហរណ៍៖ នៅដើមឆ្នាំ ២០១៩ ជនជាប់ចោទឈ្មោះ ចន្ទ ត្រូវបានតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារចំនួន ២ឆ្នាំ ពីបទហិង្សាដោយចេតនា តាមមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។បន្ទាប់មក ការផ្ដន្ទាទោសពីបទល្មើសហិង្សាដោយចេតនាបានចូលជាស្ថាពរនៅចុងឆ្នាំ ២០១៩ ។ ក្រោយមកនៅក្នុងឆ្នាំ ២០២២ ជនជាប់ចោទឈ្មោះ ចន្ទ ដដែលត្រូវបានរកឃើញមានពិរុទ្ធភាពពី បទឆបោក តាមមាត្រា៣៧៧ នៃក្រមព្រហ្មទណ្ឌ។ក្នុងករណីនេះ ជនជាប់ចោទមិនអាចទទួលបានការប្រកាសព្យួរទោសទេ ក៏ព្រោះតែជនជាប់ចោទដដែលធ្លាប់មានប្រវត្តិត្រូវបានតុលាការសម្រេចផ្ដន្ទាទោសជាស្ថាពរឱ្យជាប់ពន្ធនាគាររយៈពេល៣ឆ្នាំ(គិតចាប់ពី ២០១៩ ដល់ឆ្នាំ ២០២២) មុនពេលដែលបទឆបោកបានកើតឡើង។

ផ្ទុយមកវិញយោងតាមសម្មតិកម្មខាង ប្រសិនបើការផ្ដន្ទាទោសជាស្ថាពរពីបទហិង្សាដោយចេតនា បានប្រព្រឹត្តឡើងនៅឆ្នាំ២០១៥វិញ ហើយជនជាប់ចោទត្រូវបានតុលាការរកឃើញពីពិរុទ្ធភាពពីបទឆបោក នៅក្នុងឆ្នាំ ២០២២វិញ គឺជនជាប់ចោទនឹងទទួលបានអត្ថប្រយោជន៍ពីការព្យួរទោសធម្មតាបាន ក៏ព្រោះតែបើគិតដល់ឆ្នាំ ២០២២ ការផ្ដន្ទាទោសជាស្ថាពរពីបទល្មើសមុនបានកន្លងផុតទៅអស់រយៈពេល ៧ឆ្នាំ(គិតចាប់ពីឆ្នាំ ២០១៥ដល់ឆ្នាំ២០២២) ទៅហើយគឺជារយៈពេលលើសពីការកំណត់ដោយច្បាប់។

ជាមួយគ្នានេះផងដែរ ចំពោះការផ្ដន្ទាទោសពិន័យជាប្រាក់ ឬ ទោស ដែលបទប្បញ្ញត្តិជាមួយបទល្មើសដែលបានប្រព្រឹត្ត ឬមួយទោសផ្សេងទៀតក្រៅពីទោសដាក់ពន្ធនាគារគឺមិនមែនជាកត្តាដែលជាឧបសគ្គក្នុងការប្រកាសការព្យួរទោសនោះឡើយ ពោលគឺថាប្រសិនបើជនជាប់ចោទធ្លាប់ត្រូវបានតុលាការសម្រេចផ្ដន្ទាទោសជា

[6] យោងតាមមាត្រា ១០៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[7] យោងតាមមាត្រា ១១២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ស្ថាពរឱ្យបង់ប្រាក់ពិន័យ ឬ ទោសផ្សេងទៀតក្រៅពីទោសដាក់ពន្ធនាគារ។ក្នុងករណីនេះគឺមិនបានរារាំងដល់តុលាការក្នុងការប្រកាសការព្យួរទោសឡើយ ក៏ព្រោះតែប្រសិនបើពិនិត្យទៅលើបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ មាត្រា ១០៦ និងមាត្រា១១២ គឺបានចែងតែក្នុងករណីដែលជនជាប់ចោទធ្លាប់ត្រូវបានតុលាការផ្ដន្ទាទោសស្ថាពរ ដោយមិនបានចែងពីការមិនអនុញ្ញាតឱ្យតុលាការប្រកាសការព្យួរទោសក្នុងករណីដែលជនជាប់ចោទធ្លាប់ត្រូវបានតុលាការផ្ដន្ទាទោសពិន័យជាប្រាក់ឬទោសផ្សេងទៀតក្នុងក្រមព្រហ្មទណ្ឌក្រៅពីទោសដាក់ពន្ធនាគារ។

### ១.១.១.២.អានុភាពនៃការព្យួរទោសធម្មតា

ការព្យួរទោសធម្មតាគឺជាការលើកលែងមិនឱ្យអនុវត្តទោសមួយផ្នែក ឬ ទាំងស្រុងចំពោះជនជាប់ចោទ។ ជនជាប់ចោទនឹងទទួលបានការលើកលែងមិនឱ្យអនុវត្តទោសនេះភ្លាមៗ ក៏ប៉ុន្តែទណ្ឌិតដាច់ខាតមិនត្រូវទទួលរងការផ្ដន្ទាទោសណាមួយផ្សេងទៀតឡើយក្នុងរយៈពេលនៃការព្យួរទោសនេះ។ ជាមួយគ្នានេះផងដែរ ជនជាប់ចោទដែលទទួលបានការព្យួរទោសធម្មតានេះ តុលាការនឹងដោះលែងភ្លាមពីពន្ធនាគារ ប្រសិនបើជនជាប់ចោទត្រូវបានសម្រេចឱ្យឃុំខ្លួនជាបណ្ដោះអាសន្ន មុនពេលប្រកាសទោស។

យោងតាមក្រមព្រហ្មទណ្ឌរយៈពេលសាកល្បង នៃការព្យួរទោសធម្មតាគឺចំនួន៥ឆ្នាំ សម្រាប់បទឧក្រិដ្ឋ ឬបទមជ្ឈិមសំរាប់រយៈពេលសាកល្បងនេះ ត្រូវគិតពីពេលដែលសេចក្ដីសម្រេចផ្ដន្ទាទោសបានចូលជាស្ថាពរ។[8]

ប្រសិនបើរយៈពេល ៥ឆ្នាំ បន្ទាប់ពីការផ្ដន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយការព្យួរទោសធម្មតាហើយគ្មានការផ្ដន្ទាទោសជាថ្មីជាស្ថាពរមួយទៀតពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះទេ ការផ្ដន្ទាទោសដោយមានការព្យួរនេះត្រូវចាត់ទុកជាអសារបង់ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ។ [9] ការផ្ដន្ទាទោសត្រូវបានចាត់ទុកថាពុំធ្លាប់បានប្រកាសទាល់តែសោះ ហើយការផ្ដន្ទាទោសនេះពុំអាចយកមកធ្វើជាឧបសគ្គដល់ការផ្ដល់នៅការព្យួរទោសថ្មីទៀតទេ ប្រសិនបើបទល្មើសថ្មីមួយទៀតបានប្រព្រឹត្ត បន្ទាប់ពីរយៈពេល ៥ឆ្នាំ ដែលចាប់ផ្ដើមគិតពីពេលដែលការផ្ដន្ទាទោសចូលជាស្ថាពរ។ ការព្យួរទោសធម្មតា ត្រូវបានដកហូតដោយពេញច្បាប់ ប្រសិនបើរយៈពេល ៥ឆ្នាំ បន្ទាប់ពីការផ្ដន្ទាទោសជាស្ថាពរពី បទឧក្រិដ្ឋ ឬ បទមជ្ឈិម ដោយមានការព្យួរទោសធម្មតា ហើយមានការផ្ដន្ទាទោសថ្មីជាស្ថាពរមួយទៀតពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដោយមានការព្យួរទោសធម្មតា ហើយមានការផ្ដន្ទាទោសថ្មីជាស្ថាពរមួយទៀតពីបទឧក្រិដ្ឋ ឬបទមជ្ឈិម។ជាមួយគ្នានេះ ទោសទី១ ត្រូវអនុវត្តដោយមិនអាចស្រូបទោសចូលជាមួយ ទោសទី២ បានឡើយ។យោងតាមក្រមព្រហ្មទណ្ឌរយៈពេលសាកល្បងនៃការព្យួរទោសធម្មតាគឺចំនួន ១ឆ្នាំសម្រាប់បទលហុ សំរាប់រយៈពេលសាកល្បងនេះ ត្រូវគិតពីពេលដែលសេចក្ដីសម្រេចផ្ដន្ទាទោសបានចូលជាស្ថាពរ។

---

[8] យោងតាមមាត្រា ១១១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[9] យោងតាមមាត្រា ១១១ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ចំពោះបទលហុ វិធានទាំងឡាយមានលក្ខណៈដូចគ្នាទៅនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលបានបរិយាយខាងលើលើកលែងតែរយៈពេលដែលត្រូវកម្រិតត្រឹមតែ ១ឆ្នាំ។ដូច្នេះប្រសិនបើក្នុងរយៈពេល១ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទលហុដែលមានការព្យួរទោសធម្មតា ស្រាប់តែមានការផ្តន្ទាទោសថ្មីពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការព្យួរទោសធម្មតានេះ ត្រូវបានដកហូតដោយពេញច្បាប់ហើយ ទោសទីមួយ ត្រូវអនុវត្តដោយពុំអាចស្រូបចូលជាមួយ ទោសទីពីរ បានឡើយ។ក៏ប៉ុន្តែតុលាការនៅតែអាចសម្រេច តាមរយៈសេចក្តីសម្រេចដោយមានសំអាងហេតុពិសេសថាការផ្តន្ទាទោសថ្មីនេះ ពុំបណ្តោយឱ្យមានការដកហូតនូវការព្យួរទោសដែលត្រូវបានផ្តល់ឱ្យពីមុនមក។ បន្ថែមពីនេះ វិធានទាំងឡាយស្តីពីលក្ខខណ្ឌនៃការផ្តន្ទាទោសដោយមានការព្យួរទោសធម្មតាត្រូវចាត់ទុកជាអសារបង់ មានលក្ខណៈដូចគ្នានឹងករណីបទឧក្រិដ្ឋ ឬ បទមជ្ឈិមលើកលែងតែ រយៈពេលកំណត់សម្រាប់ការទុកជាអសាបង់នូវការផ្តន្ទាទោសគឺត្រឹមតែ១ឆ្នាំ។

-កំណត់សម្គាល់ ភាពខុសគ្នាមួយដែលត្រូវកត់សម្គាល់ត្រង់ថា ការដកហូតនៅការព្យួរទោសធម្មតាចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចធ្វើទៅក្នុងករណីដែលមានការផ្តន្ទាទោសជាស្ថាពរថ្មីពីបទឧក្រិដ្ឋ ឬបទមជ្ឈិមតែមិនមែនចំពោះបទលហុឡើយ។ ចំណែកការដកហូតនូវការព្យួរទោសធម្មតាដែលត្រូវបានប្រកាសចំពោះបទលហុវិញ អាចធ្វើទៅក្នុងករណីដែលមានការផ្តន្ទាទោសជាស្ថាពរថ្មីមួយពី បទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។

ប្រសិនបើអត្ថប្រយោជន៍នៃការព្យួរទោសធម្មតានេះត្រូវបានទៅលើតែមួយផ្នែកនៃទោសនេះ ការផ្តន្ទាទោសនេះត្រូវចាត់ទុកអសារបង់ទាំងស្រុង មានន័យថាទោសដែលតុលាការបានសម្រេចផ្តន្ទាទោស មិនអាចយកមកអនុវត្តបានទៀតឡើយ។ បន្ថែមពីនេះទៀត នៅក្នុងករណីដែលតុលាការបានសម្រេចឱ្យមានការផ្តន្ទាដាក់ពន្ធនាគារ និងពិន័យជាប្រាក់ផងសម្រាប់ទណ្ឌិតក៏ប៉ុន្តែមានតែទោសដាក់ពន្ធនាគារដែលត្រូវបានតុលាការសម្រេចអនុញ្ញាតឱ្យព្យួរទោសនេះ តែទណ្ឌិតនៅតែមានកាតព្វកិច្ចត្រូវតែបង់ប្រាក់ពិន័យ តាមការសម្រេចរបស់តុលាការ។ ករណីប្រសិនបើតុលាការសម្រេចឱ្យព្យួរទោសពិន័យជាប្រាក់ត្រឹមតែចំនួនមួយផ្នែក គឺទណ្ឌិតនៅតែមានកាតព្វកិច្ចបង់ប្រាក់ពិន័យមួយផ្នែកដែលតុលាការមិនបានអនុញ្ញាតឱ្យព្យួរ។

ផ្ទុយពីនេះ ប្រសិនបើក្នុងករណីដែលតុលាការបានសម្រេចឱ្យមានការផ្តន្ទាទោសថ្មីពី បទឧក្រិដ្ឋ ឬបទមជ្ឈិមមួយទៀតក្នុងរយៈពេលសាកល្បង ហើយការផ្តន្ទាទោសថ្មីនេះបានចូលជាស្ថាពរ ការព្យួរទោសនឹងត្រូវដកហូតមកវិញ មានន័យថាទណ្ឌិតត្រូវតែអនុវត្តទោសទីមួយដែលតុលាការសម្រេចអនុញ្ញាតឱ្យមានការព្យួរទោសទោសទី១ និងទោសទី២ដែលតុលាការបានសម្រេចផ្តន្ទាទោស សម្រាប់បទល្មើសថ្មីនេះ ដោយពុំមានលទ្ធភាពអនុវត្តនូវគោលការណ៍ស្រូបទោសបានឡើយ។

ឧទាហរណ៍៖ ជនជាប់ចោទម្នាក់ត្រូវបានតុលាការផ្តន្ទាទោសពីបទមជ្ឈិមឱ្យជាប់ពន្ធនាគារចំនួន២ឆ្នាំ ពីបទហិង្សាដោយចេតនា តាមមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ ក៏ប៉ុន្តែតុលាការបានសម្រេចឱ្យមានការព្យួរទោស

ធម្មតាចំពោះមូលទោស។មុនផុតរយៈពេល ៥ឆ្នាំ ជនដដែលបានប្រព្រឹត្តបទល្មើសថ្មីមួយទៀតគឺបទកំហែងយក តាមមាត្រា៣៦៣ នៃក្រមព្រហ្មទណ្ឌ ហើយត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ៣ឆ្នាំ។ ឧបមាថា ការផ្តន្ទាទោសនេះបានចូលជាស្ថាពររួចហើយ ដូច្នេះ ទណ្ឌិតត្រូវតែអនុវត្តទោសដោយបូកបញ្ចូលគ្នាសរុប ទាំងទោសទី១(ទោសដែលតុលាការអនុញ្ញាតព្យួរលើកមុន ត្រូវបានដកហូត ដោយសារមានការប្រព្រឹត្តបទល្មើសថ្មីក្នុងរយៈសាកល្បង) នឹងទោសទី២(ទោសដែលតុលាការផ្តន្ទាទោសសម្រាប់បទល្មើសថ្មី) គឺ៥ឆ្នាំ ជាសរុបជនជាប់ចោទខាងលើត្រូវតែអនុវត្តទោសដាក់ពន្ធនាគារចំនួន៥ឆ្នាំ ក្នុងពន្ធនាគារ។

ជាមួយគ្នានេះក្រមព្រហ្មទណ្ឌបានផ្តល់លទ្ធភាពទុកឱ្យតុលាការសម្រេចថាតើគួរតម្រូវឱ្យ ការផ្តន្ទាទោសបទល្មើសថ្មីនេះ នឹងជម្រុញនាំឱ្យមានការដកហូតមកវិញនូវការព្យួរទោសសម្រាប់បទល្មើសមុន ឬក៏យ៉ាងណា។ ក្នុងករណីដែលតុលាការបានសម្រេចថា ការផ្តន្ទាទោសថ្មី គឺពិតជាមិនតម្រូវឱ្យមានការដកហូតការព្យួរទោសកាលពីលើកមុនទេ ក៏ប៉ុន្តែតុលាការត្រូវតែគូសបញ្ជាក់ពី សំអាងហេតុជាពិសេសនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន។[10] ក្នុងករណីបែបនេះគឺ ជនល្មើសត្រូវអនុវត្តតែទោសដែលនឹងសម្រេចដោយតុលាការក្នុងការផ្តន្ទាទោសតែបទល្មើសថ្មីតែប៉ុណ្ណោះ។បន្ថែមពីនេះ គឺក្រមព្រហ្មទណ្ឌមិនបានបញ្ជាក់ទេថាសំអាងហេតុជាពិសេសនោះ ដែលតុលាការសម្រេចក្នុងសេចក្តីសម្រេចរបស់ខ្លួនឡើយ ដែលអនុញ្ញាតឱ្យតុលាការសម្រេចមិនដកហូតការព្យួរទោសនោះ។ ដូច្នេះ តុលាការនឹងពិចារណាទៅតាមស្ថានភាពជាពិសេសនៃអង្គហេតុនីមួយៗដែលជនល្មើសបានប្រព្រឹត្ត។

### ១.១.២.ការព្យួរទោសសាកល្បង

ការព្យួរទោសសាកល្បងគឺខុសគ្នាពីការព្យួរទោសធម្មតាដែលចែងក្នុងក្រមព្រហ្មទណ្ឌ ខុសប្លែកពីការព្យួរទោសធម្មតាគឺដោយការព្យួរទោសសាកល្បងមានអានុភាព ឱ្យជនជាប់ទោសស្ថិតក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវការព្វកិច្ចដោយឡែកណាមួយ ឬច្រើនក្នុងរយៈដែលត្រូវបានកំណត់ចាប់ពីរយៈពេល ១ឆ្នាំ រហូតដល់ ៣ឆ្នាំ។ [11] ចំពោះក្នុងរយៈពេលសាកល្បងនេះ ជនជាប់ទោសត្រូវទទួលរងនូវវិធានការត្រួតពិនិត្យមួយចំនួន និងគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើនដែលច្បាប់បានកំណត់។បន្ថែមលើសពីនេះអត្ថប្រយោជន៍វិញ នៃការព្យួរទោសសាកល្បង គឺស្ថិតនៅត្រង់ថាតុលាការអាចផ្តល់ឱ្យការព្យួរទោសសាកល្បង ទោះបីជាទណ្ឌិតមានប្រវត្តិនៃការផ្តន្ទាទោសចំពោះបទល្មើសណាក៏ដោយ។[12]

---

[10] យោងតាមមាត្រា ១១០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[11] យោងតាមមាត្រា ១១៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[12] សៀវភៅសិក្សានីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ២០២២ ដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ទំព័រ ៥០៧

ការសម្រេចផ្តល់ការព្យួរទោសសាកល្បង ត្រូវតែបំពេញលក្ខខណ្ឌចាំបាច់នៃការព្យួរទោសសាកល្បង (**១.១.២.១**) វិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែកសម្រាប់ទណ្ឌិតអនុវត្ត (**១.១.២.២**)ជាមួយការដក ហូតមកវិញនូវ ការព្យួរទោសសាកល្បង ក្នុងករណីទណ្ឌិតមិនព្រមគោរពតាមវិធានការដែលបានកំណត់ (**១.១.២.៣**)។

**១.១.២.១លក្ខខណ្ឌនៃការព្យួរទោសសាកល្បង**

អនុលោមតាមមាត្រា១១៧ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌការព្យួរទោសសាកល្បងអាចត្រូវបានផ្តល់ឱ្យជនជាប់ចោទ ប្រសិនបើទោសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារមានរយៈពេលពី ៦ខែ ទៅ ៥ឆ្នាំ។យោងតាមបទប្បញ្ញត្តិនៃមាត្រា១១៧ នេះបានពិនិត្យឃើញថាការព្យួរទោសសាកល្បងនេះមានតែទោសដាក់ពន្ធនាគារតែប៉ុណ្ណោះ គឺមិនមានទោសពិន័យជាប្រាក់ទេ។ដូច្នេះយើងអាចសន្និដ្ឋានបានថា ការព្យួរទោសសាកល្បងសម្រាប់នីតិបុគ្គលមិនបានទទួលផលប្រយោជន៍ពីការព្យួរទោសសាកល្បងបានទេ ក៏ព្រោះតែសម្រាប់នីតិបុគ្គលក្រមព្រហ្មទណ្ឌបានកំណត់តែទោសពិន័យជាប្រាក់តែប៉ុណ្ណោះ គឺមិនមានកំណត់ទោសដាក់ពន្ធនាគារសម្រាប់នីតិបុគ្គលឡើយ។[13]

**១.១.២.២.វិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែករបស់ទណ្ឌិត**

ចំពោះរយៈពេលសាកល្បងគឺមិនអាចតិចជាងរយៈពេល ១ឆ្នាំ ហើយក៏មិនត្រូវលើសពីរយៈពេល ៣ឆ្នាំឡើយ។ដូចនេះ តុលាការត្រូវកំណត់រយៈពេលសាកល្បងឱ្យបានច្បាស់លាស់ នៅក្នុងសេចក្តីសម្រេចរបស់តុលាការ។[14]ចំពោះវិធានការត្រួតពិនិត្យ គឺទណ្ឌិតត្រូវអនុវត្តតាមករណីដូចខាងក្រោមនេះ៖

យោងតាមមាត្រា ១១៩ នៃក្រមព្រហ្មទណ្ឌ វិធានការត្រួតពិនិត្យដែលតម្រូវលើទណ្ឌិតមានដូចតទៅ៖

-ទណ្ឌិតត្រូវគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ។

-ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ។

-ទណ្ឌិតត្រូវប្រគល់ដល់ព្រះរាជអាជ្ញា ឬ ដល់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យនូវគ្រប់ឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឱ្យទៅរស់នៅក្នុងសង្គមវិញ។

-ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរអាស័យដ្ឋានរបស់ខ្លួន។

-ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរមុខរបររបស់ខ្លួន។

-ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស។

[13] យោងតាមមាត្រា ១៦៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[14] យោងតាមមាត្រា ១១៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ក្រៅពីវិធានការត្រួតពិនិត្យហើយ តុលាការក៏អាចតម្រូវឱ្យទណ្ឌិតគោរពនូវការព្វកិច្ចដោយឡែក ឬអាចមានច្រើន នៅក្នុងសេចក្តីសម្រេចរបស់តុលាការ។ជាមួយគ្នានេះ តុលាការអាចកែប្រែកាតព្វកិច្ចដោយឡែកដែលដាក់លើទណ្ឌិតបាន គឺនៅគ្រប់ពេលវេលាតុលាការអាចកែប្រែកាព្វកិច្ចដោយឡែកដែលតម្រូវលើទណ្ឌិតបាន។[15]

តាមមាត្រា១២០ នៃក្រមព្រហ្មទណ្ឌ វិធានការត្រួតពិនិត្យដែលតម្រូវលើទណ្ឌិតមានដូចតទៅៈ

-បំពេញសកម្មភាពខាងវិជ្ជាជីវៈ។

-ទទួលការបង្ហាត់បង្រៀន ឬ ទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ។

-រស់នៅក្នុងទីកន្លែងណាមួយជាកំណត់។

-ទទួលឱ្យពេទ្យធ្វើការពិនិត្យ ឬ ការព្យាបាល។

-បញ្ជាក់ថាខ្លួនរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ។

-ធ្វើការជួសជុលការខូចខាតដែលបណ្តាលមកពីបទល្មើសតាមលទ្ធភាពនៃធនធានរបស់ខ្លួន។

-មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈ ឬ សង្គមដែលអនុញ្ញាត ឬ សម្រួលដល់ការប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីសកម្មភាពដែលហាមឃាត់។

-មិនត្រូវមានមុខនៅទីកន្លែងខ្លះ។ក្នុងករណីនេះ តុលាការបញ្ជាក់អំពីទីកន្លែងដែលហាមឃាត់។

-មិនត្រូវសេពគប់បនល្បែង។

-មិនត្រូវសេពគប់តៀមភេសជ្ជៈស្រវឹង។

-មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ពិសេស ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬ ជនរងគ្រោះនៃបទល្មើស។ ក្នុងករណីនេះតុលាការបញ្ជាក់អំពីបុគ្គលដែលមិនត្រូវសេពគប់ជាមួយ។

-មិនត្រូវកាន់កាប់ ឬ យកតាមខ្លួននូវអាវុធគ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទ។

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តុលាការត្រូវចែងអំពីកាតព្វកិច្ចដោយឡែកដែលតម្រូវលើទណ្ឌិត។ ចំណុចនេះមានន័យថា សេចក្តីសម្រេចរបស់តុលាការត្រូវចង្អុលបង្ហាញពីកាតព្វកិច្ចដោយឡែកមួយ ឬច្រើនដែលត្រូវសម្រេចលើទណ្ឌិត ក៏ប៉ុន្តែតុលាការមិនអាចបង្ខំដល់ទណ្ឌិតឱ្យអនុវត្តកាព្វកិច្ចដែលពុំបានកំណត់នៅក្នុងកាតព្វកិច្ចដោយឡែកដូចបានរៀបរាប់ខាងលើទេ។

### ១.១.២.៣.ការដកហូតការព្យួរទោសសាកល្បង

កាលណាតុលាការប្រកាសព្យួរទោសសាកល្បង តុលាការត្រូវកំណត់រយៈសាកល្បងដែលមិនអាចតិចជាង ១ឆ្នាំ និងមិនលើសពី ៣ឆ្នាំទេ។ចំណុចនេះធ្វើឱ្យការព្យួរទោសសាកល្បងមានរយៈពេលខ្លីជាង ការព្យួរទោស

[15] យោងតាមមាត្រា ១២១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ធម្មតាដែលមានរយៈពេលរហូតដល់៥ឆ្នាំ។ នៅគ្រប់ពេលវេលាតុលាការអាចកែប្រែកាតព្វកិច្ចដោយឡែកដែលតម្រូវលើទណ្ឌិត បន្ទាប់ពីបានទទួលបណ្ដឹងនៅក្នុងលក្ខខណ្ឌដែលបានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ពោលគឺតាមពាក្យបណ្ដឹងរបស់អយ្យការ ឬភាគីពាក់ព័ន្ធ និងជាយថាហេតុមេធាវីរបស់ភាគីនេះ។

ដូចគ្នានេះផងដែរ ការព្យួរទោសសាកល្បងអាចត្រូវបានដកហូតដោយតុលាការ នៅក្នុងករណីដូចខាងក្រោមនេះ៖

អនុលោមតាមមាត្រា ១២២ នៃក្រមព្រហ្មទណ្ឌ

-ប្រសិនបើក្នុងរយៈពេលសាកល្បង ទណ្ឌិតមិនគោរពតាមវិធានការត្រួតពិនិត្យ ឬ កាតព្វកិច្ចដោយឡែកទេ។

-ប្រសិនបើរយៈពេលសាកល្បង ទណ្ឌិតត្រូវបានផ្ដន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាថ្មីទៀត។

តុលាការអាចបង្គាប់ឱ្យដកហូតការព្យួរទោសសាកល្បងនេះទាំងមូល ឬមួយផ្នែក។ ក្នុងករណីនេះតុលាការ ត្រូវបានទទួលបណ្ដឹងនៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ពោលតុលាការពុំមានកាព្វកិច្ចត្រូវតែដកហូតការព្យួរទោសសាកល្បងនេះទេ បើទោះបីជាលក្ខខណ្ឌដូចបានបញ្ជាក់ពីខាងដើមត្រូវបានបំពេញក៏ដោយ គឺទណ្ឌិតត្រូវសន្មតថាទទួលបាននៅអត្ថប្រយោជន៍ពីការព្យួរទោសសាកល្បងនេះ ដរាបណាពុំមានពាក្យប្ដឹងឱ្យដកហូតនោះ។បន្ថែមពីនេះទៀត ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្ដីពីការអនុវត្តរបបនៃការព្យួរទោសសាកល្បង មិនទាន់អនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឱ្យការអនុវត្តនៃការព្យួរទោសសាកល្បង មិនទាន់បានល្អប្រសើរ។

ដើម្បីអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឱ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌បានចេញគោលការណ៍ណែនាំដល់ចៅក្រម និងព្រះរាជអាជ្ញាដូចតទៅ៖

ក-ចៅក្រមជំនុំជម្រះ

១-យោងតាមមាត្រា ១១៧ នៃក្រមព្រហ្មទណ្ឌ ចៅក្រមគប្បីត្រូវពិចារណាសម្រេចព្យួរសាកល្បងនៃទោស ឱ្យបានជាអតិបរមានូវទោស ដែលបានសម្រេចដាក់ពន្ធនាគារក្នុងបទល្មើសមជ្ឈិម។

២-តុលាការត្រូវចេញសម្រង់សាលក្រមស្ថាពរចំនួនបីច្បាប់។ ចំនួនពីរច្បាប់ប្រគល់ជូនព្រះរាជអាជ្ញា និងមួយច្បាប់ទៀតប្រគល់ឱ្យទៅទណ្ឌិតដើម្បីអនុវត្ត។

ខ-ព្រះរាជអាជ្ញា

១-ត្រូវដឹកនាំសម្របសម្រួលការអនុវត្ត សេចក្ដីសម្រេចព្យួរទោសសាកល្បងរបស់តុលាការគ្រប់ជាន់ថ្នាក់ឱ្យមានប្រសិទ្ធភាព។

២-ត្រូវចាត់តាំងបុគ្គលនៅក្នុងមូលដ្ឋានដែលទណ្ឌិតរស់នៅ ឬ បំពេញកាតព្វកិច្ច ឱ្យតាមដានសកម្មភាពរបស់ទណ្ឌិត។ បុគ្គលដែលគប្បីចាត់តាំង ដូចជានគរបាលប៉ុស្តិ៍រដ្ឋបាលសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ត្រីទទួលបន្ទុកអប់រំ និងស្តារនីតិសម្បទា.....។

៣-ត្រូវបង្គាប់ណែនាំដល់ទណ្ឌិត ឱ្យទៅបង្ហាញខ្លួននៅចំពោះមុខបុគ្គលដែលត្រូវបានចាត់តាំងឱ្យតាមដាន។

៤-ត្រូវប្រគល់សម្រង់សាលក្រម ឬ សម្រង់សាលដីកាស្ដាពរដល់បុគ្គលដែលត្រូវបានចាត់តាំងឱ្យតាមដានទណ្ឌិត និង ធ្វើការដឹកនាំសម្របសម្រួលការអនុវត្ត។

៥-ក្នុងករណីចាំបាច់ ត្រូវបង្គាប់ទៅអង្គភាពនគរបាលយុត្តិធម៌ ឱ្យចាត់វិធានការជួយតាមដានរាល់សកម្មភាពរបស់ទណ្ឌិត និងធ្វើរបាយការណ៍តាមការកំណត់ ពីការកត់សម្គាល់ឃើញរបស់ខ្លួនចំពោះសកម្មភាពរបស់ទណ្ឌិតជូនព្រះរាជអាជ្ញា ដើម្បីស្នើសុំយោបល់ ឬចាត់វិធានការ។[16]

## ១.២.ការបែងចែកទោសជាប្រភាគ

ការបែងចែកទោសជាប្រភាគគឺ មានលក្ខណៈស្រដៀងគ្នាទៅនឹង របបពាក់កណ្ដាលសេរីភាពដែលអនុញ្ញាតឱ្យមានការដោះលែងទណ្ឌិតឱ្យចេញពីពន្ធនាគារ នៅមុនពេលដែលទណ្ឌិតត្រូវទទួលរងនូវការអនុវត្តទោសដាក់ពន្ធនាគារចប់សព្វគ្រប់។ក៏ប៉ុន្តែការបែងចែកទោសជាប្រភាគ គឺជាការអនុវត្តវិធានការឯកត្តកម្មមួយប្រភេទឬ មួយប្រភេទដែលអនុញ្ញាតឱ្យមានការអនុវត្តទោសជាដំណាក់កាលៗដាច់ៗពីគ្នាដោយហេតុថាការបែងចែកទោសជាប្រភាគនេះអាចអនុវត្តបានចំពោះទោសដាក់ពន្ធនាគាររហូតដល់ទៅ ១ឆ្នាំ គឺមិនមែនត្រឹមតែ ៦ខែ ដូចរបបពាក់កណ្ដាលសេរីភាពទេ។ ការបែងចែកទោសជាប្រភាគនេះ គឺសំដៅទៅលើការសម្រេចរបស់តុលាការដែលបានអនុញ្ញាតឱ្យមានការអនុវត្តទោសជាដំណាក់កាលដាច់ៗពីគ្នា។ បន្ថែមពីនេះ ប្រភាគនៃទោសនីមួយៗក៏មិនត្រូវមានរយៈពេលតិចជាង ១ខែ ហើយចំពោះរយៈពេលអនុវត្តទោសសរុបក៏មិនអាចលើសពី ២ឆ្នាំ បានឡើយដោយត្រូវរាប់បញ្ចូលគ្នាទាំងការផ្អាកការអនុវត្តទោសផង។

យោងតាមមាត្រា១៣២នៃក្រមព្រហ្មទណ្ឌ អំពីលក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគដែលនាំឱ្យតុលាការអាចសម្រេចប្រកាន់នូវការប្រកាសបំណែងចែកទោសជាប្រភាគបានគឺៈ

-តុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង១ឆ្នាំ។

-មូលហេតុធ្ងន់ធ្ងរ ដែលមានលក្ខណៈជាគ្រួសារ ជាវេជ្ជសាស្ត្រ ជាវិជ្ជាជីវៈ ឬជាសង្គម។[17]

---

[16] សារាចរស្តីពី ការអនុវត្តបទប្បញ្ញត្តិ នៃការព្យួរទោសសាកល្បងនៃក្រសួងយុត្តិធម៌ ឆ្នាំ២០១៤។

[17] សៀវភៅសិក្សានីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ២០២២ ដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ទំព័រ ៥១៣

ឧទាហរណ៍៖ ជនជាប់ចោទម្នាក់ត្រូវបានតុលាការប្រកាសទោសផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ៨ខែ ពីបទគំរាមកំហែង តាមមាត្រា២៣១ នៃក្រមព្រហ្មទណ្ឌ។ដោយពិនិត្យឃើញថាជនចាប់ចោទមានជំងឺត្រូវទទួលការពិនិត្យជាចាំបាច់ពីតុលាការ និងត្រូវសម្រាកនៅមន្ទីរពេទ្យដើម្បីទទួលការព្យាបាលពីគ្រូពេទ្យ។ដូច្នេះក្នុងករណីនេះតុលាការមានឆន្ទានុសិទ្ធិក្នុងការសម្រេចឱ្យជនជាប់ចោទអនុវត្តទោសក្នុងពន្ធនាគារចំនួន៨ខែ ក៏ប៉ុន្តែទោសត្រូវតែអនុវត្តជាប្រភាគ ក្នុងរយៈពេលមួយខែពេញ និងអនុញ្ញាតឱ្យនៅក្រៅពន្ធនាគាររយៈពេលមួយខែ គឺការអនុវត្តទោសនេះ ដរាបណាជនជាប់ចោទអនុវត្តទោសចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្តរយៈពេល៨ខែ បានចប់សព្វគ្រប់ជាស្ថាពរតាមសេចក្តីសម្រេចរបស់តុលាការ។សរុបមកដោយពិនិត្យឃើញថាទណ្ឌិតត្រូវតែអនុវត្តទោសនៅក្នុងពន្ធនាគារចំនួន១ខែ ហើយស្ថិតនៅក្រៅពន្ធនាគារចំនួន១ខែ ដូច្នេះទណ្ឌិតត្រូវប្រើរយៈពេលរហូតដល់ ១៦ខែ ទើបបានអនុវត្តទោសចប់សព្វគ្រប់អស់។ជាក់ស្តែងពិនិត្យឃើញថាការបែងចែកទោសជាប្រភាគ ទណ្ឌិតត្រូវប្រើរយៈពេល៨ខែនៅក្នុងពន្ធនាគារ និង រយៈពេល៨ខែ នៅក្រៅពន្ធនាគារ។

ការបែងចែកទោសជាប្រភាគ នាំឱ្យទណ្ឌិតទទួលរងទោសដោយមានចន្លោះពេលជាច្រើនដោយមានការដោះលែងឱ្យមានសេរីភាព ពោលគឺអានុភាពនាំឱ្យមានការផ្អាកជាបណ្តោះអាសន្ននូវការអនុវត្តទោសជាប់ពន្ធនាគារនៅតាមចន្លោះពេលនៃប្រភាគនីមួយៗ។ចំពោះប្រភាគនៃទោសនីមួយៗមិនត្រូវតិចជាង ១ខែ ហើយចិរវេលាសរុបនៃការអនុវត្តទោសមិនអាចលើសពី ២ឆ្នាំ ទេដោយរាប់បញ្ចូលទាំងការផ្អាកការអនុវត្តទោស។បន្ថែមពីនេះទៀត គឺនៅគ្រប់ពេលវេលាទាំងអស់ តុលាការក៏អាចរៀបចំបែបបទនៃការបែងចែកទោសជាប្រភាគ ឬលុបចោលរបបនៃការបែងចែកទោសជាប្រភាគ តាមបណ្តឹងរបស់ព្រះរាជអាជ្ញា។[18] ជាចុងក្រោយ ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនវិលត្រឡប់មកពន្ធនាគារវិញ នៅពេលផុតកំណត់រយៈពេលនៃការផ្អាកការអនុវត្តទោស។[19]

## ១.៣.របបពាក់កណ្តាលសេរីភាព

របបពាក់កណ្តាលសេរីភាព គឺជាវិធានការឯកត្តកម្មនៃទោសមួយដែលអនុញ្ញាតឱ្យទណ្ឌិតរក្សាបាននៅកិច្ចការវិជ្ជាជីវៈរបស់ខ្លួនទំនាក់ទំនងគ្រួសារឬ ទទួលការបង្ហាត់បង្រៀន ឬ ការពិនិត្យព្យាបាលជម្ងឺនៅក្រៅពន្ធនាគារ។

យោងតាមមាត្រា ១២៧ នៃក្រមព្រហ្មទណ្ឌ លក្ខខណ្ឌនៃរបបពាក់កណ្តាលសេរីភាពមានដូចជា៖

-តុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង៦ខែ តុលាការអាចសម្រេចថា ទោសត្រូវអនុវត្តរបបពាក់កណ្តាលសេរីភាព។

[18] យោងតាមមាត្រា ១៣៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[19] យោងតាមមាត្រា ១៣៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

- ដើម្បីអនុញ្ញាតឱ្យទណ្ឌិតអាចបំពេញសកម្មភាពវិជ្ជាជីវៈ ទទួលការសិក្សា ឬការបណ្តុះបណ្តាល ឬការពិនិត្យជម្ងឺ ឬជួយឧបត្ថមសេចក្តីត្រូវការរបស់គ្រួសារ។

ក្នុងករណីនេះដែរ ទណ្ឌិតដែលស្ថិតនៅក្រោមរបបពាក់កណ្តាលសេរីភាពត្រូវបានអនុញ្ញាតឱ្យចាកចេញពីពន្ធនាគារក្នុងរយៈពេលជាកំណត់ ហើយតុលាការមានឆន្ទានុសិទ្ធិក្នុងការកំណត់ថ្ងៃ និងម៉ោងដែលទណ្ឌិតត្រូវបានអនុញ្ញាតឱ្យមានវត្តមានក្នុងពន្ធនាគារដោយសេចក្តីសម្រេចរបស់តុលាការ។

ឧទាហរណ៍៖ តុលាការបានសម្រេចក្នុងប្រកាសរបបពាក់កណ្តាលសេរីភាពសម្រាប់ទណ្ឌិតម្នាក់ ដោយពិនិត្យឃើញថាទណ្ឌិតមានប្រពន្ធនិង កូនច្រើនក្នុងបន្ទុកគ្រួសារធ្វើឱ្យសេដ្ឋកិច្ចគ្រួសារក្រីក្រពីមួយថ្ងៃទៅមួយថ្ងៃ ទើបតុលាការអនុញ្ញាតឱ្យទណ្ឌិតចេញក្រៅពីពន្ធនាគារ ចាប់ពីថ្ងៃចន្ទ ដល់ ថ្ងៃសៅរ៍ គឺចាប់ពីម៉ោង៧ព្រឹក រហូតដល់៧ ល្ងាច ក្រៅពីសល់រយៈពេលគឺទណ្ឌិតត្រូវតែអនុវត្តទោសនៅក្នុងពន្ធនាគារឱ្យបានទៀងទាត់។

តាមឧទាហរណ៍ខាងលើពិនិត្យឃើញថា ការកំណត់បែបបទនៃម៉ោង ថ្ងៃ និងម៉ោង ដែលទណ្ឌិតត្រូវអនុវត្តទោសក្នុងពន្ធនាគារ និងថ្ងៃ និងម៉ោងដែលទណ្ឌិតនៅក្រៅពន្ធនាគារគឺត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់។ បន្ថែមពីនេះទៀត រយៈពេលនៃពាក់កណ្តាលសេរីភាព ត្រូវគិតបញ្ចូលក្នុងចិរវេលានៃទោសកំពុងអនុវត្ត ពោលរយៈពេលដែលទណ្ឌិតនៅក្រៅពន្ធនាគារក៏ត្រូវរាប់បញ្ចូលទៅក្នុងចិរវេលានៃទោសដែលកំពុងអនុវត្ត។

ជាការពិតណាស់ ការបែងចែកទោសជាប្រភាគ ការសម្រេចអនុញ្ញាតឱ្យទណ្ឌិតបានស្ថិតនៅក្រៅពន្ធនាគារ នៅក្នុងរបបពាក់កណ្តាលសេរីភាព គឺពុំមែនជាមូលហេតុនៃការផ្អាកការអនុវត្តទោសនោះទេ មានន័យថា រយៈពេលដែលទណ្ឌិតមានសេរីភាពនៅខាងក្រៅពន្ធានាគារត្រូវតែគិតបញ្ចូលទៅក្នុងចិរវេលាជាសរុបនៃការអនុវត្តទោសនេះ។ ឆ្លើយតបចំពោះករណីរបបពាក់កណ្តាលសេរីភាព ទណ្ឌិតដែលពុំបានអនុវត្តត្រឹមត្រូវតាមកាតព្វកិច្ចទាំងឡាយដែលត្រូវបានតុលាការសម្រេចនោះទេ តុលាការអាចរៀបចំរយៈពេលរបបពាក់កណ្តាលសេរីភាព ឬក៏លុបចោលនូវរបបពាក់កណ្តាលសេរីភាព តាមបណ្តឹងរបស់ព្រះរាជអាជ្ញានៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ [20] ចុងក្រោយព្រះរាជអាជ្ញាមានអំណាចឆន្ទានុសិទ្ធដាច់ដោយឡែកក្នុងការបង្គាប់ឱ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនវិលត្រឡប់មកពន្ធនាគារវិញ នៅពេលផុតកំណត់រយៈពេលនៃពាក់កណ្តាលសេរីភាព។[21]

[20] យោងតាមមាត្រា ១៣០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[21] យោងតាមមាត្រា ១៣១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

# ជំពូកទី២

# ការកំណត់ទោសដោយ ចៅក្រម ក្នុង ករណីបទល្មើសត្រួតគ្នា

# ជំពូកទី២

# ការកំណត់ទោសដោយ ចៅក្រម ក្នុងករណីបទល្មើសត្រួតគ្នា

ក្នុងការប្រព្រឹត្តបទល្មើសរបស់ចារីគឺ អាចមានករណីបទល្មើសជាច្រើនបែបច្រើនទម្រង់ក្នុងសង្គមនីមួយសព្វថ្ងៃ។ក៏ប៉ុន្តែពេលខ្លះ ចារីបានប្រព្រឹត្តបទល្មើសជាច្រើនក្នុងពេលតែមួយ ឬគម្លាតពេលខុសៗគ្នាបន្ទាប់មកចារីបានទៅប្រព្រឹត្តបទល្មើសថ្មីមួយទៀត គឺនៅមុនពេលតុលាការមិនទាន់បានផ្តន្ទាទោសជាស្ថាពរពីបទល្មើសមុន។ ក្នុងករណីដែលបានបរិយាយនេះ នៅក្នុងក្រមព្រហ្មទណ្ឌបានចែងពីស្ថានភាពបែបនេះគឺជាបទល្មើសត្រួតគ្នាដូចនេះ តុលាការត្រូវតែយកវិធាននៃបទល្មើសត្រួតគ្នាមកអនុវត្ត។ក៏ប៉ុន្តែផ្ទុយទៅវិញប្រសិនបើជនជាប់ចោទត្រូវបានតុលាការផ្តន្ទាទោសជាស្ថាពរបទល្មើសដែលជនជាប់ចោទបានប្រព្រឹត្តរួចហើយក្រោយអនុវត្តទោសចប់បានដោះលែងឱ្យមានសេរី។បន្ទាប់មកជនដែលបានដោះលែងមានសេរីភាពហើយក៏បានទៅប្រព្រឹត្តបទល្មើជាថ្មីមួយទៀតក្នុងអំឡុងពេលដែលច្បាប់បានកំណត់នោះករណីបែបនេះមិនមែនជាបទល្មើសត្រួតគ្នាទេគឺជា ការមិនរាងចាលដែលបានលើកយកមកបរិយាយនៅក្នុងជំពូកនេះ។

នៅក្នុងករណីនៃការកំណត់ទោសទៅលើជនជាប់ចោទតុលាការត្រូវពិចារណា តាមវិធានទូទៅក្នុងករណីបទល្មើសត្រួតគ្នាគឺ យល់ច្បាស់ពីសញ្ញាណនៃបទល្មើសត្រួតគ្នា (**២.១**) ក្នុងករណីការចោទប្រកាន់តែមួយ (**២.២**) និងករណីដែលមានការចោទប្រកាន់ដាច់ពីគ្នា (**២.៣**) ចំពោះករណីពិសេសផ្សេងទៀតច្បាប់ព្រហ្មទណ្ឌបានកំណត់ឱ្យធ្វើការអនុវត្តការបូកទោសបញ្ចូលគ្នា (**២.៤**) ទៅតាមករណីនៃបទល្មើសនិងយោងតាមបទប្បញ្ញត្តិដែលច្បាប់ព្រហ្មទណ្ឌបានចែងចំពោះករណីនៃការប្រព្រឹត្តបទល្មើសនេះដែរ។

## ២.១.ការកំណត់អំពីស្ថានភាពនៃបទល្មើសត្រួតគ្នា

កាលៈទេសៈជាច្រើនដែលបង្ហាញអំពីពហុភាពនៃបទល្មើសអាចកើតឡើងនៅគ្រប់ពេល ដូចជាការមិនរាងចាល និងបទល្មើសត្រួតគ្នា។ក្នុងកាលៈទេសៈខ្លះជាស្ថានទម្ងន់ទោស ក៏អាចមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងបទល្មើសត្រួតគ្នា។ដូច្នេះបទល្មើសត្រួតនឹងពិនិត្យទៅលើសញ្ញាណនៃបទល្មើសត្រួតគ្នា (**២.១.១**) និងសញ្ញាណទ្រឹស្តីទាក់ទងនឹងទោសក្នុងករណីបទល្មើសត្រួតគ្នា(**២.១.២**)។

### ២.១.១.សញ្ញាណនៃបទល្មើសត្រួតគ្នា

យោងតាមមាត្រា១៣៦ នៃក្រមព្រហ្មទណ្ឌ បទល្មើសត្រួតគ្នាកើតឡើង កាលបើបទល្មើសមួយត្រូវបានប្រព្រឹត្តដោយបុគ្គលម្នាក់ មុនពេលដែលបុគ្គលនេះត្រូវបានផ្តន្ទាទោសជាស្ថាពរចំពោះបទល្មើសមួយផ្សេងទៀត។ យោងតាមបទប្បញ្ញត្តិនៃមាត្រានេះ បទល្មើសត្រួតគ្នា សំដៅដល់ស្ថានភាពដែលបទល្មើសច្រើនត្រូវបានប្រព្រឹត្តដោយបុគ្គលម្នាក់ ឬដោយរួមគ្នាជាមួយបុគ្គលផ្សេងទៀតហើយដែលពេលវេលានៃការប្រព្រឹត្តបទល្មើសទាំងនេះ

មិនអាចបែងចែកគ្នាដោយសេចក្តីសម្រេចផ្តន្ទាទោសជាស្ថាពររបស់តុលាការឡើយ។ស្ថានភាពនៃបទល្មើសត្រួតគ្នា គឺខុសពីស្ថានភាពនៃ ការមិនរាងចាល ។

ស្ថានភាពនៃបទល្មើសត្រួតគ្នា គឺកើតមាននៅពេលដែលអង្គហេតុនៃបទល្មើសតែមួយប៉ុន្តែអាចត្រូវបានផ្តន្ទាទោសដោយយោងតាមបទប្បញ្ញត្តិព្រហ្មទណ្ឌទៅតាមបទល្មើសដែលចែងដោយច្បាប់។ចំណែកករណី ការមិនរាងចាល សំដៅដល់ស្ថានភាពដែលបុគ្គលម្នាក់បន្ទាប់ពីត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទល្មើសណាមួយដែលច្បាប់បានចែង បន្ទាប់មកបុគ្គលដដែលបានទៅប្រព្រឹត្តបទល្មើសថ្មីមួយទៀត។

ឧទាហរណ៍៖ លោក សុខ បានលួចទ្រព្យសម្បត្តិរបស់អ្នកដទៃនៅថ្ងៃទី ១ ខែមករា ឆ្នាំ២០២២។បន្ទាប់មកនៅថ្ងៃទី ២ ខែមករា ឆ្នាំ២០២២ លោក សុខ បានកំហែងយកទ្រព្យសម្បត្តិមិត្តភក្តិរបស់គាត់ទៀត។ដូច្នេះ លោក សុខ បានប្រព្រឹត្តបទល្មើសចំនួន ២ ដែលជាបទល្មើសត្រួតគ្នា។ក៏ប៉ុន្តែក្នុងករណីខាងលើប្រសិនបើបទល្មើសលួច ត្រូវបានតុលាការផ្តន្ទាទោសដោយសេចក្តីសម្រេចជាស្ថាពរវិញនោះ ក្រោយមកជនល្មើសខាងលើបានប្រព្រឹត្តបទកំហែងនោះ ក្នុងរយៈពេលដែលច្បាប់បានកំណត់ក្រោយពេលផ្តន្ទាទោសដោយសេចក្តីសម្រេចស្ថាពរដោយតុលាការវិញ ករណីនេះគឺជាស្ថានភាពនៃការមិនរាងចាល។[22]

សូមកត់សម្គាល់ថា ក្នុងករណីខ្លះទៀត ច្បាប់ព្រហ្មទណ្ឌបានកំណត់រួចជាស្រេចអំពីទោសជាក់លាក់ដែលត្រូវផ្តន្ទាទោស ក្នុងករណីដែលមានការត្រួតគ្នានៃបទល្មើសជាក់លាក់ណាមួយដែលគេហៅថា ការបូកទោសតាមច្បាប់កំណត់ ដោយមិនយកវិធាននៃបទល្មើសត្រួតគ្នាមកអនុវត្តឡើយ ពោលគឺនៅក្នុងករណីបែបនេះ អ្នកនីតិបទប្បញ្ញត្តិកំណត់យកស្ថានភាពពហុបទល្មើស មកធ្វើជាស្ថានទម្ងន់ទោសនៃបទល្មើសទៅវិញ។[23]

ឧទាហរណ៍៖ បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ១០ឆ្នាំតាមមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ។បើបទល្មើសនេះបានប្រព្រឹត្តឡើង មុនពេល ក្នុងពេល ឬក្រោយពេលប្រព្រឹត្តអំពើទារុណកម្ម ឬអំពើឃោរឃៅ បទរំលោភសេពសន្ថវៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ ៣០ឆ្នាំ ដោយស្របតាមមាត្រា ២៤៣នៃក្រមព្រហ្មទណ្ឌ។ ចំពោះករណីខាងក្រោយនេះ គឺបទល្មើសមានចំនួនពីរបានកើតឡើងគឺ បទរំលោភសេពសន្ថវៈ និងបទទារុណកម្ម ឬ អំពើឃោរឃៅ។ដូចនេះគឺត្រូវយកមាត្រា ២៤៣ នៃក្រមព្រហ្មទណ្ឌមកអនុវត្ត គឺមិនប្រើប្រាស់វិធានស្តីពីបទល្មើសត្រួតគ្នាទេ។

ឧទាហរណ៍៖ បទឃាតកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ តាមមាត្រា ១៩៩នៃក្រមព្រហ្មទណ្ឌ។ក៏ប៉ុន្តែប្រសិនបើបទល្មើសនេះបានកើតឡើង ក្នុងពេល ឬ ក្រោយពេលប្រព្រឹត្តអំពើទារុណកម្ម អំពើ

[22] យោងតាមមាត្រា ៨៣ ដល់ មាត្រា ៩២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[23] សៀវភៅសិក្សានីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ២០២២ ដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ទំព័រ ៤៧២ និង៤៧៣

ឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ បទឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត អនុលោមតាមមាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌ។ ចំពោះករណីខាងក្រោយនេះគឺ មានបទល្មើសចំនួនពីរបានកើតឡើងគឺ បទឃាតកម្ម និងបទទារុណកម្ម ឬអំពើឃោរឃៅ និងបទឃាតកម្ម និងបទរំលោភសេពសន្ថវៈ។ក្នុងករណីនេះ មិនត្រូវយកវិធាននៃបទល្មើសត្រួតគ្នាមកអនុវត្តទេ គឺត្រូវអនុវត្តតាមមាត្រា២០៥នៃក្រមព្រហ្មទណ្ឌ។

### ២.១.២.សញ្ញាណទ្រឹស្តីទាក់ទងនឹងទោសក្នុងករណីបទល្មើសត្រួតគ្នា

ក្នុងករណីដែលមានស្ថានភាពនៃ បទល្មើសត្រួតគ្នា ដែលគេនិយមយកទៅប្រើប្រាស់វិធាននៃទោសគេពិនិត្យឃើញមានទ្រឹស្តីធំៗចំនួនពីរសម្រាប់អនុវត្តក្នុងករណីនេះ។

ទ្រឹស្តីទី១៖ គឺទ្រឹស្តីនៃការបូកទោស។យោងតាមទ្រឹស្តីនេះទោសសម្រាប់បទល្មើសនីមួយៗត្រូវប្រកាសទាំងអស់ដោយតុលាការ ហើយចំពោះទោសដែលមានប្រភេទដូចគ្នាតុលាការត្រូវបូកបញ្ចូលគ្នាទាំងអស់។ ទ្រឹស្តីនេះ មានលក្ខណៈទាក់ទាញច្រើនសម្រាប់រូបភាពខាងក្រៅនៃការយល់ឃើញអំពីយុត្តិធម៌ នៃការសម្រេចរបស់តុលាការ ក៏ប៉ុន្តែទ្រឹស្តីនេះ មិនមានភាពជាក់ស្តែងនិយមឡើយ សម្រាប់ការអនុវត្តទោសឱ្យបានពេញលេញតាមការសម្រេចរបស់តុលាការនោះឡើយ ក៏ព្រោះតែប្រសិនបើក្នុងករណីដែលជនល្មើសបានប្រព្រឹត្តបទល្មើសដូចជាបទឧក្រិដ្ឋជាច្រើនដែលជាបទល្មើសធ្ងន់ធ្ងរ ដែលអាចជាប់ពន្ធនាគារជាច្រើនឆ្នាំ ក៏ប៉ុន្តែជនល្មើសមិនអាចមានអាយុគ្រប់គ្រាន់ក្នុងការអនុវត្តទោសក្នុងពន្ធនាគារឱ្យបានពេញលេញតាមសេចក្តីសម្រេចរបស់តុលាការបានឡើយ។

ទ្រឹស្តីទី២៖ គឺជាទ្រឹស្តីនៃការស្រូបទោស។យោងតាមទ្រឹស្តីនេះ ទោសដែលប្រកាសសម្រាប់បទល្មើសស្រាល ត្រូវស្រូបបញ្ចូលទៅក្នុងទោសដែលប្រកាសសម្រាប់បទល្មើសធ្ងន់ធ្ងរ។ទ្រឹស្តីនេះត្រូវបានបង្កើតឡើងដោយឈរលើមូលដ្ឋាននៃចរិតគ្រោះថ្នាក់របស់បុគ្គលដែលបានប្រព្រឹត្តបទល្មើស។ក្នុងន័យនេះ គេសង្កេតឃើញថា អប្រសិទ្ធភាពនៃការអនុវត្តច្បាប់គឺនាំទៅដល់ស្ថានភាពនៃអវត្តមាននៃការព្រមានដល់ជនល្មើសក្រោមរូបភាពជាការផ្តន្ទាទោសសម្រាប់ បទល្មើសលើកទី១ ដែលជាហេតុធ្វើឱ្យមានការបន្ថយការទទួលខុសត្រូវផ្នែកអត្តនោម័តសម្រាប់បទល្មើសបន្តបន្ទាប់ទៀត។

នៅចន្លោះទ្រឹស្តីធំៗទាំងពីរនេះ គេក៏សង្កេតឃើញមានទ្រឹស្តីមួយទៀតគឺ ទ្រឹស្តីបូកទោសគតិយុត្ត ដែលជាទ្រឹស្តី ត្រូវបានគេយកទៅប្រើប្រាស់ជាបច្ចេកទេសក្នុងការតាក់តែងច្បាប់សម្រាប់អនុវត្តក្នុងករណីនៃស្ថានភាពបទល្មើសត្រួតគ្នាក្នុងច្បាប់។ទ្រឹស្តីនេះត្រូវបានរៀបចំឡើងដោយឈរ លើទស្សនៈមួយដែលចាត់ទុកបទល្មើសដែលមានចរិតគ្រោះថ្នាក់ស្រាលជាស្ថានទម្ងន់ទោសនៃបទល្មើសដែលមានចរិតគ្រោះថ្នាក់ធ្ងន់ធ្ងរជាង។[24]

[24] មេរៀនក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បកស្រាយដោយ ឯកឧត្តមសាស្ត្រាចារ្យ ហ៊ី សោភា ,ឯកឧត្តម ប៊ុន ហុន, ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌ ,ឯកឧត្តម ផូវ សំភី និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១១

## ២.២.ការចោទប្រកាន់តែមួយ

យោងតាមមាត្រា១៣៧ កថាខណ្ឌទី១នៃក្រមព្រហ្មទណ្ឌ កាលបើនៅក្នុងការចោទប្រកាន់តែមួយ ជនជាប់ចោទត្រូវបានគេរកឃើញថាមានពិរុទ្ធពីបទល្មើសច្រើន ទោសនីមួយៗអាចត្រូវប្រកាសឡើង។ ប៉ុន្តែកាលបើទោសត្រូវទទួលមានច្រើនហើយមានប្រភេទដូចគ្នា តុលាការត្រូវប្រកាសទោសតែមួយនៃប្រភេទនេះក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ។

ឯកសារជំនួយស្មារតីសម្រាប់ការស្វែងយល់ក្រមព្រហ្មទណ្ឌ[25] ការចោទប្រកាន់តែមួយនេះ សំដៅដល់ស្ថានភាពនៃនីតិវិធីដែលក្នុងនោះបទល្មើសត្រួតគ្នាទាំងអស់ ត្រូវបានធ្វើការចោទប្រកាន់នៅក្នុងលិខិតចោទប្រកាន់តែមួយដូចជា ការចោទប្រកាន់បទល្មើសត្រួតគ្នានៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែមួយ កំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាមតែមួយ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះតែមួយ និង ដីកាបញ្ជូនរឿងទៅជំនុំជម្រះតែមួយ ។ជាមួយគ្នានេះផងដែរ ត្រូវបានចាត់ទុកថាជាការចោទប្រកាន់តែមួយផងគឺៈ

-នៅក្នុងដំណាក់កាលស៊ើបសួរ ចៅក្រមស៊ើបសួរ បានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីអយ្យការសម្រាប់អង្គហេតុនៃបទល្មើសថ្មីផ្សេង។[26] ចៅក្រមស៊ើបសួរបានរកឃើញថា មានការពាក់ព័ន្ធនឹងជនត្រូវចោទ ហើយចៅក្រមស៊ើបសួរបានសម្រេចបិទការស៊ើបសួរតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះសម្រាប់អង្គហេតុដែលបង្កើតបានជាបទល្មើសត្រួតគ្នាទាំងនោះ។ នៅក្នុងករណីដែលសភាស៊ើបសួរពន្លាតការស៊ើបសួររបស់ខ្លួនទៅដល់បទល្មើសពាក់ព័ន្ធផ្សេងទៀត។[27] ហើយបិទបញ្ចប់ការស៊ើបសួររបស់ខ្លួន តាមសាលដីកាបញ្ជូនទៅជំនុំជម្រះ សម្រាប់អង្គហេតុដែលបង្កើតបានជាស្ថានភាពនៃបទល្មើសត្រួតគ្នាទាំងនោះ។

-នៅក្នុងករណីខ្លះតុលាការបានសម្រេចបញ្ចូលសំណុំរឿងព្រហ្មទណ្ឌ ច្រើនជាមួយគ្នាក៏ព្រោះតែនៅក្នុងសំណុំរឿងនេះមានអង្គហេតុដែលអាចបង្កើតបានជាស្ថានភាពនៃបទល្មើសត្រួតគ្នា។[28] នៅក្នុងករណី ដែលមានការចោទប្រកាន់តែមួយសម្រាប់បទល្មើសត្រួតគ្នាដូចបានរៀបរាប់ខាងលើនេះ តុលាការត្រូវអនុវត្តវិធាននៃការស្រូបទោស ដោយស្វ័យប្រវត្តិស្របតាមបទប្បញ្ញត្តិនៃមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌ បើទោះបីជាពុំមានបណ្តឹងសុំពីអយ្យការ ឬភាគីពាក់ព័ន្ធក៏ដោយ។

---

[25] ការបកស្រាយក្នុងឯកសារនេះ គឺជាការបកស្រាយក្រៅផ្លូវការ និងមានលក្ខណៈជាទ្រឹស្តីសម្រាប់ជាជំនួយស្មារតីឱ្យដល់អ្នកដែលមានបំណងចង់សិក្សាស្វែងយល់បន្ថែមអំពីបទប្បញ្ញត្តិមួយចំនួនក្នុងក្រមព្រហ្មទណ្ឌប៉ុណ្ណោះ។ឯកសារជំនួយស្មារតីសម្រាប់ការស្វែងយល់ក្រមព្រហ្មទណ្ឌ រៀបចំដោយ ឯកឧត្តម ហ៊ី សោភា និងឯកឧត្តម កើត រិទ្ធ។

[26] យោងមាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[27] យោងមាត្រា ២៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[28] យោងមាត្រា ២៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

និយាយឱ្យខ្លីការចោទប្រកាន់តែមួយនៅត្រង់បទប្បញ្ញត្តិនេះគឺ ទៅលើស្ថានភាពដែលបទល្មើសត្រួតគ្នាត្រូវបានធ្វើការចោទប្រកាន់ក្នុងសំណុំរឿងតែមួយ។

យោងតាមបញ្ញត្តិនៃមាត្រា១៣៧ នៃក្រមព្រហ្មទណ្ឌបានចែងកំណត់បានកំណត់ចេញនូវគោលការណ៍ចំនួនពីរសំខាន់ៗ ក្នុងករណីដែលមានបទល្មើសត្រួតគ្នា រួមមាន ការប្រកាសទោសត្រួតគ្នា ក្នុងករណីទោសដែលមានប្រភេទខុសគ្នា(**២.២.១**) និងការប្រកាសការស្រូបទោស(**២.២.២**)។[29]

### ២.២.១.ការប្រកាសទោសត្រួតគ្នា ក្នុងករណីដែលមានទោសប្រភេទខុសគ្នា

នៅក្នុងក្រមព្រហ្មទណ្ឌទោសមានប្រភេទខុសគ្នាច្រើនមានដូចជា មូលទោស។[30] ទោសពិន័យជាប្រាក់ និង ទោសដាក់ពន្ធនាគារ។ចំពោះទោសបន្ថែមមានដូចជា ការដកសិទ្ធិខ្លះជាពលរដ្ឋ ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះប្រព្រឹត្តនៅក្នុងពេលដែលប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្តនៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ការព្យួរលិខិតបើកបរ ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស ។ល។ បន្ថែមពីនេះទៀតក្រមព្រហ្មទណ្ឌក៏បានចែងពីទោសជំនួស[31]រួមមាន ការងារសហគមន៍ និងការស្តីបន្ទោស។[32]ទោសទាំងនេះគឺជាទោសមានការខុសប្លែកៗគ្នា ប្រសិនបើក្នុងករណីមានបទល្មើស ទោសប្រភេទទាំងនេះតុលាការអាចធ្វើការប្រកាសបាន។

យោងតាមមាត្រា១៣៧ នៃក្រមព្រហ្មទណ្ឌ កថាខណ្ឌទី១ វាក្យខ័ណ្ឌទី១ កាលបើក្នុងពេលចោទប្រកាន់តែមួយ ជនជាប់ចោទត្រូវបានគេរកឃើញថាមាន ពិរុទ្ធពីបទល្មើសច្រើន ទោសនីមួយៗអាចត្រូវបានប្រកាសឡើង។

យោងតាមបញ្ញត្តិខាងលើនេះការចោទប្រកាន់តែមួយចំពោះបទល្មើសច្រើន ប្រសិនបើទោសដែលត្រូវប្រកាសមានប្រភេទខុសគ្នា ទោសនៃប្រភេទនីមួយៗអាចត្រូវបានប្រកាសឱ្យអនុវត្តត្រួតគ្នា។ពិតណាស់ថា នៅពេលដែលមានការចោទប្រកាន់ ជនជាប់ចោទនោះត្រូវបានប្រកាសទទួលស្គាល់ថាជាពិរុទ្ធនៃបទល្មើសច្រើនត្រួតគ្នា គឺតុលាការអាចប្រកាសទោសចំពោះបទល្មើសនីមួយៗ ដែលទោសទាំងនោះអាចមានប្រភេទខុសគ្នាចំពោះបទល្មើសត្រួតគ្នា។នៅពេលជំនុំជម្រះលើបទល្មើសត្រួតគ្នា តុលាការត្រូវពិនិត្យមើលថា សម្រាប់បទល្មើស

[29] សៀវភៅសិក្សានីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ២០២២ ដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ទំព័រ ៤៧៥

[30] យោងតាមមាត្រា ៤៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[31] យោងតាមមាត្រា ៧២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[32] យោងតាមមាត្រា ៧៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

គ្រួតទាំងអស់នោះ តុលាការអាចសម្រេចប្រកាសទោសនីមួយៗ ត្រូវបានផ្តន្ទាទោសដោយទោសដែលមានប្រភេទដូចគ្នានិងទោសដែលមានប្រភេទខុសគ្នា។

ឧទាហរណ៍៖ លោកសុខ បានប្រព្រឹត្តបទល្មើសត្រួតគឺបទឃាតកម្ម តាមមាត្រា១៩៩ និងបទបរិហារកេរ្តិ៍ តាមមាត្រា៣០៥ នៃក្រមព្រហ្មទណ្ឌ។នៅពេលតុលាការទទួលជំនុំជម្រះ តុលាការពិនិត្យមើលលើបទប្បញ្ញត្តិទាំងពីរបទឃាតកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ ១៥ឆ្នាំនិងបទបរិហារកេរ្តិ៍ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១សែនរៀល ទៅ ១០លានរៀល ។ក្នុងករណីនេះ តុលាការអាចសម្រេចប្រកាសទោសនីមួយៗសម្រាប់បទល្មើសត្រួតគ្នា តុលាការប្រកាសទោសដាក់ពន្ធនាគារសម្រាប់បទឃាតកម្ម និងទោសពិន័យជាប្រាក់សម្រាប់បទបរិហារកេរ្តិ៍ក៏ព្រោះតែទោសពិន័យជាប្រាក់ និងទោសដាក់ពន្ធនាគារ គឺជាទោសដែលមានប្រភេទខុសគ្នា ដូចនេះតុលាការអាចប្រកាសទោសទាំងពីរដោយត្រួតគ្នាបាន។ដូច្នេះ តុលាការអាចសម្រេចផ្តន្ទាទោសលោក សុខ ឱ្យជាប់ពន្ធនាគារចំនួន ១៣ឆ្នាំ និង ទោសពិន័យជាប្រាក់ចំនួន ៨ លានរៀល។

### ២.២.២.ការអនុវត្តវិធានស្រូបទោស

តាមមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌបានចែងថា កាលបើនៅក្នុងពេលចោទប្រកាន់តែមួយ ហើយជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធពីបទល្មើសច្រើន ទោសនីមួយៗអាចត្រូវបានប្រកាសឡើង។ ប៉ុន្តែ កាលបើទោសត្រូវទទួលមានច្រើន ហើយមានប្រភេទដូចគ្នាតុលាការត្រូវប្រកាសទោសតែមួយនៃប្រភេទនេះ នៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ។ ទោសនីមួយៗដែលប្រកាស ត្រូវចាត់ទុកថា ជាទោសរួមចំពោះបទល្មើសដែលត្រួត នៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់អនុវត្តទៅលើបទល្មើសនីមួយៗ។[33]

យោងតាមបទប្បញ្ញត្តិខាងលើនេះ ចំពោះទោសមានប្រភេទខុសគ្នា តុលាការប្រកាសទោសនីមួយៗ ប្រសិនបើទោសដែលត្រូវបានប្រកាសមានប្រភេទដូចគ្នា នោះមានតែទោសតែមួយនៃទោសដែលមានប្រភេទដូចគ្នាទេដែលអាចត្រូវបានប្រកាស ក្នុងព្រំដែនអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ។ទោសនីមួយៗដែលបានប្រកាសត្រូវចាត់ទុកថាជាទោសរួម។ ក្នុងករណីបទល្មើសត្រួតគ្នាគឺព្រំដែននៃអតិបរមាស្របច្បាប់ត្រូវអនុវត្តទៅលើបទល្មើសនីមួយៗពោលគឺទោសជាច្រើនត្រូវបានប្រកាសដោយតុលាការ និង ត្រូវយកទៅអនុវត្តក្នុងពេលតែមួយប៉ុណ្ណោះ។ ការប្រកាសទោស និងអនុវត្តបែបនេះត្រូវបានចាត់ទុកថាជាការអនុវត្តវិធានស្រូបទោស។

ឧទាហរណ៍ទី១៖ លោក សៅ បានប្រព្រឹត្តបទល្មើសត្រួតគ្នាគឺបទល្មើសហិង្សាដោយចេតនា នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២២ និងបទរំលោភសេពសន្ថវៈ បានប្រព្រឹត្តនៅថ្ងៃទី ២ ខែមករា ឆ្នាំ២០២២។តាមមាត្រា២១៧ បទហិង្សាដោយចេតនា នៃក្រមព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២

---

[33] សៀវភៅសិក្សានីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ២០២២ ដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ទំព័រ ៤៧៦

លានរៀល ទៅ៦លានរៀល និង តាមមាត្រា២៣៩បទរំលោភសេពសន្ថវៈ នៃក្រមព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ។នៅក្នុងករណីនេះ តុលាការអាចត្រូវប្រកាសទោសតែមួយប៉ុណ្ណោះចំពោះប្រភេទនៃទោសដាក់ពន្ធនាគារ និង ប្រកាសទោសតែមួយប៉ុណ្ណោះចំពោះប្រភេទនៃទោសពិន័យជាប្រាក់ គឺនៅក្នុងព្រំដែនអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ដូច្នេះសម្រាប់បទល្មើសត្រួតគ្នាខាងលើ មានប្រភេទទោសគឺទោសប្រភេទដូចគ្នាគឺ ទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៣ឆ្នាំ និងទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ១០ឆ្នាំ និងទោសប្រភេទខុសគ្នាគឺទោសពិន័យជាប្រាក់ពី ២លានរៀល ទៅ ៦លានរៀល។

នៅក្នុងករណីការប្រកាសទោសលើជនជាប់ជោទដែលបានប្រព្រឹត្តបទល្មើសត្រួតគ្នា តុលាការត្រូវៈ

-ប្រកាសទាំងទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ក៏ព្រោះតែ ទោសទាំងពីរនេះគឺជាទោសដែលមានប្រភេទខុសគ្នា។ ដូច្នេះ តុលាការត្រូវប្រកាសផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារផង និងពិន័យជាប្រាក់ផង។

-អនុលោមតាមមាត្រា១៣៧ នៃក្រមព្រហ្មទណ្ឌ តុលាការអាចប្រកាសទោសតែមួយនៃទោសប្រភេទដូចគ្នា ក្នុងព្រំដែនអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ។ ដូចនេះតុលាការអាចប្រកាសទោសដាក់ពន្ធនាគារមិនឱ្យលើសពី ១០ឆ្នាំ(អតិបរមានៃទោសស្របច្បាប់ដែលខ្ពស់ជាងគេរវាងបទរំលោភសេពសន្ថវៈ) ។ដូច្នេះ តុលាការអាចសម្រេចផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារចំនួន៨ឆ្នាំពិន័យ ៣លានរៀល នេះហៅថា ទោសរួម ចំពោះបទល្មើសត្រួតគ្នា (បទរំលោភសេពសន្ថវៈ និងបទហិង្សាដោយចេតនា)។

ឧទាហរណ៍ទី២៖ លោក មករា បានប្រព្រឹត្តបទល្មើសក្នុងស្ថានភាពជាបទល្មើសត្រួតគ្នាគឺរួមមានៈ

-បទរំលោភសេពសន្ថវៈ តាមមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ ផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ។

-បទកំហែងយក តាមមាត្រា៣៦៤ នៃក្រមព្រហ្មទណ្ឌ ផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី៤ លានរៀល ទៅ១០លានរៀល។

-បទឆបោក តាមមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៦លានរៀល។

តាមឧទាហរណ៍ទី២នេះ ប្រសិនបើតុលាការយល់ឃើញថាសម្រេចផ្តន្ទាទោសៈ

-ចំពោះបទរំលោភសេពសន្ថវៈ ផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ៨ឆ្នាំ

-ចំពោះបទកំហែងយក ផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ៤ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨លានរៀល

-ចំពោះបទឆបោក ផ្តន្ទាទោសដាក់ពន្ធនាគារចំនួន២ឆ្នាំ និងពិន័យជាប្រាក់ចំនួន៤លានរៀល។

អនុលោមតាមមាត្រា១៣៧នៃក្រមព្រហ្មទណ្ឌ តុលាការត្រូវប្រកាសទោសតែមួយចំពោះប្រភេទនៃទោសដាក់ពន្ធនាគារ និងប្រកាសទោសតែមួយចំពោះទោសពិន័យជាប្រាក់នៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ពោល តុលាការអាចប្រកាសទោសដាក់ពន្ធនាគារអតិបរមាច្រើនបំផុត១០ឆ្នាំ(អតិបរមានៃទោសដាក់

ពន្ធនាគារចំពោះបទរំលោភសេពន្លះ) និងទោសពិន័យជាប្រាក់អតិបរមាច្រើនបំផុតត្រឹម១០លានរៀល សម្រាប់បទល្មើសទាំង៣ខាងលើ។

ចំពោះទោសដាក់ពន្ធនាគារ ១០ឆ្នាំ និងទោសពិន័យជាប្រាក់ ១០លានរៀល ដែលតុលាការប្រកាសនោះ ត្រូវបានចាត់ទុកថាជាទោសរួម ចំពោះបទល្មើសត្រួតគ្នា នៅក្នុងព្រំដែនអតិបរមាស្របច្បាប់អនុវត្តទៅលើបទល្មើសនីមួយៗ ។[34]

## ២.៣.ការចោទប្រកាន់ដាច់ពីគ្នា

ចំពោះការចោទប្រកាន់ដាច់ពីគ្នាកើតឡើងក្នុងស្ថានភាពខុសប្លែកពីអ្វីដែលបានពន្យល់សម្រាប់ការចោទប្រកាន់តែមួយ ពោលគឺបទល្មើសត្រួតគ្នាត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿងផ្សេងពីគ្នា។ការចោទប្រកាន់ដាច់ពីគ្នានេះ សំដៅដល់ស្ថានភាពនៃនីតិវិធីដែលក្នុងនោះបទល្មើសត្រួតគ្នាទាំងអស់ ត្រូវបានធ្វើការចោទប្រកាន់នៅក្នុងលិខិតចោទប្រកាន់ពីរ ឬ ច្រើនដាច់ពីគ្នា ដូចជា ការចោទប្រកាន់បទល្មើសត្រួតគ្នានៅក្នុង ដីកាសន្និដ្ឋានបញ្ជូលរឿងឱ្យស៊ើបសួរពីរ ឬច្រើនដាច់ពីគ្នា កំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាមពីរ ឬច្រើនដាច់ពីគ្នា ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះពីរ ឬច្រើនដាច់ពីគ្នា ដីកាបញ្ជូនរឿងទៅជំនុំជម្រះពីរ ឬច្រើនដាច់ពីគ្នា។[35]

និយាយជារួម គឺការចោទប្រកាន់ដាច់ពីគ្នាគឺជាការចោទប្រកាន់ចំពោះបទល្មើសច្រើន ដែលប្រព្រឹត្តឡើងដោយបុគ្គលដដែលនៅក្នុងសំណុំរឿងពីរ ឬច្រើនដាច់ដោយឡែកពីគ្នា។

អនុលោមតាមមាត្រា១៣៨ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌនៅក្នុងពេលចោទប្រកាន់ដាច់ពីគ្នាកាលបើជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធពីបទល្មើសច្រើន ទោសដែលត្រូវប្រកាសត្រូវអនុវត្តត្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ខ្ពស់ជាងគេ។ ប៉ុន្តែតុលាការចុងក្រោយដែលត្រូវសម្រេចអាចប្រកាសឱ្យអនុវត្តទោសស្រូបបញ្ចូលគ្នា ឬ មួយផ្នែកនៃទោសដែលមានប្រភេទដូចគ្នា។

អនុលោមតាមបទប្បញ្ញត្តិខាងលើនេះ ក្នុងករណីដែលមានបទល្មើសត្រួតគ្នាកើតឡើងក៏ប៉ុន្តែចំពោះការចោទគឺជាការចោទប្រកាន់ដាច់ពីគ្នាគឺ ទោសអាចត្រូវអនុវត្តត្រួតគ្នា(**២.៣.១**) ឬត្រូវប្រកាសឱ្យស្រូបបញ្ចូលគ្នា(**២.៣.២**)។

### ២.៣.១.ការអនុវត្តទោសត្រួតគ្នា

យោងតាមមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌទោសនីមួយៗតុលាការប្រកាសត្រូវអនុវត្តត្រួតគ្នា ក្នុងព្រំដែនអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ។

[34] ឯកសារជំនួយស្មារតីសម្រាប់ការស្វែងយល់ក្រមព្រហ្មទណ្ឌ វិធានអនុវត្តក្នុងករណីបទល្មើសត្រួតគ្នា ដោយឯកឧត្តមសាស្ត្រាចារ្យ ហ៊ី សោភា , ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌។

[35] ការផ្សាយរបស់សាលាត្រាជូ បទល្មើសត្រួតគ្នា ដោយ ចក សម្បត្តិ ឆ្នាំ២០១៥ ទំព័រ៤២

ឧទាហរណ៍៖ លោក ចន្ទ ត្រូវបានសាលាដំបូងខេត្ត ក (តុលាការទីមួយ)សម្រេចផ្តន្ទាទោស ឱ្យជាប់ពន្ធនាគារចំនួន២ឆ្នាំ ពីបទឆបោក តាមមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ(អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឆបោកគឺ ៣ឆ្នាំ) និងពិន័យជាប្រាក់ចំនួន៤លានរៀល(អតិបរមានៃទោសពិន័យចំពោះបទឆបោកគឺ ៦លានរៀល) ហើយបន្ទាប់មក លោក ចន្ទ ដដែលក៏ត្រូវបានសាលាដំបូងខេត្ត ខ(តុលាការទីពីរ)ធ្វើការសម្រេចផ្តន្ទាទោសពី បទរំលោភសេពសន្ថវៈ ឱ្យជាប់ពន្ធនាគារចំនួន៩ឆ្នាំ តាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ (អតិបរមានៃទោសចំពោះបទរំលោភសេពសន្ថវៈគឺ ១០ឆ្នាំ)។នៅក្នុងការអនុវត្តទោសត្រួតគ្នាចំពោះបទល្មើសទាំងពីរនេះ គឺពុំត្រូវឱ្យលើសពីអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេទេ។[36]សរុបជារួមទោសដែលត្រូវយកប្រកាសលើទណ្ឌិតសម្រាប់បទល្មើសទាំងពីរគឺទោសដាក់ពន្ធនាគារចំនួន១០ឆ្នាំ មិនមែនត្រូវអនុវត្តទោសដាក់ពន្ធនាគារចំនួន ៩ឆ្នាំ បូកនឹង ២ឆ្នាំទេ និង ទោសពិន័យជាប្រាក់ចំនួន៤ លានរៀល។

ប្រសិនបើពិនិត្យទៅលើមាត្រា ១៣៨ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ នៅក្នុងករណីទោសដែលច្បាប់កំណត់ជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាស្របច្បាប់ខ្ពស់ជាងគេ ត្រូវបានកំណត់ដាក់ពន្ធនាគារត្រឹម ៣០ឆ្នាំ ប្រសិនបើជនជាប់ចោទមិនទាន់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតទេ។ការព្យួរទោសទាំងមូល ឬមួយផ្នែកនៃទោសដែលប្រកាសចំពោះបទល្មើសដែលត្រួតគ្នានេះ មិនអាចជាឧបសគ្គដល់ការអនុវត្តទោសនៃប្រភេទដូចគ្នាដែលគ្មានការព្យួរទោសទេ។

ឧទាហរណ៍៖ លោក អង្គារ ត្រូវបានសាលាដំបូងខេត្ត គ (តុលាការទីមួយ) សម្រេចផ្តន្ទាទោសឱ្យជាប់ពន្ធនាគារចំនួន២៨ឆ្នាំ ពីបទឃាតកម្មគិតទុកជាមុន យោងតាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ(ចំពោះអតិបរមានៃទោសដាក់ពន្ធនាគារគឺផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត)បន្ទាប់មកសាលាដំបូងខេត្ត ឃ (តុលាការទីពីរ) បានសម្រេចធ្វើការផ្តន្ទាទោសលើ លោក អង្គារ ពីបទកំហែងយកមានស្ថានទម្ងន់ទោសដោយសារការប្រើប្រាស់អាវុធ ឱ្យជាប់ពន្ធនាគារចំនួន ១៣ឆ្នាំ តាមមាត្រា ៣៦៦ នៃក្រមព្រហ្មទណ្ឌ(ចំពោះអតិបរមានៃទោសដាក់ពន្ធនាគារគឺផ្តន្ទាទោសដាក់ពន្ធនាគារ១៥ឆ្នាំ)។ចំពោះការអនុវត្តទោសត្រួតគ្នាចំពោះបទល្មើសទាំងពីរខាង គឺការផ្តន្ទាទោសមិនឱ្យលើសពីកម្រិតអតិបរមា ស្របច្បាប់ខ្ពស់ជាងគេនោះទេ។ក៏ប៉ុន្តែប្រសិនបើពិនិត្យលើមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ឃើញថាអតិបរមានៃទោសដាក់ពន្ធនាគារគឺអស់មួយជីវិត។ក៏ប៉ុន្តែប្រសិនបើពិនិត្យទៅលើមាត្រា ១៣៨នៃក្រមព្រហ្មទណ្ឌ ត្រង់កថាខណ្ឌទី ២ នៅក្នុងករណីទោសដែលច្បាប់កំណត់ជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ត្រូវបានកំណត់ដាក់ពន្ធនាគារត្រឹម ៣០ឆ្នាំ ប្រសិនបើជនជាប់ចោទមិនទាន់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតទេ។ដូច្នេះ យោងតាមមាត្រា១៣៨ នៃក្រមព្រហ្មទណ្ឌ គឺតម្រូវឱ្យជនជាប់ចោទត្រូវទទួលរងទោសដាក់ពន្ធនាគារចំនួន ៣០ឆ្នាំ។

---

[36] យោងតាមមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

### ២.៣.២.ការប្រកាសការស្រូបទោស

យោងតាមមាត្រា ១៣៨ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ តុលាការចុងក្រោយ អាចប្រកាសសម្រេចឱ្យអនុវត្តទោសស្រូបទោសបញ្ចូលគ្នាទាំងមូល ឬ មួយផ្នែកនៃទោសដែលមានប្រភេទដូចគ្នា។[37]

យោងតាមបទប្បញ្ញត្តិខាងលើបានបង្ហាញថា តុលាការចុងក្រោយអាចសម្រេចទោសដែល ប្រកាសត្រូវអនុវត្តស្រូបបញ្ចូលគ្នា ជាមួយនឹងទោសដែលត្រូវប្រកាសពីលើកមុន។ បើស្រូបទោសបញ្ចូលគ្នាទាំងមូល តុលាការត្រូវប្រកាសទោសតែមួយក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ។ ចំពោះការសម្រេចឱ្យស្រូបទោសទាំងមូល ឬស្រូបទោសមួយផ្នែកស្ថិតក្នុងឆន្ទានុសិទ្ធិរបស់តុលាការ ដោយសារថាមិនមានបទប្បញ្ញត្តិច្បាប់ណាមួយចែងជាក់លាក់ថា ករណីណាត្រូវស្រូបទោសទាំងមូល និងករណីណាត្រូវស្រូបទោសមួយផ្នែកនោះទេ។

ជាទូទៅនៅក្នុងករណីដែលតុលាការសម្រេចឱ្យស្រូបទោស តុលាការតែងយកទោសដែលស្រាលជាងស្រូបបញ្ចូល ទៅក្នុងទោសដែលធ្ងន់ជាង។ វិធានអនុវត្តតាមមាត្រា១៣៨ នៃក្រមព្រហ្មទណ្ឌតុលាការចុងក្រោយអាចប្រកាសឱ្យអនុវត្តទោសស្រូបទោសបញ្ចូលគ្នាបាន បើសំណុំរឿងព្រហ្មទណ្ឌកំពុងស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួននៅឡើយ។ការសម្រេចនេះ តុលាការអាចសម្រេចដោយឯកឯងបាន អំពីការស្រូបទោសបញ្ចូលគ្នា បើសំណុំរឿងព្រហ្មទណ្ឌនោះស្ថិតនៅក្នុង សមត្ថកិច្ចតុលាការចុងក្រោយរបស់ខ្លួន។ ក្នុងករណីចុងក្រោយនេះ តុលាការត្រូវសម្រេចក្នុង ពេលសវនាការជាសាធារណៈ ក្រោយបានស្តាប់ពីអយ្យការ ភាគីពាក់ព័ន្ធ និងជាយថាហេតុ មេធាវីរបស់ភាគីនេះ។ក្នុងគ្រប់ករណីទាំងអស់ ការស្រូបទោសបញ្ចូលគ្នាត្រូវធ្វើតាមសាលក្រម ឬ សាលដីការបស់តុលាការ។

ឧទាហរណ៍ទី១៖ លោក ពុធ បានប្រព្រឹត្តបទល្មើសត្រួតគ្នាគឺបានលួចទ្រព្យសម្បត្តិអ្នកជិតខាងនៅថ្ងៃទី ១ ខែមីនា ឆ្នាំ២០២២ នៅខេត្ត ក ចំពោះបទ លួចតាមមាត្រា៣៥៣(ទោសដាក់ពន្ធនាគារពី៦ខែ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៦លានរៀល) នៃក្រមព្រហ្មទណ្ឌ ចំពោះសាលក្រមទី១ ចំពោះបទលួច ត្រូវបានសាលាដំបូងខេត្ត ក សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន៣ឆ្នាំ ។បន្ទាប់មកបាននៅថ្ងៃទី ៨ ខែមីនា ឆ្នាំ២០២២ នៅខេត្ត ខ លោក ពុធ បានទៅឆបោកប្រាក់មិត្តរបស់គាត់ ចំពោះបទឆបោក តាមមាត្រា៣៧៧ (ទោសដាក់ពន្ធនាគារពី ៦ខែ ទៅ៣ឆ្នាំ និងពិន័យជាប្រាក់ ១លានរៀល ទៅ ៦លានរៀល) ។ បន្ទាប់ពីឃាត់ខ្លួនលោក ពុធបានបញ្ជូនទៅសាលាដំបូងខេត្ត ខ ។នៅក្នុងនីតិវិធីនៃការជំនុំជម្រះលើបទឆបោក តុលាការចុងក្រោយ(សាលាដំបូងខេត្ត ខ)នេះអាចប្រកាសស្រូបទោសបាន គឺតុលាការបានសម្រេចផ្តន្ទាទោសលើ លោក ពុធ ដាក់ពន្ធនាគារចំនួន ២ឆ្នាំ ពីបទ

[37] តុលាការចុងក្រោយ សំដៅទៅលើសាលាជម្រះក្តីណាមួយ ដែលធ្វើការសម្រេចផ្តន្ទាទោសលើបទល្មើសត្រួតគ្នាក្រោយគេ ដោយរួមបញ្ចូលសាលាជម្រះក្តីជាន់ទាប និងសាលាជម្រះក្តីជាន់ខ្ពស់ ជារួមទាំងសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល។

ឆបោក ក៏ប៉ុន្តែទោសនេះត្រូវបានស្រូបបញ្ចូលគ្នាជាមួយនឹងទោស ៣ឆ្នាំ ដែលបានប្រកាសពីបទលួច តាមសាលក្រមទី១(សាលាដំបូងខេត្ត ក) ។ ដូច្នេះលោក ពុធ ត្រូវទទួលរងទោសដាក់ពន្ធនាគារចំនួន ៣ឆ្នាំ នេះគឺជាការប្រកាសស្រូបទោសទាំងមូល ។

-ករណីចំពោះឧទាហរណ៍ទី១ខាងលើនេះ គឺការអនុវត្តជាក់ស្តែងតិចតួចប៉ុណ្ណោះ ក៏ព្រោះតែសាលក្រមទីពីរលើបទឆបោកកំពុងស្ថិតនៅក្នុងសមត្ថកិច្ចរបស់តុលាការចុងក្រោយ នៅឡើយ តុលាការចុងក្រោយអាចសម្រេចដោយឆន្ទានុសិទ្ធិ បានអំពីការស្រូបទោសស្របតាមមាត្រា១៣៨នៃក្រមព្រហ្មទណ្ឌ។

ឧទាហរណ៍ទី២៖ លោក សៅ បានប្រព្រឹត្តបទល្មើសត្រួតគ្នាគឺបានលួចទ្រព្យសម្បត្តិអ្នកជិតខាងនៅថ្ងៃទី ១ ខែមីនា ឆ្នាំ២០២២ នៅខេត្ត ក ចំពោះបទ លួចតាមមាត្រា៣៥៣(ទោសដាក់ពន្ធនាគារពី៦ខែ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៦លានរៀល) នៃក្រមព្រហ្មទណ្ឌ ចំពោះសាលក្រមទី១ ចំពោះបទលួច ត្រូវបានសាលាដំបូងខេត្ត ក សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន២ឆ្នាំ ។បន្ទាប់មកបាននៅថ្ងៃទី ៨ ខែមីនា ឆ្នាំ២០២២ នៅខេត្ត ខ លោក សៅ បានទៅឆបោកប្រាក់មិត្តរបស់គាត់ ចំពោះបទឆបោក តាមមាត្រា៣៧៧ (ទោសដាក់ពន្ធនាគារពី ៦ខែ ទៅ៣ឆ្នាំ និងពិន័យជាប្រាក់ ១លានរៀល ទៅ ៦លានរៀល) ។ ចំពោះសាលក្រមទី២ ចំពោះបទឆបោក ត្រូវបានសាលាដំបូងខេត្ត ខ សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ២ឆ្នាំ ៦ខែ។

ករណីនេះសាលក្រមទាំងពីរចូលជាស្ថាពរ គឺទណ្ឌិតអាចដាក់ពាក្យសុំស្រូបទោសទៅតុលាការចុងក្រោយ (តុលាការដែលចេញសាលក្រមទី២)។ [38] ករណីនេះតុលាការអាចសម្រេចស្រូបទោសទាំងមូល ឬ អាចសម្រេចស្រូបទោសមួយផ្នែកបាន។

-ប្រសិនបើតុលាការសម្រេចស្រូបទោសទាំងមូល៖ ផ្តន្ទាទោសដាក់ពន្ធនាគារ ២ឆ្នាំ ស្រូបបញ្ចូលទាំងស្រុងជាមួយនឹងទោស ២ឆ្នាំ ៦ខែ។ដូច្នេះ ទណ្ឌិតអនុវត្តទោស ២ឆ្នាំ ៦ខែ សម្រាប់សាលក្រមទាំងពីរក្នុងការអនុវត្តទោស។ក្នុងករណីស្រូបទោសទាំងមូល ទោសដាក់ពន្ធនាគារចំនួន ២ឆ្នាំ(ទោសស្រាលជាង) ត្រូវបានស្រូបបញ្ចូលទៅក្នុងទោសដាក់ពន្ធនាគារចំនួន ២ឆ្នាំ ៦ខែ(ទោសធ្ងន់ជាង) ពោលនៅពេលដែលទណ្ឌិតអនុវត្តទោស ២ឆ្នាំ ៦ខែ គឺទណ្ឌិតក៏ដូចអនុវត្តទោស ២ឆ្នាំ ព្រមជាមួយគ្នាដែរ។ដូច្នេះជាក់ស្តែង ទណ្ឌិតត្រូវអនុវត្តទោសក្នុងពន្ធនាគារត្រឹមតែ ២ឆ្នាំ ៦ខែ។

-ប្រសិនបើតុលាការសម្រេចស្រូបទោសមួយផ្នែក៖ ផ្តន្ទាទោសដាក់ពន្ធនាគារ ២ឆ្នាំ ស្រូបបញ្ចូលត្រឹម ១ឆ្នាំ៩ខែ ជាមួយនឹងទោស២ឆ្នាំ ៦ខែ។ដូច្នេះ ទណ្ឌិតអនុវត្តទោស ២ឆ្នាំ៦ខែ បូកជាមួយទោស៣ខែ គឺ ២ឆ្នាំ ៩ខែ សម្រាប់សាលក្រមទាំងពីរ។ ក្នុងករណីស្រូបទោសមួយផ្នែក មានតែទោសដាក់ពន្ធនាគារ ១ឆ្នាំ ៩ខែ ប៉ុណ្ណោះ

[38] យោងមាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ដែលត្រូវបានស្រូបបញ្ចូលទៅក្នុងទោស ២ឆ្នាំ ៦ខែ ចំណែកទោសដាក់ពន្ធនាគារចំនួន៣ខែទៀត គឺត្រូវអនុវត្ត ជាក់ស្ដែងដោយមិនមានការស្រូបទោសឡើយ។ដូច្នេះសរុបមកទណ្ឌិតត្រូវអនុវត្តទោសក្នុងពន្ធនាគារ២ឆ្នាំ៩ខែ។

-ករណីចំពោះឧទាហរណ៍ទី២ខាងលើនេះ គឺការអនុវត្តជាក់ស្ដែងត្រូវបានប្រើជាញឹកញាប់ ក៏ព្រោះតែសាលក្រមទី ១ និងសាលក្រមទី២ ចូលជាស្ថាពរ។ករណីប្រសិនបើតុលាការមិនបានសម្រេចអំពីការស្រូបទោស អង្គការ អយ្យការ ឬភាគីដែលពាក់ព័ន្ធអាចប្ដឹងសុំឱ្យអនុវត្តការស្រូបទោសបញ្ចូលគ្នា ទៅតុលាការដែលបានសម្រេចចុង ក្រោយគេ។

ឧទាហរណ៍ទី៣៖ លោក ចន្ទ បានប្រព្រឹត្តបទល្មើសត្រួតគ្នាគឺនៅថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០២២ គាត់បាន ប្រព្រឹត្តបទឃាតកម្ម(ទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ១៥ឆ្នាំ) តាមមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ។ចំពោះសាល ក្រមទី១ តុលាការបានសម្រេចផ្ដន្ទាទោសជាស្ថាពរដាក់ពន្ធនាគារចំនួន១០ឆ្នាំ ចំពោះបទឃាតកម្មនេះ។ហើយ នៅថ្ងៃទី ៦ ខែកក្កដា ឆ្នាំ២០២២ ជនល្មើសក៏បានប្រព្រឹត្តបទរំលោភលើទំនុកចិត្ត តាមមាត្រា នៃក្រមព្រហ្មទណ្ឌ (ទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី១លានរៀល ទៅ៦លានរៀល)។ចំពោះសាលក្រមទី២ តុលាការបានសម្រេចផ្ដន្ទាទោសជាស្ថាពរដាក់ពន្ធនាគារចំនួន ២ឆ្នាំ ចំពោះបទរំលោភលើទំនុកចិត្តនេះ។ ក្រោយ ពីសាលក្រមទាំងពីរចូលជាស្ថាពររួចហើយនោះ ទណ្ឌិតបានដាក់ពាក្យសុំស្រូបទោសមក តុលាការចុងក្រោយ (តុលាការទី២) ។

ចំពោះឧទាហរណ៍ទី៣ខាងលើនេះតុលាការអាចសម្រេចដូចតទៅ៖

-សម្មតិកម្មទី១៖ តុលាការបដិសេធការស្រូបទោស(មិនអនុញ្ញាតឱ្យស្រូបទោស) ក៏ព្រោះតែនេះគឺជាឆន្ទានុ សិទ្ធិរបស់តុលាការ ប្រសិនបើបូកទោសទាំងពីរខាងលើបញ្ចូលគ្នាគឺ ទោសដាក់ពន្ធនាគារ ១០ឆ្នាំ បូកនឹងទោស ដាក់ពន្ធនាគារ២ឆ្នាំគឺមិនលើសពីកម្រិតអតិបរមាស្របច្បាប់នៃទោសដែលខ្ពស់ជាងគេ ១៥ឆ្នាំ(អតិបរមានៃទោស ចំពោះបទឃាតកម្ម)។

-សម្មតិកម្មទី២៖ តុលាការសម្រេចឱ្យស្រូបទោសទាំងមូលគឺ ផ្ដន្ទាទោសដាក់ពន្ធនាគារ២ឆ្នាំ ពីបទ រំលោភលើទំនុកចិត្ត ស្រូបបញ្ចូលទាំងមូលជាមួយនឹងទោសដាក់ពន្ធនាគារចំនួន១០ឆ្នាំ។ ដូច្នេះទណ្ឌិតគឺត្រូវ អនុវត្តទោសដាក់ពន្ធនាគារសរុប ចំនួន១០ឆ្នាំ សម្រាប់បទល្មើសទាំងពីរនេះ។ចំពោះការសម្រេចស្រូបទោស ទាំងមូលនេះ គឺជាឆន្ទានុសិទ្ធិរបស់តុលាការ ពីព្រោះថា បើបូកទោសទាំងពីរខាងលើបញ្ចូលគ្នា ទោសដាក់ ពន្ធនាគារ១០ឆ្នាំ បូកនឹងទោសដាក់ពន្ធនាគារ២ឆ្នាំ គឺមិនលើសពីកម្រិតអតិបរមាស្របច្បាប់នៃទោស(អតិបរមានៃ ទោសចំពោះបទឃាតកម្ម)ដែលខ្ពស់ជាគេនោះទេ ។

-សម្មតិកម្មទី៣៖ តុលាការសម្រេចឱ្យស្រូបទោសមួយផ្នែកគឺផ្ដន្ទាទោសដាក់ពន្ធនាគារ២ឆ្នាំ ពីបទ រំលោភលើទំនុកចិត្ត ស្រូបបញ្ចូលត្រឹម ៦ខែ ជាមួយនឹងទោសដាក់ពន្ធនាគារចំនួន១០ឆ្នាំ។ដូច្នេះ ទណ្ឌិតត្រូវអនុ

វត្តទោសដាក់ពន្ធនាគារសរុបចំនួន១១ឆ្នាំ ៦ខែ សម្រាប់បទល្មើសទាំងពីរនេះ។ចំពោះការសម្រេចស្រូបមួយផ្នែកនេះ គឺជាឆន្ទានុសិទ្ធិរបស់តុលាការ ពីព្រោះថា បើបូកទោសទាំងពីរខាងលើបញ្ចូលគ្នា ទោសដាក់ពន្ធនាគារ១០ឆ្នាំ បូកនឹងទោសដាក់ពន្ធនាគារ២ឆ្នាំ គឺមិនលើសពីកម្រិតអតិបរមាស្របច្បាប់នៃទោស(អតិបរមានៃទោសចំពោះបទឃាតកម្ម)ដែលខ្ពស់ជាគេនោះទេ ។

## ២.៤.ការអនុវត្តវិធានបូកទោស

ទោះបីជាមានការប្រើនីតិវិធីនៃការចោទប្រកាន់តែមួយ ឬ ការចោទប្រកាន់ដោយឡែកគឺវិធានបូកទោសត្រូវយកអនុវត្តករណីដែលចែងច្បាស់ដោយច្បាប់។ករណីដែលក្រមព្រហ្មទណ្ឌអនុវត្តវិធានបូកទោសបញ្ចូលគ្នាគឺជនជាប់ចោទបានប្រព្រឹត្តបទលហុដែលមានទោសពិន័យ (**២.៤.១**) និង ករណីទណ្ឌិតបានលួចរត់ចេញពីពន្ធនាគារ(**២.៤.២**)។

### ២.៤.១.ការបូកទោសបញ្ចូលគ្នាចំពោះបទលហុច្រើន

អនុលោមតាមមាត្រា១៤០ នៃក្រមព្រហ្មទណ្ឌបានចែងថា ជាបដិប្បញ្ញត្តិទៅលើបទប្បញ្ញត្តិមុនការពិន័យដែលបានប្រកាសឡើង ចំពោះបទលហុច្រើននោះ ត្រូវបញ្ចូលគ្នា ហើយត្រូវបូកផងដែរជាមួយទោសពិន័យដែលបានប្រកាសឡើងចំពោះបទឧក្រិដ្ឋ ឬ បទមជ្ឈិម ។[39]

យោងតាមខ្លឹមសារខាងលើនេះ ចំពោះទោសពិន័យដែលត្រូវប្រកាសចំពោះបទលហុ មិនអាចយកទៅស្រូបបញ្ចូលគ្នាជាមួយនឹងទោសពិន័យដែលបានប្រកាសចំពោះបទលហុ ឬបទមជ្ឈិម ឬបទឧក្រិដ្ឋផ្សេងទៀតឡើយ។វិធាននេះអនុវត្តការបូកទោសចំពោះទោសពិន័យជាប្រាក់ ចំពោះបទលហុច្រើន និងបូកផងដែរ ជាមួយទោសពិន័យចំពោះបទមជ្ឈិម និងបទឧក្រិដ្ឋ។

ជាវិធានដោយឡែកមួយដែលមានលក្ខណៈផ្ទុយពីវិធានស្រូបទោស និង វិធានត្រួតទោសក៏ព្រោះតែពិរុទ្ធជនមិនកែប្រែខ្លួន។ វិធាននេះត្រូវយកមកអនុវត្តចំពោះបទល្មើសត្រួតគ្នាទោះស្ថិតក្នុង នីតិវិធីនៃការចោទប្រកាន់តែមួយ ឬ នីតិវិធីចោទប្រកាន់ដាច់ដោយឡែកពីគ្នាក្តី។

ឧទាហរណ៍៖ លោក ពុធ បានប្រព្រឹត្តបទល្មើសត្រួតគ្នាចំនួនពីរគឺ បទហិង្សាស្រាល ដែលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥ពាន់រៀល ទៅ ១សែនរៀល តាមមាត្រា ២២៩ នៃក្រមព្រហ្មទណ្ឌ និង បទកំហែងយក ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំ ទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី៤លាន រៀល ទៅ ១០លានរៀល យោងតាមមាត្រា៣៦៤ នៃក្រមព្រហ្មទណ្ឌ។ ចំពោះបទហិង្សា គឺជាបទលហុ ហេតុដូច្នេះ ទោសពិន័យដែលបានប្រកាសពីបទហិង្សាស្រាល នេះគឺ ត្រូវយកទៅបូកជាមួយទោសពិន័យ ដែលត្រូវប្រកាសជាមួយបទកំហែងយក ។

[39] សៀវភៅសិក្សានីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ២០២២ ដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ទំព័រ ៤៨៩

ដូចនេះតុលាការប្រកាសទោសដាក់ពន្ធនាគារចំនួន ៣ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥លាន១សែនរៀល ចំពោះ លោកពុធ ដែលជាជនល្មើសបានប្រព្រឹត្តបទល្មើស។

**២.៤.២.ករណីរត់ចេញពីពន្ធនាគារ**

អនុលោមតាមមាត្រា១៤១ នៃក្រមព្រហ្មទណ្ឌបានចែងថា ក្នុងករណីផ្តន្ទាទោសពីបទរត់ចេញពីពន្ធនាគារ ទោសដែលបានប្រកាសពីបទនេះត្រូវបូកជាមួយនឹងទោសដែលបានប្រកាសឡើង ចំពោះបទល្មើសដែលនាំឱ្យមានការឃុំខ្លួនជននោះ ដោយមិនអាចមានការស្រូបទោសចូលគ្នា។

ជាវិធានដោយឡែកមួយមានលក្ខណៈផ្ទុយពីវិធានស្រូបទោស និង វិធានត្រួតទោសព្រោះតែទណ្ឌិតមិនកែប្រែខ្លួនហើយបានរត់ចេញពីពន្ធនាគារ។ វិធានបូកទោសនេះក៏អនុវត្តចំពោះទោសដាក់ពន្ធនាគារពីបទរត់ចេញពីពន្ធនាគារត្រូវបូកជាមួយទោសដែលប្រកាសចំពោះបទល្មើសដែលកំពុងជាប់ពន្ធនាគារ។

-ចំពោះបទល្មើសទាក់ទងនឹងការរត់ចេញពីពន្ធនាគារគឺមានចែងចាប់ពីមាត្រា ៥៦០ ដល់មាត្រា ៥៧០ នៃក្រមព្រហ្មទណ្ឌ។[40]

ឧទាហរណ៍៖ លោក អង្គារ ត្រូវបានតុលាការឃុំខ្លួនជាបណ្តោះអាសន្នពី បទហិង្សាដោយចេតនា ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២លានរៀល ទៅ ៦លានរៀល យោងតាមមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។ ក៏ប៉ុន្តែនៅក្នុងដំណាក់កាលឃុំខ្លួនបណ្តោះអាសន្ននោះ ជនល្មើសបានលួចរត់ខ្លួនចេញពីពន្ធនាគារ។ ចំពោះអំពើនេះគឺជាបទ ការលួចរត់ ដោយអនុលោមតាមមាត្រា៥៦១ នៃក្រមព្រហ្មទណ្ឌ ហើយដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២លានរៀល ទៅ ៦លានរៀល ដោយយោងតាមមាត្រា៥៦១ នៃក្រមព្រហ្មទណ្ឌ។ក្រោយពីការរត់ចេញពីពន្ធនាគារហើយជនល្មើសខាងលើត្រូវបានឃាត់ខ្លួនសាជាថ្មី។ក្នុងករណី ជនល្មើសនេះបានប្រព្រឹត្តបទល្មើសត្រួតគ្នា គឺបទហិង្សាដោយចេតនា និងបទការលួចរត់។ដោយសារការប្រព្រឹត្តបទល្មើសទាំងពីរខាងលើតុលាការមិនអាចអនុវត្តតាមគោលការណ៍នៃ មាត្រា ១៣៧ និងមាត្រា១៣៨នៃក្រមព្រហ្មទណ្ឌបានឡើយគឺតុលាការអនុវត្តតាមមាត្រា១៤១ នៃក្រមព្រហ្មទណ្ឌគឺការមិនស្រូបចូលនៃទោសដែលត្រូវបានប្រកាសចំពោះករណីរត់ចេញពីពន្ធនាគារ។ដូច្នេះ តុលាការអាចសម្រេចផ្តន្ទាទោស លោកអង្គារ ដាក់ពន្ធនាគារចំនួន ២ឆ្នាំ និងពិន័យជាប្រាក់ចំនួន៤លានរៀល ចំពោះបទហិង្សាដោយចេតនា និងបូកបន្ថែមជាមួយទោសនៃបទលួចរត់ ដាក់ពន្ធនាគារ១ឆ្នាំ និងពិន័យជាប្រាក់ចំនួន២លានរៀល។ដូចនេះសរុបជារួមចំពោះបទល្មើសត្រួតទាំងពីរខាងនេះ លោកអង្គារ ត្រូវផ្តន្ទាទោសដាក់ពន្ធនគារចំនួន ៣ឆ្នាំ និងពិន័យជាប្រាក់ចំនួន៦លានរៀល។

[40] សៀវភៅសិក្សានីតិព្រហ្មទណ្ឌទូទៅ ដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ទំព័រ៤៩០

# ជំពូកទី៣
# ការកំណត់ទោស ដោយ ចៅក្រម ក្នុង ករណីមានស្ថានទម្ងន់ទោស ឬស្ថាន សម្រាលទោស

# ជំពូកទី៣
# ការកំណត់ទោស ដោយ ចៅក្រម ក្នុងករណីមានស្ថានទម្ងន់ទោស ឬស្ថានសម្រាលទោស

ប្រសិនបើជនណាបានប្រព្រឹត្តបទល្មើសណាមួយមិនថាបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ឬ ច្បាប់ពិសេសដូចជា ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់និងហិរិញ្ញប្បទានភេរវកម្ម ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងបទប្បញ្ញត្តិគតិយុត្តផ្សេងៗទៀត។បន្ទាប់ពីបានរកឃើញពិរុទ្ធភាពរបស់ចារីនៃបទល្មើសរួចហើយ ចៅក្រមត្រូវកំណត់ពីការផ្តន្ទាទោសដែលចារីនឹងត្រូវទទួលរង។ បន្ថែមពីនេះទៀត ចៅក្រមត្រូវតែគិតពិចារណាពីស្ថានភាពពិតជាក់ស្តែងនៃបទល្មើសដែលជំរុញឱ្យមានការប្រព្រឹត្តបទល្មើសនិងពិចារណាពីស្ថានភាពបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ។ ហេតុដូចនេះទើបមានភាពខុសផ្លែកគ្នាក្នុងការប្រកាសទោសម្តងៗ បើទោះបីជាការប្រព្រឹត្តបទល្មើសដូចគ្នាក៏ដោយ ក៏ប៉ុន្តែបែរជាការកម្រិតទោសខុសៗគ្នាពីករណីមួយទៅករណីមួយទៀត។ ក្នុងការផ្តន្ទាទោសចំពោះជនល្មើស គឺ ចៅក្រមមានតួនាទីជាអ្នកអនុវត្តច្បាប់គឺមិនត្រូវដាក់ទោសឱ្យតិចជាងអប្បបរមានៃទោស ឬ ច្រើនជាងអតិបរមានៃទោសឡើយដោយផ្អែកលើគោលការណ៍នីត្យានុកូលភាព។[41] ក៏ប៉ុន្តែចៅក្រមអាចអនុវត្តផ្ទុយពីករណីដែលបកស្រាយខាងលើនេះគឺនៅក្នុងករណីនេះក្រមព្រហ្មទណ្ឌបានចែងពីស្ថានភាពទាក់ទងនឹងស្ថានសម្រាលទោស និងស្ថានទម្ងន់ទោស។ ជាទូទៅការកំណត់ទោសរបស់តុលាការគឺមិនឱ្យលើសពីអតិបរមានៃទោសនិងមិនឱ្យក្រោមអប្បបរមានៃទោសក៏ប៉ុន្តែករណីនេះតុលាការអាចកំណត់ទោសដោយឆន្ទានុសិទ្ធិបានគឺ នៅក្នុងករណីបែបនេះក្រមព្រហ្មទណ្ឌបានចែងពី ស្ថានទម្ងន់ទោស(**៣.១**) និងស្ថានសម្រាលទោស(**៣.២**) ។

## ៣.១ស្ថានទម្ងន់ទោស

ស្ថានទម្ងន់ទោសទោះបី ជាមិនបានចែងនៅក្នុងក្រមព្រហ្មទណ្ឌជាក់លាក់ក៏ប៉ុន្តែអាចទាញចេញពីបទប្បញ្ញត្តិនៃច្បាប់របស់កម្ពុជា ជានិយមន័យស្ថានទម្ងន់ទោសគឺជាស្ថានភាពមួយចំនួនដែលច្បាប់បានចែងយ៉ាងជាក់ច្បាស់លាស់ដែលជាហេតុធ្វើឱ្យទោសដែល ត្រូវផ្តន្ទាទោសកាន់តែមានសភាពធ្ងន់ធ្ងរឡើងគឺធ្ងន់ធ្ងនជាងកម្រិតអតិបរមានៃទោសកំណត់ដោយច្បាប់។ ស្ថានទម្ងន់ទោសមិនមែនចង់សំដៅលើស្ថានទម្ងន់ដែលតុលាការ

[41] យោងតាមមាត្រា ៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ត្រូវយកមកពិចារណា ដើម្បីដាក់ទោសទៅលើជនជាប់ចោទដោយកម្រិតមិនឱ្យលើសពីអតិបរមានៃទោសដែលបានកំណត់ដោយច្បាប់នោះទេ។ ស្ថានទម្ងន់ទោស គឺជាស្ថានភាពមួយដែលនាំឱ្យមានការផ្តន្ទាទោសលើសពីអតិបរមានៃបទល្មើសដែលជនល្មើសបានប្រព្រឹត្ត។ ចំពោះស្ថានទម្ងន់ទោសនេះ ទាល់តែមានច្បាប់ចែងច្បាស់លាស់ប្រសិនបើច្បាប់មិនបានចែងច្បាស់លាស់នោះតុលាការមិនអាចយកមកធ្វើជាស្ថានទម្ងន់ទោសបានទេ។

ឧទាហរណ៍៖ ក្នុងករណីជនជាប់ចោទបានប្រព្រឹត្តបទល្មើសគឺបទឃាតកម្ម យោងតាមមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ (អប្បបរមានៃទោស) ទៅ ១៥ ឆ្នាំ(អតិបរមានៃទោស)។ បន្ទាប់មកតុលាការបានប្រកាសលើទោសជនជាប់ចោទ ១៤ឆ្នាំ ដោយតុលាការបានពិចារណាទៅលើ ស្ថានទម្ងន់ទោសពាក់ព័ន្ធនឹងរឿងក្តីនេះ ដោយផ្អែកលើគោលការណ៍ឯកត្តកម្មនៃទោស។ [42]

ឧទាហរណ៍៖ អំពើកំហែងយក យោងតាមមាត្រា៣៦៣ នៃក្រមព្រហ្មទណ្ឌត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ដល់ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០លានរៀលជាក់ស្តែងគឺជាបទមជ្ឈិម។[43]ក៏ប៉ុន្តែក្នុងករណីប្រសិនបើជនជាប់ចោទបានប្រព្រឹត្តដោយមានស្ថានទម្ងន់ទោសក្នុងករណីនេះអំពើកំហែងយកតាមមាត្រា ៣៦៥ នៃក្រមព្រហ្មទណ្ឌ គឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ឆ្នាំ ជាក់ស្តែងគឺជាបទឧក្រិដ្ឋ។[44]

យោងតាមក្រមព្រហ្មទណ្ឌ ស្ថានទម្ងន់ទោសខ្លះគឺជាស្ថានទម្ងន់ទោសទូទៅ (**៣.១.១**)ចំណែកករណីខ្លះគឺស្ថានទម្ងន់ទោសដោយឡែក(**៣.១.២**)ដែលចែងសម្រាប់បទល្មើសជាក់លាក់ណាមួយ។

### ៣.១.១ ស្ថានទម្ងន់ទោសទូទៅ

យោងតាមខ្លឹមសារមាត្រា៨៣ នៃក្រមព្រហ្មទណ្ឌចែងថា ការមិនរាងចាលមានអានុភាពនាំឱ្យមានការបន្ថែមទម្ងន់អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិម នៅក្នុងលក្ខខណ្ឌដែលមានចែងដោយកថាភាគនេះ។

តាមបទប្បញ្ញត្តិខាងលើក៏បានបង្ហាញថា ក្រមព្រហ្មទណ្ឌពុំបាន កម្រិតការអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាលទៅលើបទឧក្រិដ្ឋ ឬ បទមជ្ឈិម ណាមួយឡើយដែលជាហេតុនាំឱ្យមានការគិតសន្និដ្ឋានថាស្ថាន់ទម្ងន់ទោសនេះត្រូវយកមកអនុវត្តសម្រាប់រាល់បទឧក្រិដ្ឋ ឬ បទមជ្ឈិមទាំងអស់កាលបើលក្ខខណ្ឌនៃការមិនរាងចាលត្រូវបានបំពេញ។ស្ថានទម្ងន់ទោសទូទៅមានតែមួយគត់គឺការមិនរាងចាលមានភាពជាក់លាក់ចំពោះ បទល្មើស

[42] យោងតាមមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[43] យោងតាមមាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[44] យោងតាមមាត្រា ៤៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ណាក៏ដោយឱ្យតែស្ថិតក្នុងស្ថានភាពមិនរាងចាលគឺទោសត្រូវតែកើន។ ការមិនរាងចាល គឺជាស្ថានទម្ងន់ទោស ដែលត្រូវយកទៅអនុវត្តសម្រាប់រាល់បទឧក្រិដ្ឋ ឬ បទមជ្ឈិ
មទាំងអស់។កាលបើលក្ខខណ្ឌនៃការមិនរាងត្រូវបានបំពេញយ៉ាងគ្រប់គ្រាន់។ ជាគោលការណ៍ការដាក់ទណ្ឌកម្ម លើបទល្មើសណាមួយគឺត្រូវផ្តន្ទាទោសទៅលើជនចាប់ចោទ ឱ្យទទួលទោសតាម ចំណាត់ថ្នាក់នៃបទល្មើស នោះ។ ករណីខាងលើនេះច្បាប់បានកំណត់តាមសកម្មភាពរបស់ជនល្មើសដែលបានប្រព្រឹត្តបទល្មើសក្នុងករណី មិនរាងចាលគឺជនល្មើសបានប្រព្រឹត្ត បទល្មើសណាមួយហើយ និង ត្រូវបានតុលាការសម្រេចផ្តន្ទាទោសដែល សេចក្តីសម្រេចនោះចូលជាស្ថាពរ។បន្ទាប់ពីអំឡុងពេលអនុវត្តទោសនោះហើយជនល្មើសបានទៅប្រព្រឹត្តបទ ល្មើសមួយផ្សេងទៀត ក្នុងរយៈពេលដែលមានចែងក្នុងបទប្បញ្ញត្តិណាមួយនៃក្រមព្រហ្មទណ្ឌ សកម្មភាពនេះ ហើយដែលច្បាប់បានបញ្ញត្តិចាត់ទុកជាករណីនៃការមិនរាងចាល។

ការមិនរាងចាល គឺបានសម្តែងឱ្យឃើញពីភាពបរាជ័យនៃការផ្តន្ទាទោសជាស្ថាពរកាលពីលើកមុនទៅ លើបទល្មើសដែលជនល្មើសបានប្រព្រឹត្ត ក្រោយមកជនល្មើសបានប្រព្រឹត្តបទល្មើសថ្មីទៀតតាមលក្ខខណ្ឌនៃ ច្បាប់កំណត់។ហេតុដូចនេះដើម្បីកំណត់ថាជនណាម្នាក់ស្ថិតនៅក្នុងករណីមិនរាងចាល គឺត្រូវស្ថិតក្នុងលក្ខខណ្ឌ ចាំបាច់មួយចំនួនដែលត្រូវបានបំពេញនៃការមិនរាងចាល (**៣.១.១.១**)នឹងមានអានុភាពបន្ថែមទម្ងន់ទោសទៅ តាមប្រភេទនៃបទល្មើសនីមួយៗ(**៣.១.១.២**)។[45]

### ៣.១.១.១ ករណីនៃការមិនរាងចាល

ករណីនៃការមិនរាងចាលដោយយោងតាមមាត្រា៨៤ នៃក្រមព្រហ្មទណ្ឌបានចែងថាករណីដែលជន ណាម្នាក់បានប្រព្រឹត្តបទល្មើស តាមការបទប្បញ្ញត្តិនេះទោះបីជាក្នុងករណីណាក៏ដោយគឺចាត់ទុកថាជាការ ប្រព្រឹត្តបទល្មើសក្នុងករណីមិនរាងចាល។ យោងតាមខ្លឹមសារនៃមាត្រា៨៤ ការកំណត់ជនណាម្នាក់ស្ថិតក្នុង ស្ថានភាពមិនរាងចាលឬក៏អត់ គឺត្រូវតែពិនិត្យទៅលើប្រភេទបទល្មើស គឺទីមួយតុលាការបានសម្រេចផ្តន្ទាទោស ជាស្ថាពររួចហើយ និងប្រភេទបទល្មើសថ្មីដែលចារីបានប្រព្រឹត្ត ព្រមទាំងរយៈពេលគម្លាតរវាងការផ្តន្ទាទោសជា ស្ថាពរកាលពីលើកមុនការប្រព្រឹត្តបទល្មើសថ្មីចុងក្រោយបន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីលើកមុន។[46]

លក្ខខណ្ឌនៃមាត្រា៨៤នៃក្រមព្រហ្មទណ្ឌទាក់ទងនឹងការមិនរាងចាលមានដូចតទៅ៖

ក.កាលបើបុគ្គលណាម្នាក់ត្រូវផ្តន្ទាទោសជាស្ថាពររួចហើយពីបទឧក្រិដ្ឋបុគ្គលនោះបានប្រព្រឹត្ត បទឧក្រិដ្ឋថ្មីទៀតក្នុងរយៈពេល១០ឆ្នាំ

[45] សៀវភៅសិក្សានីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ២០២២ ដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ទំព័រ ៤៤៣ និង៤៤៤

[46] យោងតាមមាត្រា ៩១ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

នេះគឺជាករណីដែលជនណាម្នាក់ត្រូវបានផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ និងអានុភាពរបស់វាត្រូវបានប្រែប្រួលទៅតាមប្រភេទនៃ បទល្មើសទី២គឺជាបទល្មើសឧក្រិដ្ឋ។ ជារួមការចាត់ទុកថាជាការមិនរាងចាលគឺលុះត្រាតែ បទឧក្រិដ្ឋទី២បានកើតឡើងក្នុងរយៈពេល១០ឆ្នាំ ។

ដើម្បីកត់សម្គាល់ថា គម្លាតពេលរវាងការផ្តន្ទាទោសលើកមុន និង ការប្រព្រឹត្តបទល្មើសជាថ្មីម្តងទៀតត្រូវចាប់ផ្តើមគិតពីថ្ងៃដែលសេចក្តីសម្រេចរបស់តុលាការដែលបានផ្តន្ទាទោសចំពោះបទល្មើសលើកទីមួយ បានចូលជាស្ថាពររួចហើយ។

ដូចនេះដើម្បីដឹងថាបុគ្គលណាម្នាក់ ធ្លាប់ត្រូវបានតុលាការសម្រេចផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ហើយបន្ទាប់មកជននោះបានប្រព្រឹត្តបទឧក្រិដ្ឋថ្មីមួយទៀត ក្នុងរយៈពេល១០ឆ្នាំ គឺនៅក្នុងស្ថានភាពនេះហើយគេត្រូវពិនិត្យមើលអតិបរមានៃទោសសម្រាប់បទល្មើសថ្មីនោះជាមុនសិន។

- ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារ ចំពោះបទឧក្រិដ្ឋថ្មីមិនលើសពី២០ឆ្នាំទេ នោះអតិបរមានេះត្រូវឡើងទ្វេដង។

ឧទាហរណ៍៖ លោក សៅ ត្រូវបានតុលាការបានសម្រេចផ្តន្ទាទោសពី បទកំហែងយកដោយសារការប្រើប្រាស់អាវុធ យោងតាមមាត្រា៣៦៦ នៃក្រមព្រហ្មទណ្ឌតុលាការបានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន៨ឆ្នាំ។បន្ទាប់មក សេចក្តីសម្រេចផ្តន្ទាទោសក៏បានចូលជាស្ថាពរនៅថ្ងៃទី ១ ខែមករា ឆ្នាំ២០១០។ ហើយនៅថ្ងៃទី ១ ខែមេសា ឆ្នាំ២០១៧ លោកត្រូវបានដោះលែងឱ្យមានសេរីភាពឡើងវិញ។ក៏ប៉ុន្តែប៉ុន្មានឆ្នាំក្រោយមក គឺនៅថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១៨ បានប្រព្រឹត្តបទល្មើសថ្មីគឺបទទារុណកម្ម និងអំពើឃោរឃៅ យោងតាមមាត្រា២១០នៃក្រមព្រហ្មទណ្ឌ។ដូចនេះប្រសិនបើពិនិត្យលើថ្ងៃដែលសេចក្តីសម្រេចបានចូលជាស្ថាពរគិតពីថ្ងៃទី ១ ខែមករា ឆ្នាំ ២០១០រហូតដល់ ថ្ងៃប្រព្រឹត្តបទល្មើសថ្មីថ្ងៃទី ១១ខែ ឧសភា ឆ្នាំ២០១៨ គឺ មានរយៈពេលប្រមាណជា៨ឆ្នាំ ។ ដូចនេះអតិបរមានៃទោសដាក់ពន្ធនាគារចំពោះ បទទារុណកម្ម និងអំពើឃោរឃៅ ដែលជាបទល្មើសថ្មីត្រូវអនុវត្តទ្វេដង។ ដោយយោងតាមមាត្រា២១០នៃក្រមព្រហ្មទណ្ឌ ចំពោះទារុណកម្ម និងអំពើឃោរឃៅត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ឆ្នាំ ទៅ ១៥ ឆ្នាំ។ក៏ប៉ុន្តែដោយសារស្ថានភាពមិនរាងចាល តុលាការត្រូវគិតពិចារណាថាទោសដាក់ពន្ធនាគារដែលត្រូវអនុវត្តលើករណីរបស់លោក សៅ សម្រាប់បទទារុណកម្ម និងអំពើឃោរឃៅចាប់ពី ៧ឆ្នាំ (អប្បបរមានៃទោស) ដល់៣០ឆ្នាំ (អតិបរមានៃទោស)។

-ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋថ្មីមានរយៈពេលរហូតដល់ទៅ៣០ឆ្នាំ នោះអតិបរមានៃទោសដាក់ពន្ធនាគាររហូតអស់មួយជីវិត។

ឧទាហរណ៍៖ នៅក្នុងករណីខាងលើដដែល ក៏ប៉ុន្តែប្រសិនបើលោក សៅ បានប្រព្រឹត្តបទល្មើសដោយលោកបានប្រព្រឹត្ត បទល្មើសរំលោភសេពសន្ថវៈដោយបានបណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនា

សម្លាប់ ដោយយោងតាម មាត្រា២៤៤នៃក្រមព្រហ្មទណ្ឌ ដែលជាធម្មតាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ឆ្នាំ ទៅ ៣០ឆ្នាំ។ក៏ប៉ុន្តែចំពោះបទល្មើសដែលលោក ក បានប្រព្រឹត្តថ្មីនេះគឺស្ថិតក្នុងស្ថានភាពមិនរាងចាល ដូចនេះ តុលាការត្រូវតែផ្តន្ទាទោស សម្រាប់លោក សៅ គឺទោសដាក់ពន្ធនាគារពី ១៥ឆ្នាំ (អប្បបរមានៃទោស) ទៅដល់ ទោសដាក់ពន្ធនាគារអស់មួយជីវិត(អតិបរមានៃទោស)។

ខ.កាលបើបុគ្គលណាម្នាក់ត្រូវផ្តន្ទាទោសជាស្ថាពររួចហើយពីបទឧក្រិដ្ឋបុគ្គលនោះបានប្រព្រឹត្ត បទមជ្ឈិមថ្មីទៀត ក្នុងរយៈពេល៥ឆ្នាំ

ការមិនរាងចាលក្នុងករណីនេះអាចត្រូវបានអានុភាព លុះត្រាតែបុគ្គលណាម្នាក់ធ្លាប់ត្រូវបានតុលាការ សម្រេចផ្តន្ទាទោសពីបទឧក្រិដ្ឋក្រោយមកបុគ្គលនោះបានទៅប្រព្រឹត្តបទមជ្ឈិមថ្មីមួយទៀត នៅក្នុងរយៈពេល៥ ឆ្នាំ គឺគិតចាប់ពីពេលសេចក្តីសម្រេចផ្តន្ទាទោសលើកមុនបានចូលជាស្ថាពរ ។

-នោះអតិបរមានៃទោសដាក់ ពន្ធនាគារចំពោះ បទមជ្ឈិមដែលបានប្រព្រឹត្តថ្មីត្រូវតម្លើងទ្វេដង។[47] ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវបានផ្តន្ទាទោសទ្វេឡើងក៏ដោយ ក៏បទល្មើសថ្មីនេះគឺនៅតែ ជាបទមជ្ឈិមដដែល។[48]

ឧទាហរណ៍៖ លោកស្រី សោភា ត្រូវបានតុលាការសម្រេចផ្តន្ទាទោសពីបទលួចមានស្ថានទម្ងន់ទោស ដោយសារការប្រព្រឹត្តអំពើហិង្សាដោយយោងតាម មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌដែលជាបទឧក្រិដ្ឋ ដោយ តុលាការបានផ្តន្ទាទោសដាក់ពន្ធនាគារ៣ឆ្នាំ។បន្ទាប់មកសេចក្តីសម្រេចផ្តន្ទាទោសបានចូលជាស្ថាពរនៅថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ២០១៤។នៅថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៦ លោកស្រី សោភា ត្រូវបានដោះលែងឱ្យមានសេរីភាព។ក្រោយ មកទៀតនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ លោកស្រីសោភា បានប្រព្រឹត្តបទល្មើសថ្មីគឺ បទទទួលផលចោរកម្ម ដោយ យោងតាមមាត្រា៤០០ នៃក្រមព្រហ្មទណ្ឌត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ(អប្បបរមានៃទោស) ទៅ ៥ឆ្នាំ(អតិបរមានៃទោស)។ ប្រសិនគិតពីថ្ងៃនៃសេចក្តីសម្រេចផ្តន្ទាទោសមុនគឺនៅថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ២០១៤ រហូតដល់ថ្ងៃប្រព្រឹត្តបទល្មើសថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ មានរយៈពេលប្រមាណជា៣ឆ្នាំ។ដូចនេះការប្រព្រឹត្ត នេះគឺស្ថិតក្នុងករណីមិនរាងចាល នោះទោសដែលត្រូវផ្តន្ទាទោសលើលោកស្រី សោភា គឺទោសដាក់ពន្ធនាគារពី ២ឆ្នាំ(អប្បបរមានៃទោស) ទៅ ១០ឆ្នាំ(អតិបរមានៃទោស) និងពិន័យជាប្រាក់ពី ៤លានរៀល(អប្បបរមានៃទោស) ដល់ ១០លានរៀល(អតិបរមានៃទោស)។ បើទោះបីជាអតិបរមានៃទោសដាក់ពន្ធនាគារកើនដល់១០ឆ្នាំក៏ដោយក៏ បទល្មើសថ្មីនេះនៅតែជាបទមជ្ឈិមដដែល។

[47] យោងមាត្រា ៨៦ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[48] យោងមាត្រា ៨៦ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

គ.កាលបើបុគ្គលណាម្នាក់ត្រូវផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិមដោយត្រូវជាប់ពន្ធនាគារស្មើ ឬ លើសពី៣ឆ្នាំ ហើយ បុគ្គលនោះបានប្រព្រឹត្តបទឧក្រិដ្ឋថ្មីទៀតក្នុងរយៈពេល៥ឆ្នាំ

ជាដំបូងនៅពេលជនណាម្នាក់ធ្លាប់ត្រូវបានតុលាការផ្តន្ទាទោសជាស្ថាពររួចហើយ ចំពោះបទមជ្ឈិមដែលទោស នោះត្រូវទទួលរងដាក់ពន្ធនាគារស្មើ ឬលើសពី៣ឆ្នាំ ក្រោយមកជនដដែលនោះបានទៅប្រព្រឹត្តបទល្មើសថ្មីជាបទឧក្រិដ្ឋហើយគម្លាតរវាងសេចក្តីសម្រេចផ្តន្ទាទោសជាស្ថាពរលើកមុន និងការប្រព្រឹត្តបទល្មើសថ្មីគឺតិចជាង ឬស្មើនៅក្នុងរយៈពេល៥ឆ្នាំ។

ក្នុងករណីលក្ខខណ្ឌខាងលើត្រូវបានបំពេញ គេត្រូវពិនិត្យទៅលើអតិបរមានៃទោសដែលច្បាប់បានកំណត់ ចំពោះបទឧក្រិដ្ឋដែលទើបតែបានប្រព្រឹត្តជាថ្មី។

-ក្នុងករណីដែលអតិបរមានៃទោស ចំពោះបទល្មើសថ្មីមិនលើសពី ២០ឆ្នាំទេ នោះអតិបរមានៃទោសត្រូវឡើងទ្វេ ។

-ប្រសិនអតិបរមានៃទោសដាក់ពន្ធនាគារ ចំពោះបទឧក្រិដ្ឋថ្មីនេះមានរយៈពេល៣០ឆ្នាំ នោះអតិបរមានៃទោសដាក់ពន្ធនាគារអស់មួយជីវិត។[49]

ឧទាហរណ៍៖ លោក សៀ ត្រូវបានតុលាការសម្រេចផ្តន្ទាទោសឱ្យជាប់ពន្ធនាគារចំនួន ៤ឆ្នាំ ដោយបានប្រព្រឹត្តបទល្មើសគឺ បទបោះបង់អនីតិជន ដោយយោងតាម មាត្រា៣២១ នៃក្រមព្រហ្មទណ្ឌ។បន្ទាប់មកសេចក្តីសម្រេចផ្តន្ទាទោសបានចូលជាស្ថាពរនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧។ក្រោយមក លោក សៀ ត្រូវបានដោះលែងនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។ក្រោយពីបានដោះលែងមានសេរី លោក សៀ បានទៅប្រព្រឹត្តបទល្មើសថ្មីមួយទៀតគឺបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារកាត់អវៈយវៈ ឬ ពិការភាព គឺជាបទឧក្រិដ្ឋយោងតាម មាត្រា២២៣ នៃក្រមព្រហ្មទណ្ឌ ដែលបានប្រព្រឹត្តនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២១។ប្រសិនបើគិតចាប់ពី ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧នៃសេចក្តីសម្រេចផ្តន្ទាទោសរហូតដល់ថ្ងៃប្រព្រឹត្តបទល្មើសថ្មីទី១ខែមករា ឆ្នាំ២០២១មានរយៈពេលប្រមាណ ៤ឆ្នាំ។ហេតុនេះការប្រព្រឹត្តបទល្មើសគឺស្ថិតក្នុងករណីមិនរាងចាលនោះ ទោសដែលតុលាការផ្តន្ទាទោសសម្រាប់បទល្មើសថ្មីគឺទោសដាក់ពន្ធនាគារពី៥ឆ្នាំ (អប្បបរមានៃទោស) ទៅ ២០ឆ្នាំ (អតិបរមានៃទោស)។ក្នុងករណីប្រសិនបើ លោក សៀ បានប្រព្រឹត្តបទឃាតកម្មដោយប្រើថ្នាំពុល តាមមាត្រា២០១ នៃក្រមព្រហ្មទណ្ឌដែលជាបទឧក្រិដ្ឋ នោះទោសដែលតុលាការផ្តន្ទាទោសសម្រាប់បទល្មើសថ្មីនេះគឺទោសដាក់ពន្ធនាគារពី ១៥ឆ្នាំ ទៅ អស់មួយជីវិត។

ជាមួយគ្នានេះផងដែរ ប្រសិនបើការផ្តន្ទាទោសលើកមុន លោក សៀ ត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនគារចំនួន ១ឆ្នាំ ពីបទបោះបង់អនីតិជន ទោះបី លោក សៀ បានប្រព្រឹត្តបទឧក្រិដ្ឋជាថ្មីក៏ដោយ ក៏

[49] យោងតាមមាត្រា ៨៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

លោក សៀ មិនមែនស្ថិតក្នុងភាពមិនរាងចាល ក៏ព្រោះតែអំពើរបស់គាត់ មិនត្រូវតាមលក្ខខណ្ឌដែលបានកំណត់តាមច្បាប់។

ឃ.កាលបើបុគ្គលណាម្នាក់ត្រូវផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិមហើយ បុគ្គលនោះបានប្រព្រឹត្តបទមជ្ឈិមថ្មីទៀតក្នុងរយៈពេល៥ឆ្នាំ

លក្ខខណ្ឌដែលនាំឱ្យមានការមិនរាងចាល ក្នុងករណីនេះមានដូចជា៖

-ជនល្មើសធ្លាប់ត្រូវបានតុលាការសម្រេចផ្តន្ទាទោសជាស្ថាពរពីបទមជ្ឈិម

-ជនល្មើសបានប្រព្រឹត្តបទមជ្ឈិមដដែលជាថ្មីទៀត

-សេចក្តីសម្រេចផ្តន្ទាទោសជាស្ថាពរលើកមុននិងការប្រព្រឹត្តបទល្មើសថ្មី គឺមានរយៈពេលតិចជាង ឬស្មើនឹង៥ឆ្នាំ

ដើម្បីអាចចាត់ទុកថាជាការមិនរាងចាលបានក្នុងករណីនេះ ចាំបាច់ត្រូវពិនិត្យមើលថា ជនល្មើសបានប្រព្រឹត្ត បទមជ្ឈិមដដែល ដែលខុសប្លែកពីករណីផ្សេងទៀតនៃការមិនរាងចាលដូចការរៀបរាប់ខាងលើ ក៏ព្រោះតែក្នុងក្រមព្រហ្មទណ្ឌពុំបានតម្រូវឱ្យមានការប្រព្រឹត្តបទល្មើសដដែលនោះឡើយ។

-ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទមជ្ឈិមដែលបានប្រព្រឹត្តថ្មីនេះត្រូវតម្លើងទ្វេដង។[50]

ឧទាហរណ៍៖ លោកស្រី សុភី ត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ១ឆ្នាំ ពីបទលួច យោងតាម មាត្រា៣៥០ នៃក្រមព្រហ្មទណ្ឌ។បន្ទាប់មកសេចក្តីសម្រេចផ្តន្ទាទោសបានចូលជាស្ថាពរនៅថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១៩។ ក៏ប៉ុន្តែនៅថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០២០ លោកស្រី សុភី បានប្រព្រឹត្តបទល្មើសថ្មីមួយទៀត គឺ លោកស្រី បានឆបោកមិត្តរបស់គាត់យកបានម៉ូតូមួយគ្រឿង។នៅក្នុងករណីនេះ លោកស្រី សុភី បានប្រព្រឹត្តបទល្មើស ស្ថិតក្នុងស្ថានភាពមិនរាងចាលពីព្រោះតែបទល្មើសលួចដែលលោកស្រីបានប្រព្រឹត្តកន្លងមកជាបទមជ្ឈិម ដែលសេចក្តីសម្រេចផ្តន្ទាទោសបានចូលជាស្ថាពរទៅហើយ ក៏ប៉ុន្តែលោកស្រី បានប្រព្រឹត្តបទល្មើសថ្មីមួយទៀតគឺ បទឆបោក។ប្រសិនបើគិតពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោសមុនចូលជាស្ថាពរ គឺថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១៩ គឺមានរយៈពេលប្រមាណ ១ឆ្នាំជាង។

ជាធម្មតា យោងតាមមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ បទឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ (អប្បបរមានៃទោស) ទៅ ៣ឆ្នាំ(អតិបរមានៃទោស) និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៦លានរៀល។ប៉ុន្តែចំពោះករណីរបស់លោកស្រីសុភីគឺស្ថិតក្នុងស្ថានភាពមិនរាងចាល។

ដូចនេះទោសសម្រាប់បទល្មើសឆបោកគឺការដាក់ពន្ធនាគារពី ៦ខែ(អប្បបរមានៃទោស) ទៅ ៦ឆ្នាំ(អតិបរមានៃទោស) និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៦លានរៀល។

[50] យោងតាមមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

-កំណត់សម្គាល់ ដើម្បីពង្រីកវិសាលភាពនៃការអនុវត្តមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ និង មាត្រា៨៩ នៃក្រមព្រហ្មទណ្ឌគឺការប្រដូចបទល្មើស ដើម្បីបង្កើតឱ្យមានការមិនរាងចាល។ដើម្បីអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល បទលួច បទរំលោភ លើទំនុកចិត្ត និងបទឆបោក ត្រូវចាត់ទុកថាជាបទល្មើសដូចគ្នាដដែល។បទល្មើសទទួលផលចោរកម្ម ត្រូវប្រដូចជាបទល្មើសដែលជា ប្រភពនៃទ្រព្យសម្បត្តិដែលទទួលលាក់បំបាំង ។បទល្មើសសំអាតប្រាក់ ត្រូវប្រដូចជាបទល្មើសដែលការសំអាតប្រាក់នេះបានសម្រេច ។

-ត្រូវចាត់ទុកថាជាបទមជ្ឈិមដដែលចំពោះ បទលួច បទរំលោភលើទំនុកចិត្ត និង បទឆបោក។

ឧទាហរណ៍៖ ចំពោះបទល្មើសទី ១ ជាបទលួច បន្ទាប់មកបានប្រព្រឹត្តបទរំលោភលើទំនុកចិត្ត ក្នុងករណីនេះត្រូវបានចាត់ទុកថាជាបទមជ្ឈិមដដែល។

-ត្រូវចាត់ទុកថាជាបទមជ្ឈិមដដែល បទទទួលផលចោរកម្ម និងបទល្មើសដែលជាប្រភពនៃទ្រព្យសម្បត្តិទទួលលាក់បាំង។

ឧទាហរណ៍៖ ចំពោះបទល្មើសទី ១ ជាបទលួច បន្ទាប់មកបានប្រព្រឹត្តបទទទួលផលចោរកម្ម(ទទួលទិញវត្ថុពីជនដែលបានលួចទ្រព្យសម្បត្តិអ្នកដទៃ) ក្នុងករណីនេះត្រូវចាត់ទុកថាជាបទមជ្ឈិមដដែល។

-ត្រូវចាត់ទុកថាជាបទមជ្ឈិមដដែលចំពោះបទសំអាតប្រាក់និងបទល្មើសដែលការសំអាតប្រាក់នេះបានសម្រេច។

ឧទាហរណ៍ ៖ ចំពោះបទល្មើសទី ១ ជាបទលួចបន្ទាប់មកបានប្រព្រឹត្តបទសំអាតប្រាក់ (លាក់បាំងប្រភពទ្រព្យសម្បត្តិដែលបានមកពីការលួចទ្រព្យសម្បត្តិអ្នកដទៃ) ក្នុងករណីនេះត្រូវចាត់ទុកថាជាបទមជ្ឈិមដដែល។

### ៣.១.១.២ អានុភាពនៃការមិនរាងចាល

ការមិនរាងចាលមានអានុភាព នាំឱ្យមានការបន្ថែមទម្ងន់អតិបរមា នៃទោសដាក់ពន្ធនាគារចំពោះបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិម នៅក្នុងលក្ខខណ្ឌដែលមានចែងដោយក្រមព្រហ្មទណ្ឌ។ក្រៅពីការបន្ថែមទម្ងន់ទោសលើបទល្មើសដែលទើបតែបានប្រព្រឹត្តជាថ្មី ការមិនរាងចាលធ្វើឱ្យជនល្មើសបាត់បង់ឱកាសនឹងទទួលបាននូវវិធានការអនុគ្រោះផ្សេងៗពីតុលាការសម្រាប់ខ្លួន ដូចជាការដែលអាចព្យួរទោសជាដើម។ [51] ការមិនរាងចាលជាវិធានព្រហ្មទណ្ឌមួយដ៏សំខាន់សម្រាប់ទប់ស្កាត់កុំឱ្យបទល្មើសព្រហ្មទណ្ឌកើតមានជាថ្មី តាមរយៈការបន្ថែមទម្ងន់ទោសទៅលើបទល្មើសថ្មីប្រសិនបើការប្រព្រឹត្តនោះ ចូលក្នុងលក្ខខណ្ឌនៃការមិនរាងចាល។ចំណុចនេះគឺជាការគោលការណ៍ដ៏សំខាន់ ដើម្បីកាត់បន្ថយបទល្មើសក៏ដូចជាក្រើនរំលឹកដល់បុគ្គលគ្រប់រូបឱ្យមានការប្រុងប្រយ័ត្នចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត។ ម៉្យាងវិញទៀតចំពោះបុគ្គលដែលបានផ្តន្ទាទោសពីតុលាការរួចមកហើយ ជឿជាក់ថាលក្ខខណ្ឌនៃការមិនរាងចាលអាចធ្វើឱ្យបុគ្គលនោះ ហាក់មានការខ្លាចរអា ក៏ដូចជាមានការប្រយ័ត្ន មិនឱ្យមានបទល្មើសថ្មីកើតឡើងទៀតឡើយ។

[51] យោងតាមមាត្រា ១០៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ជាមួយគ្នានេះ សម្រាប់ជនល្មើសជាអនីតិជន ដោយអនុលោមតាមមាត្រា ១៦៣ នៃក្រមព្រហ្មទណ្ឌមិនអនុវត្តស្ដីពីការមិនរាងចាលចំពោះអនីតិជនទេ។បើទោះបីជាអនីតិជននោះបានប្រព្រឹត្តបទល្មើសដូចករណីនៃការមិនរាងដែលបានចែង ក្នុងក្រមព្រហ្មទណ្ឌក៏ដោយតុលាការមិនអាចបន្ថែមស្ថានទម្ងន់ទោសទៅលើអនីតិជននោះបានទេ។

**៣.១.២. ស្ថានទម្ងន់ទោសដោយឡែក**

ស្ថានទម្ងន់ទោសដោយឡែក គឺជាស្ថានទម្ងន់ទោសដែលត្រូវយកមកអនុវត្ត កាលបើច្បាប់បានចែងជំជាក់លាក់ចំពោះ បទល្មើសជាក់លាក់ណាមួយ។ចំពោះស្ថានទម្ងន់ទោសនេះមិនមែនមានតែចែងពីបទប្បញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាទេ។ជាក់ស្តែងច្បាប់ពិសេសផ្សេងៗទៀត ក៏មានចែងពីស្ថានទម្ងន់ទោសដោយឡែកយ៉ាងច្បាស់លាស់នេះ ដោយអាស្រ័យទៅតាមប្រភេទនៃបទល្មើសដែលជនល្មើសបានប្រព្រឹត្ត។ទាក់ទងនឹងស្ថានទម្ងន់ទោសនេះដែរក្រមព្រហ្មទណ្ឌ និង ច្បាប់ពិសេសបានកំណត់ដូចជា៖ ស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ (**៣.១.២.១**) ស្ថានទម្ងន់ទោសទាក់ទងនឹងចារី (**៣.១.២.២**) ស្ថានទម្ងន់ទោសទាក់ទងនឹងអំពើជាសត្យានុម័តនៃបទល្មើស (**៣.១.២.៣**) ស្ថានទម្ងន់ទោសដោយសារពហុបទល្មើស (**៣.១.២.៤**) និងស្ថានទម្ងន់ទោសផ្សេងៗទៀត (**៣.១.២.៥**)។

**៣.១.២.១.ស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ**

ស្ថានភាពរបស់ជនរងគ្រោះដែលច្បាប់ព្រហ្មទណ្ឌច្រើន យកមកធ្វើជាស្ថានទម្ងន់ទោសនៃបទល្មើសមានដូចជា៖ ស្ថានភាពទន់ខ្សោយពិសេសដោយមូលហេតុអាយុ(វ័យក្មេងពេក ឬវ័យចាស់ជរាពេក) ស្ថានភាពមានជំងឺស្ថានភាពមានពិការភាព ស្ថានភាពមានភគ៌(ស្ថានភាពនេះត្រូវបានឃើញដោយជាក់ស្តែងឬ កាលបើជនល្មើសបានដឹង) និងស្ថានភាពគុណភាពរបស់ជនរងគ្រោះ(សហព័ទ្ធ ឬអ្នករាជការសាធារណៈ)។

ឧទាហរណ៍៖ យោងតាមមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ បទឃាតកម្មត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី១០ឆ្នាំ ទៅ ១៥ឆ្នាំ។ក៏ប៉ុន្តែប្រសិនបើឃាតកម្មប្រព្រឹត្តលើបុគ្គលទន់ខ្សោយពិសេសដូចជាទារក នោះការផ្តន្ទាទោសត្រូវកើនឡើងដោយត្រូវដាក់ពន្ធនាគារពី១៥ឆ្នាំ ទៅ ៣០ឆ្នាំ យោងតាមមាត្រា២០២ នៃក្រមព្រហ្មទណ្ឌ។

ឧទាហរណ៍៖ យោងតាមមាត្រា២១៧នៃក្រមព្រហ្មទណ្ឌបទហិង្សាដោយចេតនាដោយតម្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២លានរៀល ទៅ៦លានរៀល។ក៏ប៉ុន្តែយោងតាមមាត្រា២២២នៃក្រមព្រហ្មទណ្ឌ អំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ ឬ អនីតិសង្វាសជន ដោយត្រូវផ្តន្ទាទោសដាក់ពី២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០លានរៀល គឺជាស្ថានទម្ងន់ទោសគុណភាពរបស់ជនរងគ្រោះគឺជាសហព័ទ្ធ ឬ អនីតិសង្វាសជន។

-កំណត់សម្គាល់ ប្រសិនបើយើងក្រឡេកមើលក្រមព្រហ្មទណ្ឌចាប់ពីមាត្រា១៩៩ដល់មាត្រា២០៦នៃក្រមព្រហ្មទណ្ឌ ចំពោះស្ថានទម្ងន់ទោសបទល្មើសទាក់ទងនឹងឃាតកម្មទៅលើសហព័ទ្ធគឺក្រមព្រហ្មទណ្ឌមិនបានចែងពីទេក៏ប៉ុន្តែតុលាការអាចផ្តល់ស្ថានទម្ងន់ទោសដោយពិចារណា ទៅលើគោលការណ៍ឯកត្តកម្មនៃទោសបាន។

### ៣.១.២.២.ស្ថានទម្ងន់ទោសទាក់ទងនឹងចារី

ស្ថានភាពរបស់ចារីដែលច្បាប់ព្រហ្មទណ្ឌច្រើនយកមកធ្វើជាស្ថានទម្ងន់ទោសនៃបទល្មើសដូចជា គុណភាពរបស់ចារីជាអ្នករាជការសាធារណៈ គុណភាពរបស់ចារីជាសហព័ទ្ធ ជាអនីតិសង្វាស គុណភាពរបស់ចារីជាជនដែលមានអំណាចលើជនរងគ្រោះ ជាបុព្វញាតិ ឬ បច្ឆាញាតិរបស់ជនរងគ្រោះ។បន្ថែមលើសពីនេះស្ថានទម្ងន់ទោសទាក់ទងនឹងចារីនេះច្បាប់ព្រហ្មទណ្ឌ ក៏បានចែងពីចំនួននៃជនប្រព្រឹត្តបទល្មើសគឺការប្រព្រឹត្តបទល្មើសដោយមានគ្នាច្រើនក្នុងឋានៈជា ចារី សហចារី អ្នកសមគំនិត និងអ្នកផ្តើមគំនិត។

ឧទាហរណ៍៖ យោងតាមមាត្រា២២១នៃក្រមព្រហ្មទណ្ឌ បទហិង្សាដោយចេតនាប្រព្រឹត្តដោយអ្នករាជការសាធារណៈ ក្នុងក្របខ័ណ្ឌនៃមុខងារ ឬក្នុងឱកាសបំពេញមុខងាររបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំ ទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ១០លានរៀល។

ឧទាហរណ៍៖យោងតាមមាត្រា២០៤នៃក្រមព្រហ្មទណ្ឌបទឃាតកម្មប្រព្រឹត្តដោយអ្នករាជការសាធាណៈ ឃាតកម្មដែលប្រព្រឹត្តដោយ អ្នករាជការសាធារណៈ ក្នុងក្របខ័ណ្ឌនៃមុខងារ ឬក្នុងឱកាសបំពេញមុខងាររបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥ឆ្នាំ ទៅ៣០ឆ្នាំ។

ឧទាហរណ៍៖ យោងតាមមាត្រា២៤០ នៃក្រមព្រហ្មទណ្ឌស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬទាក់ទងនឹងជនល្មើសបទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ឆ្នាំ ទៅ ១៥ឆ្នាំ កាលបើបទល្មើសនេះប្រព្រឹត្តឡើងដោយបុគ្គលច្រើនរូប ដែលប្រព្រឹត្តឡើង ក្នុងឋានៈជាចារី សហចារី អ្នកសមគំនិត ឬអ្នកផ្តើមគំនិត។

### ៣.១.២.៣.ស្ថានទម្ងន់ទោសទាក់ទងនឹងអំពើជាសត្យានុម័តនៃបទល្មើស

ស្ថានទម្ងន់ទោសទាក់ទងនឹងអំពើនិងអំពើជាសត្យានុម័តនៃបទល្មើសមានដូចជា៖

-ស្ថានទម្ងន់ទោសទាក់ទងនឹងក្រុមមានការចាត់តាំង

យោងតាមមាត្រា ៧៧ នៃក្រមព្រហ្មទណ្ឌ ក្រុមមានការចាត់ជាការប្រមូលផ្តុំដែលបានបង្កើតឡើង ឬជាសន្និដ្ឋិភាព។ដើម្បីរៀបចំឬប្រព្រឹត្តបទល្មើសមួយឬច្រើនការរួមគ្នាជាក្រុម ឬសន្និដ្ឋិភាពនេះមិនមែនធ្វើឡើងដើម្បីគ្រាន់តែបង្ហាញអំពីគំនិតរួមគ្នាប៉ុណ្ណោះទេប៉ុន្តែធ្វើឡើងដោយមានការព្រមព្រៀង ឬដោយត្រូវគ្នាដើម្បីប្រព្រឹត្តបទល្មើស។សកម្មភាពនេះ ត្រូវបានចាត់ទុកថាជាការរៀបចំអនុវត្តបទល្មើស ការរៀបចំអនុវត្តនេះ ថ្វីត្បិតតែមិន

ទាន់ចូលដំណាក់កាលនៃការអនុវត្តបទល្មើស ក៏ប៉ុន្តែវាក៏មិនមែនជាដំណាក់កាលធម្មតានៃការសម្រេចចិត្តបទល្មើសដែរ ដោយហេតុថាការរៀបចំនេះបានស្តែងចេញជាសកម្មភាពជាក់ស្តែង ឬអំពើជាសម្ភារៈដែលអាចនាំទៅដល់ការកំណត់រូបរាងច្បាស់លាស់។

ឧទាហរណ៍៖ យោងតាមមាត្រា៤០៥ នៃក្រមព្រហ្មទណ្ឌ ការសំអាតប្រាក់ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យពី៤លានរៀល រហូតដល់តម្លៃមូលនិធិដែលជាកម្មវត្ថុនៃការសំអាតប្រាក់។ ប្រសិនបើបទល្មើសនេះ ប្រព្រឹត្តដោយមានការចាត់តាំង នោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ មាត្រា៤០៦ នៃក្រមព្រហ្មទណ្ឌ។

-ស្ថានទម្ងន់ទោសទាក់ទងនឹងការកាប់គាស់ទម្លុះទម្លាយ

យោងមាត្រា ៧៩ នៃក្រមព្រហ្មទណ្ឌ ការកាប់គាស់ទម្លុះទម្លាយជាអំពើបង្ខំធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញគ្រឿងបិទទ្វារ ឬរបង ទោះបីមានប្រភេទយ៉ាងណាក៏ដោយ។

ឧទាហរណ៍៖ យោងតាមមាត្រា៣៥៦នៃក្រមព្រហ្មទណ្ឌ ការលួចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ខែ ទៅ៣ឆ្នាំ និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៦លានរៀល។ ក៏ប៉ុន្តែប្រសិនបើការលួចប្រព្រឹត្តទៅដោយមានការកាប់ទម្លុះទម្លាយនោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ឆ្នាំ ទៅ ១០ឆ្នាំ មាត្រា៣៥៧នៃក្រមព្រហ្មទណ្ឌ។

-ស្ថានទម្ងន់ទោសទាក់ទងនឹងការឆ្លោះរបងចូល

យោងមាត្រា៨០ នៃក្រមព្រហ្មទណ្ឌ ការឆ្លោះរបងចូលជាអំពើចូលទៅក្នុងទីកន្លែងណាមួយដោយឆ្លងរបង ឬដោយចូលតាមទ្វារ ឬ បង្អួចដែលមិនមែនសម្រាប់ធ្វើជាផ្លូវចូលទេ។ក្នុងករណីនេះក្រមព្រហ្មទណ្ឌពុំមានបទប្បញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌដែលយកធ្វើជាស្ថានទម្ងន់ទោសនៃបទល្មើសណាមួយជាក់លាក់នោះទេ។

-ស្ថានទម្ងន់ទោសទាក់ទងនឹងការប្រើប្រាស់អាវុធ

យោងមាត្រា៨១ នៃក្រមព្រហ្មទណ្ឌ អាវុធគឺជាវត្ថុទាំងឡាយដែលធ្វើឡើងដើម្បីសម្លាប់ឬធ្វើឱ្យមានរបួស។

ឧទាហរណ៍៖ យោងតាមមាត្រា២៤៦ នៃក្រមព្រហ្មទណ្ឌ បទប្រទូស្តកេរខ្មាសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២លានរៀល ទៅ ៦លានរៀល។ ប្រសិនបើបទល្មើសនេះប្រព្រឹត្តដោយការប្រើប្រាស់អាវុធ នោះការផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី៤លានរៀល ទៅ១០លានរៀល យោងតាមមាត្រា២៤៧ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ។

ឧទាហរណ៍៖ យោងតាមមាត្រា៣៦៣ នៃក្រមព្រហ្មទណ្ឌបទកំហែងយកត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី៤លានរៀល ទៅ ១០លានរៀល។ប្រសិនបើបទល្មើសនេះប្រព្រឹត្ត

ដោយសារការប្រើប្រាស់អាវុធ ឬ ដោយគំរាមកំហែងនឹងអាវុធ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ឆ្នាំ ទៅ ១៥ឆ្នាំ យោងតាមមាត្រា៣៦៦ នៃក្រមព្រហ្មទណ្ឌ។

ឧទាហរណ៍៖ យោងតាមមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌបទរំលោភសេពសន្ថវៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ។ប្រសិនបើបទល្មើសនេះប្រព្រឹត្តដោយការប្រើប្រាស់អាវុធនោះការផ្តន្ទាទោសដាក់ពន្ធនាគារពីឆ្នាំ ៧ ឆ្នាំ ទៅ ១៥ឆ្នាំ យោងតាមមាត្រា២៤០ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ។

-ស្ថានទម្ងន់ទោសទាក់ទងនឹងការពួនស្ទាក់

យោងតាមមាត្រា៨២ នៃក្រមព្រហ្មទណ្ឌ ការពួនស្ទាក់គឺជាអំពើឃ្លាំចាំជនរងគ្រោះនៅទីកន្លែងណាមួយក្នុងរយៈពេលមួយរយៈដើម្បីប្រព្រឹត្តបទល្មើស។

ឧទាហរណ៍៖ បទឃាតកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ យោងតាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។ ក្នុងករណីដែលអំពើសម្លាប់មនុស្សបានប្រព្រឹត្តដោយមានការពួនស្ទាក់យោងតាមមាត្រា ២០០នៃក្រមព្រហ្មទណ្ឌនោះការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

-ស្ថានទម្ងន់ទោសទាក់ទងនឹងការគិតទុកជាមុន

យោងតាមមាត្រា ៧៨ នៃក្រមព្រហ្មទណ្ឌ បានផ្តល់និយមន័យថា ការគិតទុកជាមុនជាគម្រោងដែលបង្កើតឡើងមុនសកម្មភាពប្រព្រឹត្តបទល្មើស។ ព្រោះតែចារីបានគិតគូរទុកជាមុនពីគម្រោងក្នុងការប្រព្រឹត្តបទល្មើសនោះ ទើបបានប្រព្រឹត្តជាក្រោយ។

ឧទាហរណ៍៖ បទហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២លានរៀល ទៅ ៦លានរៀល យោងតាមមាត្រា ២១៧នៃក្រមព្រហ្មទណ្ឌ។ ក៏ប៉ុន្តែប្រសិនបើ ក្នុងករណីដែលមានការគិតទុកជាមុន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០ លានរៀល។

### ៣.១.២.៤.ស្ថានទម្ងន់ទោសដោយសារពហុបទល្មើស

ជាធម្មតាប្រសិនបើចារីបានប្រព្រឹត្តបទល្មើសច្រើនក្នុងពេលតែមួយ ឬជាបន្តបន្ទាប់ស្ថានភាពនេះអាចបង្កើតបានជាបទល្មើសត្រួតគ្នា ឬ ស្ថានភាពមិនរាងចាល(កាលបើលក្ខខណ្ឌដែលច្បាប់បានចែងបានបំពេញ)។ ប៉ុន្តែករណីខ្លះ ក្រមព្រហ្មទណ្ឌ យកស្ថានភាពនៃការប្រព្រឹត្តពហុបទល្មើសមកធ្វើជាស្ថានទម្ងន់ទោសវិញ។ ជាក់ស្តែងក្រមព្រហទណ្ឌយកស្ថានភាពនៃការប្រព្រឹត្ត ដែលបានបណ្តាលឱ្យជនរងគ្រោះស្លាប់បាត់បង់ជីវិត ឬក៏បណ្តាលឱ្យមានការកាត់អវៈយវៈ ឬ បង្កឱ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះឬ ក៏ករណីដែលបទល្មើសប្រព្រឹត្តឡើងមុនពេល ក្នុងពេលឬក្រោយពេលប្រព្រឹត្តអំពើទារុណកម្ម ឬអំពើឃោរឃៅមកធ្វើជាស្ថានទម្ងន់ទោសសម្រាប់បទល្មើសជាច្រើន ដូចជា បទរំលោភសេពសន្ថវៈ បទលួច ជាដើម។

ឧទាហរណ៍៖ យោងតាមមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌបទរំលោភសេពសន្ថវៈ គឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ។ក៏ប៉ុន្តែប្រសិនបើបទល្មើសនេះបានប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលប្រព្រឹត្តអំពើទារុណកម្ម ឬអំពើឃោរឃៅបទរំលោភសេពសន្ថវៈគឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ ៣០ឆ្នាំ យោងតាមមាត្រា២៤៣ នៃក្រមព្រហ្មទណ្ឌ។

ឧទាហរណ៍៖ យោងតាមមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៦លានរៀល។ក៏ប៉ុន្តែប្រសិនបើបទល្មើសនេះបានប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលប្រព្រឹត្ត ដោយសារការធ្វើទារុណកម្ម ឬ អំពើឃោរឃៅបទលួចគឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ឆ្នាំ ទៅ ៣០ឆ្នាំ យោងតាមមាត្រា៣៥៩ នៃក្រមព្រហ្មទណ្ឌ។

បន្ថែមពីនេះទៀតការធ្វើទារុណកម្មនិងអំពើឃោរឃៅទៅលើជនរងគ្រោះក្នុងគោលបំណងណាមួយដែលខ្លួនចង់បាន។ជាធម្មតាការធ្វើទារុណកម្ម និងអំពើឃោរឃៅលើជនរងគ្រោះ មិនធ្វើឱ្យជនរងគ្រោះស្លាប់ភ្លាមៗទេនៅពេលដែលបានប្រព្រឹត្តនេះ។

### ៣.១.២.៥.ស្ថានទម្ងន់ទោសផ្សេងៗទៀត

នៅមានករណីនៃស្ថានភាពផ្សេងៗទៀត ដែលច្បាប់ព្រហ្មទណ្ឌ និង ច្បាប់ពិសេសអាចយកមកកំណត់ធ្វើជាស្ថានទម្ងន់ទោសបានដែររួមមានជាអាទិ៍៖

-ស្ថានទម្ងន់ទោសទាក់ទងនឹងគោលដៅនៃការប្រព្រឹត្តបទល្មើស

ឧទាហរណ៍៖ យោងតាមមាត្រា២៥៣ នៃក្រមព្រហ្មទណ្ឌចែងពីបទចាប់ ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ ដែលតម្រូវឱ្យមានការផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ១០ឆ្នាំ គឺ អាស្រ័យទៅតាមថិរវេលានៃការឃុំឃាំង។យោងតាមមាត្រា២៥៤ នៃក្រមព្រហ្មទណ្ឌតម្រូវឱ្យផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ឆ្នាំ ទៅ ៣០ឆ្នាំ ប្រសិនបើការចាប់ ឃុំឃាំង ឬបង្ខាំងដោយខុសច្បាប់បានធ្វើឡើងក្នុងគោលដៅជំរិតយកទ្រព្យសម្បត្តិ ឬឱ្យបំពេញលក្ខខណ្ឌអ្វី។ក៏ប៉ុន្តែប្រសិនបើ បុគ្គលដែលចាប់ឃុំឃាំង ឬ បង្ខាំងជនដទៃ ដោយគ្មានអំណាចតាមផ្លូវច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត តាមមាត្រា២២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងករណី ប្រព្រឹត្តក្នុងគោលដៅជំរិតយកប្រាក់។

-ស្ថានទម្ងន់ទោសទាក់ទងនឹងកម្មវត្ថុនៃបទល្មើស

ឧទាហរណ៍៖ យោងតាម មាត្រា៣៦៤ នៃក្រមព្រហ្មទណ្ឌ ការកំហែងយកត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ២ឆ្នាំ ដល់ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ១០លានរៀល។ប្រសិនបើការកំហែងយកសារធាតុនុយក្លេអ៊ែរវិញនោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ២០ឆ្នាំ តាមមាត្រា ៤៣ នៃច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម។ច្បាប់ពិសេសក៏បានកំណត់ស្ថានទម្ងន់ទោសទាក់ទង់នឹងប្រភេទកម្មវត្ថុនៃបទល្មើស។

## ៣.២.ស្ថានសម្រាលទោស

អនុលោមតាមមាត្រា៩៣ នៃក្រមព្រហ្មទណ្ឌបានចែងថាកាលណាកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ តុលាការអាចសម្រេចឱ្យជនល្មើសបានទទួលនូវស្ថានសម្រាលទោស។ ស្ថានសម្រាលទោសអាចត្រូវផ្តល់ឱ្យជនជាប់ចោទបានដែរ ទោះបីជាជននោះ ត្រូវបានប្រកាសថា ស្ថិតនៅក្នុងភាពមិនរាងចាលក៏ដោយ។

ដោយអនុលោមតាមខ្លឹមសារនៃមាត្រា៩៣ នៃក្រមព្រហ្មទណ្ឌប្រសិនបើពិចារណាចំពោះស្ថានភាពនៃស្ថានសម្រាលទោសក៏បានបែងចែកជាពីរគឺ ស្ថានសម្រាលទោសទូទៅ(**៣.២.១**)គឺជាស្ថានសម្រាលទោសដែលអនុវត្តលើគ្រប់បទល្មើសទាំងអស់ និង ស្ថានសម្រាលទោសដោយឡែក(**៣.២.២**)គឺជាស្ថានសម្រាលទោសដែលអនុវត្តលើគ្រប់បទល្មើសជាក់លាក់ណាមួយដែលបទប្បញ្ញត្តិនៃច្បាប់បានចែង ។[52]

### ៣.២.១. ស្ថានសម្រាលទោសទូទៅ

យោងតាមមាត្រា៩៣ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌកាលណាកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ តុលាការអាចសម្រេចឱ្យជនល្មើសបានទទួលនូវស្ថានសម្រាលទោស។ ស្ថានសម្រាលទោសអាចត្រូវផ្តល់ឱ្យជនជាប់ចោទបានដែរទោះបីជាជននោះត្រូវបានប្រកាសថាស្ថិតនៅក្នុង ភាពការរាងចាលក៏ដោយ។

ស្ថានសម្រាលទោសទូទៅត្រង់មាត្រា៩៣ នៃក្រមព្រហ្មទណ្ឌច្បាប់មិនបានផ្តល់និយមន័យជាក់លាក់កាលណាកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទគឺទុកលទ្ធភាពជាពិសេសឱ្យតុលាការពិចារណា ដើម្បីថ្លឹងថ្លែងពិចារណាក្នុងការផ្តល់ស្ថានសម្រាលទោស ឬមិនផ្តល់ស្ថានសម្រាលទោសក្នុងករណីជនល្មើសបានប្រព្រឹត្តបទល្មើសគឺអាស្រ័យលើតុលាការពិចារណា។បន្ថែមពីនៅត្រង់មាត្រា ៣១ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌជាឧទាហរណ៍មួយនៃស្ថានភាពដែលតម្រូវឱ្យតុលាការយកមកគិតគូរពិចារណាក្នុងការកំណត់ទោស។ ក្នុងករណីនៃវិបល្លាសស្មារតីដែលបានបន្ថយការយល់ដឹងការទទួលខុសត្រូវរបស់ជនជាប់ចោទគឺជាមូលហេតុមួយដែលតុលាការត្រូវតែពិចារណា ក្នុងការផ្តល់ស្ថានសម្រាលទោសនៃជនជាប់ចោទ។ ត្រង់ចំណុចនេះផងដែរ រវាងស្ថានសម្រាលទោស និងគោលការណ៍ឯកត្តកម្មនៃទោសក៏ព្រោះតែគោលការណ៍ឯកត្តកម្មនៃទោសតុលាការអាចធ្វើការប្រកាសទោសដោយផ្អែកទៅតាមកាលៈទេសៈ នៃការប្រព្រឹត្តបទល្មើស និងទៅតាមបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ក៏ប៉ុន្តែការប្រកាសទោសនេះស្ថិតនៅក្នុងទំហំអតិបរមា និងអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់បទល្មើស។

[52] សៀវភៅសិក្សានីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ២០២២ ដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ទំព័រ ៤៣២

ដូចនេះតុលាការអាចពិចារណាបានថាដើម្បីកំណត់ពី ស្ថានសម្រាលទោសទូទៅគឺតុលាការត្រូវពិចារណាលើពីរចំណុចទី១ គឺ កាលៈទេសៈនៃបទល្មើស(**៣.២.១.១**) និង ចំណុចទី២ គឺកាលៈទេសៈនៃជនជាប់ចោទ(**៣.២.១.២**)។

**៣.២.១.១.កាលៈទេសៈនៃបទល្មើស**

ក្រមព្រហ្មទណ្ឌមិនបានផ្តល់និយមន័យនៃពាក្យកាលៈទេសៈនៃបទល្មើស នេះទេដោយទុកលទ្ធភាពជាពិសេសឱ្យតុលាការពិចារណាទៅតាមករណីជាក់ស្តែងនីមួយៗ។ ក៏ប៉ុន្តែបទល្មើសគឺបានចេញជាសកម្មភាពដូចជា ប្រព្រឹត្តបទល្មើស ដោយសារតែមានការរុញច្រាន និងអំពើបង្កហេតុពីជនរងគ្រោះជាមុន ប្រព្រឹត្តបទល្មើស នៅក្នុងស្ថានភាពនៃការការពារខ្លួនហួសព្រំដែនដែលបានកំណត់ដោយច្បាប់ ប្រព្រឹត្តបទល្មើស ដោយសារត្រូវការប្រាក់ដើម្បីយកទៅបង់ថ្លៃព្យាបាលគ្រួសារដែលមានជំងឺ និងចាស់ជរាជាដើម និងស្ថានភាពជាច្រើនដែលតុលាការអាចពិចារណាដើម្បីផ្តល់ស្ថានសម្រាលទោស។

ឧទាហរណ៍៖ ជនជាប់ចោទ បានប្រព្រឹត្តបទល្មើសគឺបទលួចប្រាក់ ឬ លួចយកវត្ថុមានតម្លៃយកទៅលក់។ ក្នុងគោលបំណងយកប្រាក់ដែលបានពីបទល្មើសនោះដោយសារត្រូវការប្រាក់ដើម្បីយកទៅព្យាបាលបង់ថ្លៃវះកាត់ជំងឺរបស់គាត់។

ឧទាហរណ៍៖ លោកចន្ទ បានវាយទៅលើលោក សុខ ដោយកណ្តាប់ដៃ បន្ទាប់មកលោក សុខ បានតបតដោយប្រើកាំបិតចាក់ទៅលើលោកចន្ទបណ្តាលឱ្យហូរឈាមរងរបួសធ្ងន់។ ចំពោះស្ថានភាពបែបនេះគឺជាការប្រព្រឹត្តបទល្មើស ដោយសារតែមានការបង្កហេតុពីជនរងគ្រោះមុន។

សរុបជារួមមកចំពោះស្ថានភាពបែបនេះគឺមានករណីជាច្រើនទៀតដូចជាជនជាប់ចោទប្រព្រឹត្តបទល្មើស ស្ថានភាពដូចបរិយាយខាងលើនេះអាស្រ័យលើតុលាការជាអ្នកពិចារណាពីស្ថានភាពដែលជនជាប់ចោទ បានប្រព្រឹត្តបទល្មើសក៏ព្រោះតែពុំមាននិយមន័យពីបទប្បញ្ញត្តិអំពីបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទឡើយ។

**៣.២.១.២.បុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ**

ក្រមព្រហ្មទណ្ឌមិនបានផ្តល់និយមន័យ នៃពាក្យបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទនេះទេដោយទុកលទ្ធភាពជាពិសេសឱ្យតុលាការពិចារណាទៅតាមករណីជាក់ស្តែងនីមួយៗ។ ក៏ប៉ុន្តែចំពោះករណីនេះតុលាការអាចពិចារណាទៅលើ ជនជាប់ចោទមានវ័យក្មេងនៅឡើយ ជនជាប់ចោទធ្លាប់មានប្រវត្តិដែលទទួលរងនូវអំពើហិង្សាក្នុងគ្រួសារ កាលនៅវ័យកុមារ។ ជនជាប់ចោទបានសងការខូចខាងដល់ជនរងគ្រោះ និងសម្តែងការសោកស្តាយនូវអំពើរបស់ខ្លួន ជនជាប់ចោទទើបប្រព្រឹត្តបទល្មើសជាលើកដំបូង ជនជាប់ចោទប្រព្រឹត្តបទល្មើសដោយសារមានវិបត្តិផ្នែកស្មារតីដែលកាត់បន្ថយការយល់ដឹងខុសត្រូវនិងស្ថានភាពជាច្រើនទៀតដែល តុលាការអាពិចារណាដើម្បីផ្តល់ស្ថានសម្រាលទោស។

ឧទាហរណ៍៖ ជនជាប់ចោទ មានអាយុ១៥ឆ្នាំ បានប្រព្រឹត្តបទល្មើសលួចដោយសារការប្រព្រឹត្តអំពើហិង្សា តាមមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌក៏ព្រោះតែចង់បានប្រាក់មកទិញកង់សម្រាប់ជិះទៅសាលារៀន។ បទល្មើសនេះប្រព្រឹត្តដោយជនល្មើសមានវ័យក្មេងពេក ក៏ព្រោះតែជនជាប់ចោទ មានចំណេះដឹងនៅមានកម្រិត។ ចំពោះចំនុចនេះគឺជាការសំខាន់គួរតែស្រាវជ្រាវពី កុមារភាពនៃជនល្មើសក្នុងគ្រួសារបណ្តាលមកពីអំពើហិង្សាក្នុងគ្រួសារ។

ឧទាហរណ៍៖ ជនជាប់ចោទ បានប្រព្រឹត្តបទល្មើសបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់អ្នកជិតខាងរបស់ខ្លួន ព្រោះតែទាស់ពាក្យសម្តីជាមួយគ្នា។ក៏ប៉ុន្តែក្រោយមក ជនជាប់ចោទ ក៏បានចេញសំណងការខូចខាត សារភាព និងសុំទោសពីទោសកំហុសដែលបានប្រព្រឹត្តលើអ្នកជិតខាងរបស់គាត់។ ចំពោះស្ថានភាពនេះជនជាប់ចោទបានសារភាពពីទោសកំហុសរបស់គាត់ សងការខូចខាត និងសម្តែងការសោកស្តាយនូវអំពើរបស់ខ្លួន។

ឧទាហរណ៍៖ ជនជាប់ចោទ បានជិះម៉ូតូហើយបានឆក់កាបូបរបស់ ជនរងគ្រោះ ក្នុងពេលកំពុងដើរតាមផ្លូវ។ បន្ទាប់ពីឆក់បានកាបូបហើយក៏ដួលម៉ូតូស្រាប់តែត្រូវបានគេក្របួចបានក៏ព្រោះតែជនជាប់ចោទ មិនធ្លាប់បានប្រព្រឹត្តបទល្មើសពីមុនមក ទើបតែលើកទីមួយក៏ព្រោះដោយសារជាប់បំណុល និងគ្មានការងារប្រកបទើបសម្រេចចិត្តប្រព្រឹត្តអំពើបែបនេះ។ចំពោះស្ថានភាពបែបនេះជនជាប់ចោទទើបប្រព្រឹត្តបទល្មើសជាលើកដំបូង។

សរុបជារួមមកចំពោះស្ថានភាពបែបនេះគឺមានករណីជាច្រើនទៀតដូចជា ជនជាប់ចោទប្រព្រឹត្តបទល្មើសដោយសារមានវិបត្តិផ្នែកស្មារតីដែលបន្ថយការយល់ដឹងខុសត្រូវ ជនជាប់ចោទធ្លាប់មានប្រវត្តិដែលទទួលរងនូវអំពើហិង្សាក្នុងគ្រួសារ។ល។ ស្ថានភាពដូចបរិយាយខាងលើនេះអាស្រ័យលើតុលាការជាអ្នកពិចារណាពីស្ថានភាពដែលជនជាប់ចោទ បានប្រពឹត្តបទល្មើស ក៏ព្រោះតែពុំមាននិយមន័យនិងបទប្បញ្ញត្តិអំពីបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទឡើយ។

យោងតាមគោលការណ៍ឯកត្តកម្មនៃទោសគឺតុលាការប្រកាសទោសក្នុងព្រំដែនមិនឱ្យលើសពីអតិបរមានៃទោស ឬក្រោមអប្បបរមានៃទោសទេក្នុងបទប្បញ្ញត្តិនៃមាត្រា។ផ្ទុយទៅវិញ ប្រសិនបើតុលាការបានរកឃើញថាបទល្មើសដែលបានប្រព្រឹត្តមានលក្ខណៈពិសេសគឺកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈនៃជនជាប់ចោទ តុលាការអាចផ្តន្ទាទោសដោយបន្ថយអប្បបរមានៃទោសតាមករណីដូចមានចែងក្នុងមាត្រា ៩៤ និង មាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌ ដូចខាងក្រោម៖

ក.ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី១០ឆ្នាំ អប្បបរមានៃទោសនេះត្រូវបន្ថយមកត្រឹម២ឆ្នាំ

ឧទាហរណ៍៖ ជនជាប់ចោទបានប្រព្រឹត្តបទល្មើសគឺបទឃាតកម្ម មាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ ផ្តន្ទាទោសដាក់ពន្ធនាគារពី១០ឆ្នាំ (អប្បបរមានៃទោស) ទៅ ១៥ឆ្នាំ(អតិបរមានៃទោស) ។នៅក្នុងករណីដែលតុលាការ

សម្រេចផ្តល់ស្ថានសម្រាលទោសឱ្យជនជាប់ជោទ នោះអប្បបរមានៃទោស និងអតិបរមានៃទោសសម្រាប់បទឃាតកម្ម ដែលត្រូវអនុវត្តចំពោះជនជាប់ចោទរូបនេះគឺដាក់ពន្ធនាគារពី ២ឆ្នាំ(អប្បបរមានៃទោស) ទៅ១៥ឆ្នាំ(អតិបរមានៃទោសគឺនៅដដែល)។

ខ.ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី៥ ហើយតិចជាង១០ឆ្នាំអប្បបរមានៃទោសនេះត្រូវបន្ថយមកត្រឹម១ឆ្នាំ

ឧទាហរណ៍៖ ជនជាប់ចោទបានប្រព្រឹត្តបទល្មើសគឺបទកំហែងយកមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ តាមមាត្រា៣៦៥ នៃក្រមព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ(អប្បបរមានៃទោស) ទៅ ១០ឆ្នាំ(អតិបរមានៃទោស)។ នៅក្នុងករណីដែលតុលាការសម្រេចផ្តល់ស្ថានសម្រាលទោសឱ្យជនជាប់ចោទនោះ អប្បបរមា និង អតិបរមានៃទោសសម្រាប់បទកំហែងយកមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះដែលត្រូវអនុវត្តចំពោះជនជាប់ចោទគឺ ទោសដាក់ពន្ធនាគារពី ១ឆ្នាំ (អប្បបរមានៃទោស) ទៅ ១០ឆ្នាំ (អតិបរមានៃទោសគឺនៅដដែល)។

គ.ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី២ឆ្នាំហើយតិចជាង៥ឆ្នាំ អប្បបរមានៃទោសត្រូវបន្ថយមកត្រឹម៦ខែ

ឧទាហរណ៍៖ ជនជាប់ចោទបានប្រព្រឹត្តបទល្មើសគឺបទសញ្ចារកម្ម មាត្រា២៨៤ នៃក្រមព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ(អប្បបរមានៃទោស) ទៅ ៥ឆ្នាំ(អតិបរមានៃទោស)។នៅក្នុងករណីដែលតុលាការសម្រេចផ្តល់ស្ថានសម្រាលទោសឱ្យជនជាប់ចោទនោះ អប្បបរមា និងអតិបរមានៃទោសសម្រាប់ បទសញ្ចារកម្ម ដែលត្រូវអនុវត្តចំពោះជនជាប់ចោទគឺ ទោសដាក់ពន្ធនាគារពី ៦ខែ(អប្បបរមានៃទោស) ទៅ ៥ឆ្នាំ(អតិបរមានៃទោសនៅដដែល)។

ឃ.ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី៦ថ្ងៃហើយតិចជាង២ឆ្នាំ អប្បបរមានៃទោសត្រូវបន្ថយមកត្រឹម១ថ្ងៃ

ឧទាហរណ៍៖ ជនជាប់ចោទបានប្រព្រឹត្តបទល្មើសគឺបទឆបោកមាត្រា៣៧៨នៃក្រមព្រហ្មទណ្ឌត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ(អប្បបរមានៃទោស) ទៅ ៣ឆ្នាំ(អតិបរមានៃទោស)។នៅក្នុងករណីដែលតុលាការសម្រេចផ្តល់ស្ថានសម្រាលទោសឱ្យជនជាប់ចោទនោះ អប្បបរមា និងអតិបរមានៃទោសសម្រាប់ បទឆបោកដែលត្រូវអនុវត្តចំពោះជនជាប់ចោទគឺ ទោសដាក់ពន្ធនាការពី ១ថ្ងៃ(អប្បបរមានៃទោស) ទៅ ៣ឆ្នាំ(អតិបរមានៃទោសគឺនៅដដែល)។

ង.អប្បបរមានៃទោសពិន័យត្រូវបន្ថយត្រឹមពាក់កណ្ដាល

ឧទាហរណ៍៖ ជនជាប់ចោទបានប្រព្រឹត្តបទល្មើសគឺបទឆបោកមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ខែ(អប្បបរមានៃទោស) ទៅ ៣ឆ្នាំ(អតិបរមានៃទោស) និង ពិន័យជាប្រាក់ពី ១លានរៀល (អប្បបរមានៃទោស) ទៅ ៦លានរៀល(អតិបរមានៃទោស)។នៅក្នុងករណីដែលតុលាការសម្រេចផ្ដល់ស្ថានសម្រាលទោសឱ្យជនជាប់ចោទនោះ អប្បបរមា និងអតិបរមានៃទោសសម្រាប់ បទឆបោក ដែលត្រូវអនុវត្តចំពោះជនជាប់ចោទគឺ ទោសដាក់ពន្ធនាគារពី១ថ្ងៃ(អប្បបរមានៃទោស) ទៅ ៣ឆ្នាំ(អតិបរមានៃទោសគឺនៅដដែល) និងពិន័យជាប្រាក់ពី ៥សែនរៀល(អប្បបរមានៃទោស) ទៅ៦លានរៀល(អតិបរមានៃទោស)។

ច.កាលណាបទល្មើសមួយត្រូវបានសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតហើយផ្ដន្ទាទោសដាក់ពន្ធនាគារចន្លោះរវាង១៥ឆ្នាំ និង៣០ឆ្នាំ

ឧទាហរណ៍៖ ជនជាប់ចោទបានប្រព្រឹត្តបទល្មើសគឺបទឃាតកម្មគិតទុកជាមុនតាមមាត្រា២០០ នៃក្រមព្រហ្មទណ្ឌបទឃាតកម្មគិតទុកជាមុនត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។ នៅក្នុងករណីដែលតុលាការសម្រេចផ្ដល់ស្ថានសម្រាលទោសឱ្យជនជាប់ចោទ តុលាការអាចប្រកាសទោសដាក់ពន្ធនាគារចាប់ពី ១៥ឆ្នាំ រហូតដល់ ៣០ឆ្នាំ។

-កំណត់សម្គាល់ចំពោះស្ថានសម្រាលទោសទូទៅ អនុវត្តសម្រាប់គ្រប់បទល្មើសទាំងអស់នៅក្នុងក្រមព្រហ្មទណ្ឌលើកលែងតែច្បាប់ពិសេសផ្សេងទៀត។ ជាក់ស្ដែងនៅត្រង់មាត្រា៣៣នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនបានចែងថា បទប្បញ្ញត្តិនៃមាត្រា ៩៣ ដល់មាត្រា ៩៥នៃក្រមព្រហ្មទណ្ឌ មិនត្រូវយកមកអនុវត្តឡើយចំពោះបទឧក្រិដ្ឋទាំងឡាយដែលមានចែងក្នុងច្បាប់នេះ។ក៏ព្រោះតែអ្នកនីតិបទប្បញ្ញត្តិយល់ឃើញថាបទល្មើសគ្រឿងញៀនបានបង្កគ្រោះថ្នាក់ដល់សង្គមធ្ងន់ធ្ងរ និងប៉ះពាល់សណ្ដាប់ធ្នាប់សង្គម។

-ចំពោះករណីផ្ដល់ស្ថានសម្រាលទោសដល់អនីតិជន នីតិករនិងអ្នកអនុវត្តច្បាប់បានផ្ដល់ភាពអនុគ្រោះខ្លាំងដល់អនីតិជន។

យោងមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌបានចែងថា កាលណាតុលាការ សម្រេចផ្ដន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ៖

-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្ដាល។

-ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ ឆ្នាំ។

-អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បរមានេះលើសពី ១ ថ្ងៃ។

-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល។[53]

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមចិរវេលាមួយស្មើ ឬ តិចជាង ៥ឆ្នាំ នោះ បទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល។

ស្ថានសម្រាលទោសត្រូវអនុវត្តទៅលើអនីតិជន កាលបើតុលាការ បានសម្រេចឱ្យមានស្ថានសម្រាលទោស អប្បបរមានៃមូលទោសលើអនីតិជនពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម មាត្រា១៦៤ នៃក្រមព្រហ្មទណ្ឌត្រូវបន្ថយតាមខ្នាតដោយឡែកដូចតទៅ៖

ក.ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី១០ឆ្នាំ អប្បបរមានៃទោសនេះត្រូវបន្ថយមកត្រឹម១ឆ្នាំ

ឧទាហរណ៍៖ ជនជាប់ចោទបានប្រព្រឹត្តបទដឹកនាំកុបកម្ម មាត្រា៤៦៩ នៃក្រមព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ឆ្នាំ(អប្បបរមានៃទោស) ទៅ ៣០ឆ្នាំ(អតិបរមានៃទោស)។ក្នុងករណីដែលបទល្មើសប្រព្រឹត្តដោយអនីតិជន មូលទោសត្រូវបានបន្ថយតាមមាត្រា ១៦០នៃក្រមព្រហ្មទណ្ឌ ពោលគឺអប្បបរមា និងអតិបរមានៃទោសត្រូវបន្ថយពាក់កណ្តាល ដូចនេះ បទដឹកនាំកុបកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ។នៅក្នុងករណីដែលតុលាការសម្រេចផ្តល់ស្ថានសម្រាលទោសឱ្យជនជាប់ចោទជាអនីតិជននោះ អប្បបរមានៃទោសត្រូវបន្ថយមកនៅ១ឆ្នាំ។ ដូច្នេះ ទោសត្រូវអនុវត្តចំពោះជនជាប់ចោទគឺ ទោសដាក់ពន្ធនាគារពី ១ឆ្នាំ(អប្បបរមានៃទោស) ទៅ ១៥ឆ្នាំ (អតិបរមានៃទោសគឺនៅដដែល)។

ឧទាហរណ៍៖ ជនជាប់ចោទបានប្រព្រឹត្តបទឃាតកម្មគិតទុកជាមុន មាត្រា២០០ នៃក្រមព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។ ក្នុងករណីដែលបទល្មើសប្រព្រឹត្តដោយអនីតិជន មូលទោសត្រូវបានបន្ថយតាមមាត្រា ១៦០នៃក្រមព្រហ្មទណ្ឌ ចំណុចទី២ ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ឆ្នាំ។ប្រសិនបើពិនិត្យមើលមាត្រា១៦៤ ចំណុចទី១ ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី១០ឆ្នាំ អប្បបរមានៃទោសនេះត្រូវបន្ថយមកត្រឹម១ឆ្នាំ ។ ដោយសារតែអតិបរមានៃទោសដាក់ពន្ធនាគារ២០ឆ្នាំ និងអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី១០ នោះចំពោះបទល្មើសដែលប្រព្រឹត្តដោយអនីតិជននេះនឹងត្រូវទទួលទោសដាក់ពន្ធនាគារចន្លោះពី

[53] សៀវភៅសិក្សានីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ២០២២ ដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ទំព័រ៤៣៨

១ឆ្នាំ ទៅ២០ឆ្នាំ។ផ្អែកតាមការបកស្រាយខាងលើនេះ គឺជាការបកស្រាយលក្ខណៈតឹងរឹងដើម្បីជាប្រយោជន៍ដល់ជនជាប់ចោទ។[54]

ខ.ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី៥ ហើយតិចជាង១០ឆ្នាំ អប្បបរមានៃទោសនេះត្រូវបន្ថយមកត្រឹម៦ខែ

ឧទាហរណ៍៖ ជនជាប់ចោទបានប្រព្រឹត្តបទឃាតកម្ម មាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ(អប្បបរមានៃទោស) ទៅ ១៥ឆ្នាំ(អតិបរមានៃទោស)។ក្នុងករណីដែលបទល្មើសប្រព្រឹត្តដោយអនីតិជន មូលទោសត្រូវបានបន្ថយតាមមាត្រា ១៦០នៃក្រមព្រហ្មទណ្ឌ ពោលគឺអប្បបរមា និងអតិបរមានៃទោសត្រូវបន្ថយពាក់កណ្តាល។ ដូចនេះបទឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ៧ឆ្នាំ ៦ខែ។នៅក្នុងករណីដែលតុលាការសម្រេចផ្តល់ស្ថានសម្រាលទោស ឱ្យជនជាប់ចោទជាអនីតិជននោះអប្បបរមានៃទោសត្រូវបន្ថយមកនៅ ៦ខែ។ ដូច្នេះ ទោសត្រូវអនុវត្តចំពោះជនជាប់ចោទគឺ ទោសដាក់ពន្ធនាគារពី ៦ខែ (អប្បបរមានៃទោស) ទៅ ៧ឆ្នាំ ៦ខែ (អតិបរមានៃទោសគឺនៅដដែល)។

គ.ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី២ឆ្នាំហើយតិចជាង៥ឆ្នាំ អប្បបរមានៃទោសត្រូវបន្ថយមកត្រឹម៣ខែ

ឧទាហរណ៍៖ ជនជាប់ចោទបានប្រព្រឹត្តបទរំលោភសេពសន្ថវៈមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ រំលោភសេពសន្ថវៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ(អប្បបរមានៃទោស) ទៅ ១០ឆ្នាំ(អតិបរមានៃទោស)។ក្នុងករណីដែលបទល្មើសប្រព្រឹត្តដោយអនីតិជន មូលទោសត្រូវបានបន្ថយតាមមាត្រា ១៦០នៃក្រមព្រហ្មទណ្ឌ ពោលគឺអប្បបរមា និងអតិបរមានៃទោសត្រូវបន្ថយពាក់កណ្តាល ដូចនេះ បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ៦ខែ ទៅ ៥ឆ្នាំ។នៅក្នុងករណីដែលតុលាការសម្រេចផ្តល់ស្ថានសម្រាលទោសឱ្យជនជាប់ចោទជាអនីតិជននោះអប្បបរមានៃទោសត្រូវបន្ថយមកនៅ ៣ខែ។ ដូច្នេះ ទោសត្រូវអនុវត្តចំពោះជនជាប់ចោទគឺ ទោសដាក់ពន្ធនាគារពី ៣ខែ (អប្បបរមានៃទោស) ទៅ ៥ឆ្នាំ (អតិបរមានៃទោសគឺនៅដដែល)។

ឃ.ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី៦ថ្ងៃហើយតិចជាង២ឆ្នាំ អប្បបរមានៃទោសត្រូវបន្ថយមកត្រឹម១ថ្ងៃ

ឧទាហរណ៍៖ ជនជាប់ចោទបានប្រព្រឹត្តបទលួច មាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ(អប្បបរមានៃទោស) ទៅ ៣ឆ្នាំ(អតិបរមានៃទោស)។ក្នុងករណីដែលបទល្មើសប្រព្រឹត្តដោយអនីតិជន មូលទោសត្រូវបានបន្ថយតាមមាត្រា ១៦០នៃក្រមព្រហ្មទណ្ឌ ពោលគឺអប្បបរមា និងអតិបរមានៃទោសត្រូវបន្ថយពាក់កណ្តាល ដូចនេះ បទឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ខែ ទៅ ១ឆ្នាំ ៦ខែ។នៅក្នុងករណី

[54] យោងមាត្រា ១៣៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ដែល តុលាការសម្រេចផ្តល់ស្ថានសម្រាលទោសឱ្យជនជាប់ចោទជាអនីតិជននោះអប្បបរមានៃទោសត្រូវបន្ថយមកនៅ ១ថ្ងៃ។ ដូច្នេះ ទោសត្រូវអនុវត្តចំពោះជនជាប់ចោទគឺ ទោសដាក់ពន្ធនាគារពី ១ថ្ងៃ (អប្បបរមានៃទោស) ទៅ ១ឆ្នាំ ៦ខែ (អតិបរមានៃទោសគឺនៅដដែល)។

ង.ប្រសិនបើអប្បបរមានៃទោសពិន័យត្រូវបន្ថយត្រឹមពាក់កណ្តាល

ឧទាហរណ៍៖ ជនជាប់ចោទបានប្រព្រឹត្តបទលួច តាមមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ បទលួចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ(អប្បបរមានៃទោស) ទៅ ៣ឆ្នាំ(អតិបរមានៃទោស) និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៦លានរៀល។ក្នុងករណីដែលបទល្មើសប្រព្រឹត្តដោយអនីតិជន មូលទោសត្រូវបានបន្ថយតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ពោលគឺអប្បបរមា និងអតិបរមានៃទោសត្រូវបន្ថយពាក់កណ្តាល ដូចនេះ បទលួចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ខែ ទៅ ១ឆ្នាំ ៦ខែ និងពិន័យជាប្រាក់ពី ៥សែនរៀល ទៅ ៣លានរៀល។នៅក្នុងករណីដែលតុលាការសម្រេចផ្តល់ស្ថានសម្រាលទោសឱ្យជនជាប់ចោទជាអនីតិជននោះ ទោសត្រូវអនុវត្តចំពោះជនជាប់ចោទគឺ ទោសដាក់ពន្ធនាគារពី ១ថ្ងៃ (អប្បបរមានៃទោស) ទៅ ១ឆ្នាំ ៦ខែ (អតិបរមានៃទោសគឺនៅដដែល) និងពិន័យជាប្រាក់ពី ២សែន៥០០០០រៀល(អប្បបរមានៃទោស) ទៅ ៣លានរៀល(អតិបរមានៃទោសគឺនៅដដែល)។

**៣.២.២.ស្ថានសម្រាលទោសដោយឡែក**

ក្រៅពីមានស្ថានសម្រាលទោសទូទៅដូចបានរៀបរាប់ខាងលើមក ក្រមព្រហ្មទណ្ឌមិនបានកំណត់ជាក់លាក់ពីស្ថានសម្រាលទោសដោយឡែកទេ ក៏ប៉ុន្តែនៅមានបទប្បញ្ញត្តិពិសេសផ្សេងៗទៀត បានចែងដោយឡែកសម្រាប់តែបទល្មើសជាក់លាក់ណាមួយតែប៉ុណ្ណោះ។

ឧទាហរណ៍៖មាត្រា៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនបានផ្តល់ស្ថានសម្រាលទោសឱ្យចារីសហចារី អ្នកសមគំនិត ឬអ្នកផ្តើមគំនិតក្នុងការប្រព្រឹត្តបទល្មើសដែលមានចែងក្នុងជំពូក៤ នៃច្បាប់នេះដែលបានរាយការណ៍ឱ្យស្គាល់អត្តសញ្ញាណអ្នកចូលរួមដទៃទៀត ក្រោយពេលដែលខ្លួនត្រូវបានចោទប្រកាន់។ នៅក្នុងករណីនេះ ទោសត្រូវបន្ថយតាមលក្ខខណ្ឌដូចខាងក្រោម៖

-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល។

-ប្រសិនបើអតិបរមានៃទោសនោះ គឺទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ឆ្នាំ។

-អប្បបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី១ថ្ងៃ។

-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល។[55]

---

[55] សៀវភៅសិក្សានីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ២០២២ ដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ទំព័រ ៤៤០

ឧទាហរណ៍៖ មាត្រា៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទក៏បានផ្តល់ស្ថានសម្រាលទោសដែរទាក់ទងនឹងបទល្មើសការនាំយកអនីតិជន ជាអាទិ៍ ចេញដោយមិនស្របច្បាប់បានចែងថា ជនណានាំយកអនីតិជន ឬ ជនដែលនៅក្រោមអាណាព្យាបាលទូទៅ ឬ នៅក្រោមហិតូបត្ថម្ភ ឬ នៅក្រោមអ្នកគ្រប់គ្រងស្របច្បាប់ចេញដោយមិនស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ដល់ ៥ឆ្នាំ។

ចំពោះបទល្មើសដែលមានចែងក្នុងមាត្រានេះ ការផ្តន្ទាទោសត្រូវលើកលែង ឬ ទទួលស្ថានសម្រាល ក្នុងករណីលក្ខខណ្ឌទាំងអស់ ត្រូវបានបំពេញដូចតទៅនេះ៖

-បើជនស្ថិតនៅក្រោមការគ្រប់គ្រង ដែលគេនាំយកទៅនោះ មានអាយុចាប់ពី ១៥ ឆ្នាំ ឡើងទៅ និងយល់ព្រមដោយស្ម័គ្រចិត្ត ចំពោះអំពើល្មើស។

-ការពុំមានប្រើវិធានការណាមួយដែលមានចែង ក្នុងកថាខណ្ឌទី១មាត្រា៨ នៃច្បាប់នេះត្រូវបានប្រើប្រាស់។

-ជនល្មើសមិនមានគោលបំណង ប្រព្រឹត្តបទល្មើសណាមួយ។

ឧទាហរណ៍៖មាត្រា១៣ នៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត បានចែងថា ករណីលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវឬទទួលការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ។

ចំពោះបុគ្គលដែលបានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា៧ មាត្រា៨ មាត្រា១០ និងមាត្រា១១នៃច្បាប់នេះ។ អាចលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវឬទទួលការសម្រាលការទទួលខុសត្រូវខុសព្រហ្មទណ្ឌ ប្រសិនបើបុគ្គលនោះបានបង្ហាញប្រាប់ព័ត៌មានដល់មន្ត្រីសុខាភិបាល ឬមន្ត្រីមានសមត្ថកិច្ចឬបានផ្តល់កិច្ចសហការចាំបាច់នានាដើម្បីជាប្រយោជន៍ក្នុងការទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ឱ្យបានទាន់ពេលវេលា។ ការលើលែងឱ្យរួចផុតពីការទទួលខុសត្រូវ ឬទទួលបាននូវការសម្រាលការទទួលបាននូវការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌខាងលើ ក៏ត្រូវយកទៅអនុវត្តផងដែរ ក្នុងករណីដែលក្រុមគ្រួសារនៃបុគ្គលដែលបានប្រព្រឹត្តបទល្មើស ដែលមានចែងក្នុងមាត្រា៧ មាត្រា៨ មាត្រា១០ និងមាត្រា១១នៃច្បាប់នេះ បានបង្ហាញប្រាប់ព័ត៌មានដល់មន្ត្រីសុខាភិបាលនៃជំងឺកូវីដ-១៩ឱ្យបានទាន់ពេលវេលា។ ទាក់ទងនឹងចំណុចនេះប្រសិនបើពិនិត្យមើលឃើញថាច្បាប់នេះមិនបានចែងពីស្ថានសម្រាលទោសទេដូចនេះតុលាការអាចផ្តល់ស្ថានសម្រាលទោស ដោយយោងតាមមាត្រា៩៣ និងចំពោះការបន្ថយខ្នាតនៃទោសយោងតាមមាត្រា៩៤នៃក្រមព្រហ្មទណ្ឌដែលជាបទប្បញ្ញត្តិទូទៅ។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ការកំណត់ទោសដោយចៅក្រម គឺជាវិធានការក្នុងការប្រកាសទោសដោយចៅក្រមជាមួយការប្រើប្រាស់ឆន្ទានុសិទ្ធិក្នុងការសម្រេចសេចក្តីទៅលើជនជាប់ចោទ។បន្ទាប់ពីបានរកឃើញពិរុទ្ធភាពរបស់ចារីនៃបទល្មើស គឺចៅក្រមត្រូវធ្វើការកំណត់ការផ្តន្ទាទោសចំពោះចារីនឹងត្រូវទទួលរង។ បើទោះបីជាជនជាប់ចោទបានប្រព្រឹត្តបទល្មើសក៏ពិតមែនក៏ប៉ុន្តែ ក្នុងក្រមព្រហ្មទណ្ឌក៏បានចែងពី ការព្យួរទោស ការបែងចែកទោសជាប្រភាគ និងរបបពាក់កណ្តាលសេរីភាព។យើងឃើញថាវិធានការនេះ ពិតជាផ្តល់ប្រយោជន៍ដល់ទណ្ឌិតក្នុងការទទួលបានផលប្រយោជន៍ពីច្បាប់ដែលបានចែង។ទោះបីជាទណ្ឌិតទទួលបានប្រយោជន៍ក៏ពិតមែន ក៏ប៉ុន្តែក្នុងក្រមព្រហ្មទណ្ឌនេះបានចែងពីលក្ខខណ្ឌដែលតម្រូវឱ្យត្រូវតាមច្បាប់កំណត់ ហើយពិសេសការសម្រេចសេចក្តីនេះគឺអាស្រ័យលើឆន្ទានុសិទ្ធិរបស់តុលាការក្នុងការអនុញ្ញាតផ្តល់ឱ្យផងដែរ។ ក្រៅពីការផ្តល់យុត្តិធម៌ដល់ជនរងគ្រោះនៃបទល្មើសក៏ប៉ុន្តែប្រសិន បើបទល្មើសដែលចារីបានប្រព្រឹត្តនោះស្ថិតក្នុងស្ថានភាពដែលត្រូវលើកលែងដោយច្បាប់ ឬ ជាស្ថានភាពជាច្រើនដែលជាវិធានការដែលបានរៀបរាប់ខាងលើនោះចារី ក៏ត្រូវបានទទួលការអនុគ្រោះពីតុលាការផងដែរ បើទោះបីជាលក្ខខណ្ឌមិនតម្រូវចំពោះចារីក៏ដោយ ក្រោយពីពេលដែលការអនុវត្តទោសក្នុងពន្ធនាគារចប់ និងត្រូវបានដោះលែងឱ្យមានសេរីភាព ក៏បានផ្តល់ឱកាសក្នុងការកែប្រែខ្លួននឹងមិនទៅប្រព្រឹត្តបទល្មើសជាថ្មីម្តងទៀតឡើយ ដើម្បីឱ្យចារីបានធ្វើសមាហរណកម្មចូលរស់នៅក្នុងសង្គមវិញ និងរស់នៅក្នុងសន្តិភាពទាំងផ្លូវចិត្តរួមទាំងផ្លូវកាយ។

ម្យ៉ាងវិញទៀត ក្រៅពីការរៀបរាប់ខាងលើក្រមព្រហ្មទណ្ឌក៏បានចែងបទប្បញ្ញត្តិនូវករណីនៃការប្រព្រឹត្តបទល្មើសត្រួតគ្នាដែលការប្រព្រឹត្តបទល្មើសត្រួតគ្នានេះជាបទល្មើសប្រព្រឹត្តដោយជនដដែលម្តងហើយម្តងទៀតដែលជាមូលហេតុបានប៉ះពាល់ដល់សណ្តាប់សង្គមយ៉ាងធ្ងន់ធ្ងរ។ ក៏ប៉ុន្តែចំណុចនេះក៏មានការប្រកាសទោសបែបផ្សេងពីករណីនៃការមិនរាងចាលទៅវិញ ក៏ព្រោះតែខុសប្លែកគ្នាត្រង់ថាបទល្មើសត្រួតគ្នាមិនទាន់ទទួលបានសេចក្តីសម្រេចផ្តន្ទាទោសជាស្ថាពរពីតុលាការនៅឡើយទេ។ទោះបីជាយ៉ាងនេះក្តី បទល្មើសត្រួតគ្នាប្រសិនបើជនណាម្នាក់បានប្រព្រឹត្តបទល្មើសត្រួតគ្នានោះ ប្រាកដជាស្ថិតក្នុងការចោទប្រកាន់មិនថាជាការចោទប្រកាន់តែមួយឬដាច់ដោយឡែកទេគឺនៅតែទទួលខុសត្រូវខាងព្រហ្មទណ្ឌដដែល ក៏ប៉ុន្តែនីតិវិធីនៃការអនុវត្តខុសៗគ្នាទៅតាមករណីនីមួយៗ។ អ្វីដែលពិសេសនោះគឺក្នុងករណីពេលដែលតុលាការបានប្រកាសចំពោះបទល្មើសត្រួតគ្នានេះ ត្រង់នេះគឺមានវិធានការស្រូបទោស ចំពោះបទល្មើសត្រួតគ្នាបានផ្តល់អត្ថប្រយោជន៍ដល់ជនជាប់ចោទក៏ព្រោះតែប្រសិនបើ ក្រមព្រហ្មទណ្ឌប្រើគោលការណ៍នៃការបូកទោសក្នុងករណីនៃការប្រព្រឹត្តបទល្មើសស្ថិតក្នុងបទលហុវិញមិនចោទជាបញ្ហាទេ។ក៏ប៉ុន្តែប្រសិនបើជាបទឧក្រិដ្ឋ និងបទមជ្ឈិមវិញគឺប្រាកដជាមានការបូកទោសពន្ធនាគារជាច្រើនឆ្នាំហួតដល់លើសពីអាយុនៃការរស់នៅរបស់បុគ្គលក្នុងសង្គមផងដែរ ហេតុដូច្នេះករណីនេះ

ប្រសិនបើអនុវត្តនោះប្រាកដជាផ្តល់ជាវិនាសសកម្មដល់សង្គមជាតិជាយថាហេតុផងដែរ។ ជារួមការប្រើប្រាស់វិធានការក្នុងការស្រូបទោសពិតជាវិធានការមួយដល់ល្អសម្រាប់ប្រកាសទោសដល់ជនជាប់ចោទ ដើម្បីឱ្យមានភាពយុត្តិធម៌។បន្ថែមពីទៀតយើងសង្កេតឃើញថា ការស្រូបទោសនេះបានបែងចែកចេញជាពីរទៀតគឺការស្រូបទោសមួយផ្នែក និងការស្រូបទោសទាំងមូល ទាំងនេះគឺជាឆន្ទានុសិទ្ធិរបស់តុលាការក្នុងការអនុញ្ញាតក្នុងការប្រកាសការស្រូបទោសមួយផ្នែក ឬទាំងមូលដល់ជនជាប់ចោទ។

ក្នុងករណីដែលជនដដែលបានអនុវត្តទោសចប់សព្វគ្រប់ក្នុងពន្ធនាគារ ហើយបានដោះលែងឱ្យមានសេរីភាពក៏ប៉ុន្តែជនដដែលបានទៅប្រព្រឹត្តបទល្មើសជាថ្មីដូចតាមការកំណត់ក្នុងក្រមព្រហ្មទណ្ឌ។ ក្នុងករណីនេះក្រមព្រហ្មទណ្ឌបានបទប្បញ្ញត្តិថាជាករណីនៃការមិនរាងចាល ក៏ព្រោះជននោះបានទៅប្រព្រឹត្តបទល្មើសថ្មីបើទោះបីជាបទល្មើសនោះក្នុងទម្រង់បែបណាក៏ដោយ ប្រសិនបើច្បាប់បានចែងពីបទល្មើសដែរបានប្រព្រឹត្តនោះ។ ប្រសិនបើការមិនរាងចាលត្រូវបានកំណត់តាមលក្ខខណ្ឌតាមការកំណត់របស់ច្បាប់ យើងឃើញថានឹងមានការបន្ថែមស្ថានទម្ងន់ទោសទូទៅក្នុងករណីនីមួយៗឱ្យដល់អតិបរមាតែម្តង។ផ្ទុយទៅវិញប្រសិនបើ ស្ថិតក្នុងស្ថានសម្រាលទោសទូទៅវិញក្រមព្រហ្មទណ្ឌពិតជាមានការអនុគ្រោះជាច្រើនផងដែរ មិនថាជានីតិជន ឬជាអនីតិជនទេ។ជាពិសេសមិនថាបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌទេ សូម្បីតែច្បាប់ពិសេសផ្សេងទៀតជាច្រើនបានបែងចែកជាស្ថានសម្រាលទោសដោយឡែក ក្នុងការផ្តល់ដល់បុគ្គលដែលបានប្រព្រឹត្តបទល្មើសដូចដែលមានចែងក្នុងច្បាប់ពិសេសដែលនៅជាធរមានផងដែរ។ជារួមការផ្តន្ទាទោសក្នុងសេចក្តីសម្រេចតុលាការមិនថាជាស្ថានទម្ងន់ទោស ឬ ជាស្ថានសម្រាលទោសនោះឡើយគឺតុលាការត្រូវតែប្រើប្រាស់នូវឆន្ទានុសិទ្ធិដែលមានគិតគូរពិចារណាដល់កម្រិតជាអតិបរមាច្បាស់លាស់បើទោះបីជាមាន លក្ខខណ្ឌដែលច្បាប់បានចែងមិនថាក្នុងបទប្បញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ពិសេសផ្សេងទៀតឡើយ។

សរុបសេចក្តីមកយើងអាចសន្និដ្ឋានបាន ការកំណត់ទោសដោយចៅក្រមនេះជាឆន្ទានុសិទ្ធិក្នុងការសម្រេចផ្តន្ទាទោសទៅលើជនជាប់ចោទតាមច្បាប់ដែលបានផ្តល់អំណាចឱ្យក្នុងសម្រេច។ ដូច្នេះចៅក្រមពិតជាមានអំណាចក្នុងការសម្រេចនិងត្រូវពិចារណាឱ្យល្អិតល្អន់ជាអតិបរមាក្នុងការសម្រេច ក៏ព្រោះតែការសម្រេចឱ្យផ្តន្ទាទោសដាក់ពន្ធនាគារគឺពិតជាប៉ះពាល់សិទ្ធិសេរីភាពជាមូលដ្ឋានរបស់ពលរដ្ឋក្នុងសង្គមខ្លាំងណាស់ ថែមទាំងប៉ះពាល់ដល់សេដ្ឋកិច្ច ជាពិសេសសេដ្ឋកិច្ចគ្រួសារជាយថាហេតុផងដែរ។ផ្ទុយទៅវិញប្រសិនបើ ជនជាប់ចោទមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការអនុញ្ញាតឱ្យព្យួរទោស ការអនុវត្តទោសដោយបានបែងចែងជាប្រភាគ និងរបបពាក់កណ្តាលសេរីភាព រួមទាំងករណីដែលការប្រព្រឹត្តបទល្មើសទទួលបានស្ថានសម្រាលទោសពីតុលាការនោះគឺបានផ្តល់ឱកាសឱ្យទណ្ឌិតមានការកែប្រែ ឬបានសងនូវព្យសនកម្មនូវការខូចខាតទៅក្នុងសង្គម ឬជនរងគ្រោះជាជាងការឱ្យទណ្ឌិតអនុទោសក្នុងពន្ធនាគារ។ចំពោះយន្តការដែលបានរៀបរាប់ខាងលើ គឺជាការធ្វើសមាហរណ

កម្មរបស់ទណ្ឌិតដែលបានកែប្រែខ្លួនឆាប់បានត្រលប់ចូលទៅរស់នៅក្នុងសង្គមវិញ ដូចជាការព្យួរទោស ការបែងចែកទោសជាប្រភាគ និងរបបពាក់កណ្តាលសេរីភាព។យន្តការទាំងនេះពិតជាមានផលប្រយោជន៍ដល់ទណ្ឌិតថែមទាំងជាប្រយោជន៍ដល់សង្គមដែលអាចជាលទ្ធផល នាំឱ្យមានការថមថយចុះនៃកំណើននៃបទល្មើស។បើទោះបីជាយ៉ាងណាក៏ដោយយើងសង្កេតឃើញថាវិធានការទាំងនេះ នៅតែមានការអនុវត្តតិចនៅឡើយ។ក៏ប៉ុន្តែសង្ឃឹមថានៅថ្ងៃអនាគតខាងមុខវិធានការដែលបានរៀបរាប់នេះនឹងត្រូវបានតុលាការ ផ្តល់ការសម្រេចក្នុងការប្រកាសចំពោះជនជាប់ចោទ។ជាចុងក្រោយ វិធានការក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ពិសេសដទៃទៀតពិតជាបានចូលរួមទប់ស្កាត់ បង្ការ ការកើតមានបទល្មើសក្នុងសង្គមដើម្បីរក្សាសណ្តាប់ធ្នាប់ សន្តិសុខ និងមិនមានការបទល្មើសច្រើន បន្ថែមជាមួយការថយចុះនៃទណ្ឌិតក្នុងការអនុវត្តទោសក្នុងពន្ធនាគារ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានបកស្រាយយ៉ាងក្បោះក្បាយនូវប្រធានបទខាងលើនេះរួចមកបានកត់សម្គាល់ឃើញក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ គឺមានវិធានការនិងយន្តការច្រើនសម្រាប់កំណត់ទោសដោយចៅក្រម ចំពោះបុគ្គលដែលបានប្រព្រឹត្តបទល្មើសដូចដែលមានបទប្បញ្ញត្តិបានចែងក្នុងក្រមព្រហ្មទណ្ឌ។ ចំពោះរបបនៃការប្រកាសទោសនៅក្នុងក្រមព្រហ្មទណ្ឌគឺមានដូចជា ការព្យួរទោស ការបែងចែកទោសជាប្រភាគ និងរបបពាក់កណ្តាលសេរីភាព។បន្ថែមពីនេះទៀត បើទោះបីជាក្រមព្រហ្មទណ្ឌបានផ្តល់សិទ្ធិឱ្យតុលាការក្នុងការអនុញ្ញាតឱ្យមានរបបនៃការព្យួរទោស ការបែងចែកទោសជាប្រភាគ និងរបបពាក់កណ្តាលសេរីភាពក៏តម្រូវឱ្យមានលក្ខខណ្ឌជាច្រើនដែលទណ្ឌិតត្រូវមានដើម្បីឱ្យតុលាការផ្តល់ការអនុញ្ញាត។ ក៏ប៉ុន្តែរបបនៃការប្រកាសទោសនេះគឺអាស្រ័យឆន្ទានុសិទ្ធិរបស់តុលាការក្នុងការផ្តល់ឱ្យតែប៉ុណ្ណោះ។ បើទោះបីជាក្នុងក្រមព្រហ្មទណ្ឌមានចែងពីរបបនៃការប្រកាសទោសនេះក៏ដោយ យើងសង្កេតឃើញថាវិធានការទាំងនេះមិនសូវបានតុលាការយកមកអនុវត្តទេ ក៏ព្រោះតែវិធានការនេះត្រូវការអ្នកតាមដានក្នុងមូលដ្ឋានដែលទណ្ឌិតរស់នៅ ប្រសិនបើទណ្ឌិតស្ថិតក្នុងពេលអនុវត្តទោសនេះមិនបានគោរពតាមវិធានការនិងកាតព្វកិច្ចដែលតុលាការដាក់ឱ្យអនុវត្តទោស វិធានការបន្ថែមគឺមានតែឃាត់ខ្លួនសាជាថ្មី។ចំពោះករណីនៃការរាងចាលវិញយើងឃើញថា មានការបន្ថែមស្ពានទម្ងន់ទោសទៅតាមខ្ទាតនៃក្រមព្រហ្មទណ្ឌវិធានការអាចធ្វើឱ្យជនល្មើសខ្លាចរអា និងមិនហ៊ានប្រព្រឹត្តបទល្មើសម្តងទៀតឡើយ ផ្ទុយទៅវិញប្រសិនបើជនល្មើសនៅតែប្រព្រឹត្តគឺជាកត្តាមួយផ្តល់ផលមិនល្អដល់សង្គមគ្រួសារ និងសង្គមជាតិ។ជាពិសេសគឺកំណើននូវទណ្ឌិតនៅក្នុងពន្ធនាគារច្រើនលើសលប់ដែលជាបន្ទុករបស់រដ្ឋក្នុងការចំណាយលើបញ្ហាពន្ធនាគារ លើសពីនេះទៅទៀត បានធ្វើបាត់បង់កម្លាំងពលកម្មដែលជាកម្លាំងចលករក្នុងការជាក់កំណើនសេដ្ឋកិច្ចជាតិផងដែរ។

ជាចុងក្រោយនេះខ្ញុំសង្ឃឹមថា នារយៈពេលខ្លីខាងមុខនេះតុលាការព្រហ្មទណ្ឌនឹងជ្រើសរើសវិធានការខាងលើឱ្យបានជាអតិបរមាតាមដែលអាចធ្វើបាន។ វិធានការអស់ទាំងនេះហើយ គឺអាចផ្តល់ឱកាសឱ្យទណ្ឌិតបើទោះបីជាពួកគាត់បានប្រព្រឹត្តបទល្មើសក៏ពិតមែន ប៉ុន្តែអាចជាការគិតខុសឆ្គងមួយពេល ដូច្នេះយើងអាចផ្តល់ឱកាសឱ្យគាត់បានកែប្រែខ្លួនដើម្បីប្រើប្រាស់ ចំណេះជំនាញនិងទេពកោសល្យរបស់គាត់ ដើម្បីជួយសេដ្ឋកិច្ចជាតិនិងសេដ្ឋកិច្ចគ្រួសារជាចម្បងជាជាងឱ្យពួកគាត់ជាប់ពន្ធនាគារដោយមិនបានជួយអ្វីសោះដល់សង្គមជាតិយើង។ ក៏ប៉ុន្តែ ការអនុវត្តវិធានការខាងលើមិនមែនមានន័យថាផ្តល់សេរីភាពដល់ពួកគាត់ធ្វើអ្វីតាមចិត្តបាននោះទេ ឬអាចនាំឱ្យការប្រព្រឹត្តបទល្មើសថ្មី ជាគ្រោះថ្នាក់ដល់សង្គមទេ គឺរាល់វិធានការនីមួយៗនិងកាតព្វកិច្ចគឺស្ថិតក្រោមការត្រួតពិនិត្យយ៉ាងតឹងតែងជាទីបំផុត។

# ឯកសារយោង

**១.លិខិតបទដ្ឋានគតិយុត្ត**

-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣។

-ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩។

-ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧។

-ច្បាប់ស្ដីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវឆ្នាំ ២០០៥។

-ច្បាប់ស្ដីពីការគ្រប់គ្រងអាស៊ីដខ្លាំងឆ្នាំ ២០១១។

-ច្បាប់ស្ដីពីពន្ធនាគារ ២០១១ ។

-ច្បាប់ស្ដីពីការប្រឆាំងនឹងភេរវកម្មឆ្នាំ ២០០៧។

-ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ ២០១២។

-ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទឆ្នាំ ២០០៨។

-ច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ឆ្នាំ២០២១។

-សារាចរស្ដីពី ការអនុវត្តបទប្បញ្ញត្តិ នៃការព្យួរទោសសាកល្បងនៃក្រសួងយុត្តិធម៌ ឆ្នាំ២០១៤។

**២.សព្ទានុក្រម**

-វចនានុក្រមខ្មែររបស់សម្ដេចសង្ឃរាជ ជួន ណាត

-វចនានុក្រមច្បាប់ បោះពុម្ពលើកទី៣ ឆ្នាំ ២០១០ ដោយលោក ហ៊ីង ធីឫទ្ធិ

**៣.ឯកសារស្រាវជ្រាវ**

-សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធិ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០២២។

- មេរៀននីតិវិធីព្រហ្មទណ្ឌរបស់លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធិ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ ២០១៧- ២០១៨។

-មេរៀនក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បកស្រាយដោយ ឯកឧត្តមសាស្ត្រាចារ្យ ហ៊ី សោភា ,ឯកឧត្តម ប៊ុន ហុន, ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌ ,ឯកឧត្តម ផូវ សំភី និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១១ ចងក្រងដោយ លោក សឿន មុនីរ័ត្ន ព្រះរាជអាជ្ញារង ខេត្តកំពង់ធំ។

-ការផ្សាយរបស់សាលាត្រាជូ បទល្មើសត្រួតគ្នា ដោយ ចក សម្បត្តិ ឆ្នាំ២០១៥។

-ឯកសារជំនួយស្មារតីសម្រាប់ការស្វែងយល់ក្រមព្រហ្មទណ្ឌ វិធានអនុវត្តក្នុងករណីបទល្មើសត្រួតគ្នា ដោយឯកឧត្តមសាស្ត្រាចារ្យ ហ៊ី សោភា , ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌។

**៤.បទសម្ភាសន៍**

-ប្រសាសន៍របស់ ឯកឧត្តម ផូវ សំភី ឯកឧត្តម ប៊ុន ហុន និងឯកឧត្តម កើត រិទ្ធ អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ នៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី ក្រមព្រហ្មទណ្ឌ ដែលរៀបចំឡើងដោយ ក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជា។

# ឧបសម្ព័ន្ធ

# តារាងឧបសម្ព័ន្ធ

-ឧបសម្ព័ន្ធទី១៖ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ចាប់ពីមាត្រា៤៣ ដល់មាត្រា៥២និង ចាប់ពីមាត្រា៧៧ ដល់មាត្រា១៦៤

-ឧបសម្ព័ន្ធទី២៖ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ចាប់ពីមាត្រា៤០ ដល់មាត្រា៤៩,មាត្រា១២៥, មាត្រា២៦៣, មាត្រា២៩៩, និងមាត្រា៥០១

-ឧបសម្ព័ន្ធទី៣៖ សារាចរស្តីពី ការអនុវត្តបទប្បញ្ញត្តិ នៃការព្យួរទោសសាកល្បងនៃក្រសួងយុត្តិធម៌ ឆ្នាំ២០១៤

-ឧបសម្ព័ន្ធទី៤៖ វិធានអនុវត្តក្នុងករណីបទល្មើសត្រួតគ្នា ដោយឯកឧត្តមសាស្ត្រាចារ្យ ហ៊ី សោភា , ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌

-ឧបសម្ព័ន្ធទី៥៖ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

-ឧបសម្ព័ន្ធទី៦៖ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម

-ឧបសម្ព័ន្ធទី៧៖ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

-ឧបសម្ព័ន្ធទី៨៖ កំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម

# ឧបសម្ព័ន្ធទី១

# ក្រមព្រហ្មទណ្ឌ

ព្រះរាជក្រម

នស/រកម/១១០៩/០២២

# យើង

# ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

# ប្រកាសឱ្យប្រើ

ក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៦ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

## ជំពូកទី ៤
## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

**មាត្រា ៤២.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គល លើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍ របស់នីតិបុគ្គលនោះ ។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុស ត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ក្នុងអំពើដដែលនោះទេ ។

## មាតិកាទី ៣
## ទោស
## ជំពូកទី ១
## ប្រភេទនៃទោស
## ផ្នែកទី ១
## មូលទោស

**មាត្រា ៤៣.-** មូលទោស

មូលទោសរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យ ។

ការពិន័យត្រូវគិតជាប្រាក់រៀល ។

**មាត្រា ៤៤.-** អប្បបរមា និងអតិបរមានៃមូលទោស

កាលបើបទល្មើសត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ ច្បាប់កំណត់អំពី អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ ។

កាលបើបទល្មើសត្រូវផ្ដន្ទាទោសពិន័យ ច្បាប់កំណត់អំពីអប្បបរមា និង អតិបរមា នៃចំនួនទឹកប្រាក់ពិន័យដែលត្រូវទទួល ។

**មាត្រា ៤៥.-** ការទម្ងន់ទោស និងការសម្រាលទោស

អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ និងការពិន័យជាប្រាក់ អាចបន្ថែម ឬបន្ថយនៅក្នុងលក្ខខណ្ឌដែលចែងដោយក្រមនេះ ។

**មាត្រា ៤៦.-** និយមន័យនៃបទឧក្រិដ្ឋ

បទល្មើសជាបទឧក្រិដ្ឋ នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ :

១-ជាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

២-ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ (ប្រាំ) ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ (សាមសិប) ឆ្នាំ ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

**មាត្រា ៤៧.-** និយមន័យនៃបទមជ្ឈិម

បទល្មើសជាបទមជ្ឈិម នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ មានរយៈពេលលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងក្រោម ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

**មាត្រា ៤៨.-** និយមន័យនៃបទលហុ

បទល្មើសជាបទលហុ នៅក្នុងករណីដែល :

១-អតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ មានរយៈពេលក្រោម ឬស្មើនឹង ៦ (ប្រាំមួយ) ថ្ងៃ ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

២-បទល្មើសត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ។

**មាត្រា ៤៩.-** ការគណនាអំពីចិរវេលានៃទោសដាក់ពន្ធនាគារ

ទោសដាក់ពន្ធនាគារ ១ (មួយ) ថ្ងៃ ត្រូវគិត ២៤ (ម្ភៃបួន) ម៉ោង ។

ទោសដាក់ពន្ធនាគារ ១ (មួយ) ខែ ត្រូវគិត ៣០ (សាមសិប) ថ្ងៃ ។

ទោសដាក់ពន្ធនាគារលើសពី ១ (មួយ) ខែ ត្រូវគិតតាមចំនួនថ្ងៃជាក់ស្តែង ដែលមាននៅក្នុងខែនោះ ។

ទោសដាក់ពន្ធនាគារ ១ (មួយ) ឆ្នាំ ត្រូវគិត ១២ (ដប់ពីរ) ខែ ។

**មាត្រា ៥០.-** លក្ខខណ្ឌដោយឡែកនៃការបញ្ចប់ទោស

ជាគោលការណ៍ ទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបញ្ចប់នៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកផ្សេងទៀតដែលច្បាប់ ឬបទដ្ឋានគតិយុត្តបានកំណត់ ត្រូវតែដោះលែងឱ្យមានសេរីភាពវិញនៅមុនថ្ងៃឈប់សម្រាកនោះ ។

**មាត្រា ៥១.-** ការគិតបញ្ចូលចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវគិតបញ្ចូលទាំងស្រុងទៅក្នុងចិរវេលានៃទោសដាក់ពន្ធនាគារដែលត្រូវទទួល ។

**មាត្រា ៥២.-** ផលនៃទោសពិន័យ

ប្រាក់ពិន័យដែលទទួលបាន ត្រូវបង់ចូលថវិការដ្ឋ ។

## ផ្នែកទី ២

## ទោសបន្ថែម

**មាត្រា ៥៣.-** ប្រភេទនៃទោសបន្ថែម

ទោសបន្ថែមរួមមាន :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្ត នៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ ។

៣-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ។

៤-ការព្យួរលិខិតបើកបរ ។

៥-ការហាមឃាត់ចំពោះការស្នាក់នៅ ។

៦-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

## កថាភាគទី ២
## ការស្តីបន្ទោស

**មាត្រា ៧៦.–** របបគតិយុត្តនៃការស្តីបន្ទោស

កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ ដែលមានអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសស្តីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌទាំងបីដូចតទៅនេះ :

-ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីបទល្មើសបានបញ្ចប់

-ការខូចខាតត្រូវបានជួសជុលរួចហើយ និង

-ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ ។

## ជំពូកទី ២
## ស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស
## ផ្នែកទី ១
## ស្ថានទម្ងន់ទោស
## កថាភាគទី ១
## និយមន័យនៃស្ថានទម្ងន់ទោសដោយឡែកខ្លះៗ

**មាត្រា ៧៧.–** ក្រុមមានការចាត់តាំង

ក្រុមមានការចាត់តាំង គឺជាការប្រមូលផ្តុំដែលបានបង្កើតឡើង ឬជាសន្និដ្ឋិភាពដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬប្រព្រឹត្តបទល្មើសមួយ ឬច្រើន ។

**មាត្រា ៧៨.–** ការគិតទុកជាមុន

ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនសកម្មភាពប្រព្រឹត្តបទល្មើស ។

**មាត្រា ៧៩.-** ការកាប់គាស់ទម្លុះទម្លាយ

ការកាប់គាស់ទម្លុះទម្លាយគឺជាអំពើបង្ខំធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញគ្រឿងបិទទ្វារ ឬរបង ទោះបីមានប្រភេទយ៉ាងណាក៏ដោយ ។

ត្រូវចាត់ទុកដូចជាការកាប់គាស់ទម្លុះទម្លាយ :

១-ការប្រើប្រាស់កូនសោក្លែង ។

២-ការប្រើប្រាស់កូនសោដែលបានមកដោយឧបាយកលទុច្ចរិត ។

៣-ការប្រើប្រាស់គ្រប់ឧបករណ៍ ដើម្បីធ្វើឱ្យគ្រឿងបិទមានដំណើរការដោយគ្មានការបង្ខំ ការខូចខាត ឬការបំផ្លិចបំផ្លាញទេ ។

**មាត្រា ៨០.-** ការផ្លោះរបងចូល

ការផ្លោះរបងចូល គឺជាអំពើចូលទៅក្នុងទីកន្លែងណាមួយដោយឆ្លងរបង ឬដោយចូលតាមទ្វារ ឬបង្អួច ដែលមិនមែនសម្រាប់ធ្វើជាផ្លូវចូលទេ ។

**មាត្រា ៨១.-** អាវុធ និងវត្ថុដែលត្រូវបានចាត់ទុកដូចអាវុធ

អាវុធ គឺជាវត្ថុទាំងអស់ដែលធ្វើឡើងដើម្បីសម្លាប់ ឬធ្វើឱ្យមានរបួស ។

ត្រូវបានចាត់ទុកដូចជាអាវុធ វត្ថុដទៃទៀត ដែលអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់មនុស្សនៅក្នុងករណីដូចតទៅ :

១-វត្ថុត្រូវបានប្រើប្រាស់សម្រាប់សម្លាប់ ធ្វើឱ្យរបួស ឬគំរាមកំហែង ។

២-វត្ថុមានទីដៅសម្រាប់សម្លាប់ ធ្វើឱ្យមានរបួស ឬគំរាមកំហែង ។

ការប្រើប្រាស់សត្វដើម្បីសម្លាប់ ធ្វើឱ្យមានរបួស ឬគំរាមកំហែង ត្រូវចាត់ទុកដូចបានប្រើប្រាស់អាវុធដែរ ។

**មាត្រា ៨២.-** ការពួនស្ទាក់

ការពួនស្ទាក់ គឺជាអំពើឃ្លាំចាំជនរងគ្រោះនៅទីកន្លែងណាមួយ ក្នុងរយៈពេលមួយរយៈដើម្បីប្រព្រឹត្តបទល្មើស ។

# កថាភាគទី ២
# ការមិនរាងចាល

**មាត្រា ៨៣.-** អានុភាពនៃការមិនរាងចាល

ការមិនរាងចាលមានអានុភាព នាំឱ្យមានការបន្ថែមទម្ងន់អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទល្មើសឧក្រិដ្ឋ ឬមជ្ឈិម នៅក្នុងលក្ខខណ្ឌដែលមានចែងដោយកថាភាគនេះ ។

**មាត្រា ៨៤.-** លក្ខខណ្ឌនៃការមិនរាងចាល

ការមិនរាងចាលត្រូវបានកើតក្នុងករណីណាមួយដូចតទៅ :

១-កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទឧក្រិដ្ឋ បុគ្គលនោះបានប្រព្រឹត្តបទឧក្រិដ្ឋថ្មីទៀតនៅក្នុងរយៈពេល ១០ (ដប់) ឆ្នាំ ។

២-កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទឧក្រិដ្ឋ បុគ្គលនោះបានប្រព្រឹត្តបទមជ្ឈិមក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ។

៣-កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិម ដោយត្រូវជាប់ពន្ធនាគារស្មើ ឬលើសពី ៣ (បី) ឆ្នាំ បុគ្គលនោះបានប្រព្រឹត្តបទឧក្រិដ្ឋ ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ។

៤-កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិម បុគ្គលនោះបានប្រព្រឹត្តបទមជ្ឈិមដដែលនៅក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ។

រយៈពេល ១០ (ដប់) ឆ្នាំ និង ៥ (ប្រាំ) ឆ្នាំ ចាប់ផ្តើមគិតពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោសចំពោះបទល្មើសទី ១ ចូលជាស្ថាពរ ។

**មាត្រា ៨៥.-** ការមិនរាងចាលក្នុងបទឧក្រិដ្ឋ

កាលបើបុគ្គលណាមួយត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទឧក្រិដ្ឋ បុគ្គលនេះបានប្រព្រឹត្តបទឧក្រិដ្ឋណាមួយថ្មីទៀតនៅក្នុងរយៈពេល ១០ (ដប់) ឆ្នាំ អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋថ្មី ត្រូវបន្ថែមទម្ងន់តាមខ្នាតដូចតទៅ :

១-ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋថ្មីមិនលើសពី ២០ (ម្ភៃ) ឆ្នាំ ទេ អតិបរមានេះ ត្រូវទ្វេឡើង ។

២-ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋថ្មីនេះមាន រយៈពេល ៣០ (សាមសិប) ឆ្នាំ អតិបរមានៃទោស គឺដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ៨៦.-** ការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីការផ្តន្ទាទោសបទឧក្រិដ្ឋ

កាលបើបុគ្គលណាមួយ ត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទឧក្រិដ្ឋ ណាមួយ បុគ្គលនេះបានប្រព្រឹត្តបទមជ្ឈិមនៅក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ អតិបរមា នៃទោសដាក់ពន្ធនាគារចំពោះបទមជ្ឈិម ត្រូវទ្វេឡើង ។

តាមអានុភាពនៃការមិនរាងចាល ក្នុងករណីដែលអតិបរមានៃទោសដាក់ ពន្ធនាគារលើសពី ៥ (ប្រាំ) ឆ្នាំ បទល្មើសនៅតែជាបទមជ្ឈិមដដែល ទោះបីជាមាន ការបន្ថែមទម្ងន់ទោសយ៉ាងណាក៏ដោយ ។

**មាត្រា ៨៧.-** ការមិនរាងចាលក្នុងបទឧក្រិដ្ឋបន្ទាប់ពីការផ្តន្ទាទោសបទមជ្ឈិម

កាលបើបុគ្គលណាមួយ ត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិម ដាក់ពន្ធនាគារស្មើ ឬលើសពី ៣ (បី) ឆ្នាំ បុគ្គលនេះបានប្រព្រឹត្តបទឧក្រិដ្ឋ នៅក្នុង រយៈពេល ៥ (ប្រាំ) ឆ្នាំ ទោសដែលត្រូវផ្តន្ទាទោសលើបទឧក្រិដ្ឋនេះ ត្រូវបន្ថែមទម្ងន់ ទៅតាមខ្នាតដូចតទៅ :

១-ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋមិនលើសពី ២០ (ម្ភៃ) ឆ្នាំ ទេ អតិបរមានេះ ត្រូវទ្វេឡើង ។

២-ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋមានរយៈពេល ៣០ (សាមសិប) ឆ្នាំ អតិបរមានៃទោស គឺដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ៨៨.-** ការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីការផ្តន្ទាទោសបទមជ្ឈិម

កាលបើបុគ្គលណាមួយ ត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិម ណាមួយ បុគ្គលនេះបានប្រព្រឹត្តបទមជ្ឈិមដដែលនៅក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទមជ្ឈិមថ្មី ត្រូវទ្វេឡើង ។

តាមអានុភាពនៃការមិនរាងចាល ក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារលើសពី ៥ (ប្រាំ) ឆ្នាំ បទល្មើសនៅតែជាបទមជ្ឈិមដដែល ទោះបីជាមានការបន្ថែមទម្ងន់ទោសយ៉ាងណាក៏ដោយ ។

**មាត្រា ៨៩.-** ការប្រដូចបទល្មើស ដើម្បីបង្កើតឱ្យមានការមិនរាងចាល

ដើម្បីអនុវត្តបទប្បញ្ញត្តិស្ដីពីការមិនរាងចាល បទលួច បទរំលោភលើទំនុកចិត្ត និងបទឆបោក ត្រូវចាត់ទុកថាជាបទល្មើសដូចគ្នាដដែល ។

បទល្មើសទទួលផលចោរកម្ម ត្រូវប្រដូចជាបទល្មើសដែលជាប្រភពនៃទ្រព្យសម្បត្តិដែលទទួលលាក់បំបាំង ។

បទល្មើសសំអាតប្រាក់ ត្រូវប្រដូចជាបទល្មើសដែលការសំអាតប្រាក់នេះបានសម្រេច ។

**មាត្រា ៩០.-** ការមិនរាងចាល និងកិច្ចនៃការចោទប្រកាន់

ការមិនរាងចាលអាចត្រូវតុលាការជំនុំជម្រះកត់ត្រាទុក និងអាចជាមូលហេតុនៃការបន្ថែមទម្ងន់ទោសដាក់ពន្ធនាគារបាន ប្រសិនបើមានចែងយ៉ាងជាក់លាក់នៅក្នុងលិខិតចោទប្រកាន់ ។

**មាត្រា ៩១.-** ការមិនរាងចាល និងសេចក្ដីសម្រេចស្ថាពរ

សេចក្ដីសម្រេចត្រូវបានចាត់ទុកថាជាស្ថាពរ កាលណាសេចក្ដីសម្រេចនេះមិនអាចមានផ្លូវតវ៉ាបានទៀតឡើយ ។

ដើម្បីអនុវត្តបទប្បញ្ញត្តិស្ដីពីការមិនរាងចាល ត្រូវគិតគូរតែលើការផ្ដន្ទាទោសស្ថាពរខាងបណ្ដឹងអាជ្ញាប៉ុណ្ណោះ ។

**មាត្រា ៩២.-** បទប្បញ្ញត្តិដោយឡែក

ការមិនរាងចាលអាចត្រូវកត់ត្រាទុក ទោះបីទោសដែលកើតចេញពីការផ្ដន្ទាទោសនោះត្រូវផុតអាជ្ញាយុកាលក៏ដោយ ។

ការមិនរាងចាល មិនអាចត្រូវកត់ត្រាទុកទេ បើទោសដែលកើតចេញពីការផ្តន្ទាទោសស្ថាពរនោះ ត្រូវបានលើកលែងដោយអនុលោមតាមមាត្រា ៩០ ថ្មី (ពីរ) វាក្យខណ្ឌទី ៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

## ផ្នែកទី ២
## ស្ថានសម្រាលទោស

**មាត្រា ៩៣.-** និយមន័យនៃស្ថានសម្រាលទោស

កាលណាកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ តុលាការអាចសម្រេចឱ្យជនជាប់ចោទបានទទួលនូវស្ថានសម្រាលទោស ។

ស្ថានសម្រាលទោសអាចត្រូវផ្តល់ឱ្យជនជាប់ចោទបានដែរ ទោះបីជាជននោះត្រូវបានប្រកាសថា ស្ថិតនៅក្នុងភាពមិនរាងចាលក៏ដោយ ។

**មាត្រា ៩៤.-** អានុភាពនៃស្ថានសម្រាលទោស

កាលណាតុលាការផ្តល់ឱ្យជនជាប់ចោទនូវស្ថានសម្រាលទោស អប្បបរមានៃមូលទោសចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវបន្ថយតាមខ្នាតដូចខាងក្រោម :

១-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០ (ដប់) ឆ្នាំ អប្បបរមានៃទោសនេះ ត្រូវបន្ថយមកត្រឹម ២ (ពីរ) ឆ្នាំ ។

២-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៥ (ប្រាំ) ឆ្នាំ ហើយតិចជាង ១០ (ដប់) ឆ្នាំ អប្បបរមានៃទោសនេះ ត្រូវបន្ថយមកត្រឹម ១ (មួយ) ឆ្នាំ ។

៣-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២ (ពីរ) ឆ្នាំ ហើយតិចជាង ៥ (ប្រាំ) ឆ្នាំ អប្បបរមានៃទោសនេះ ត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ ។

៤-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៦ (ប្រាំមួយ) ថ្ងៃ ហើយតិចជាង ២ (ពីរ) ឆ្នាំ អប្បបរមានៃទោសនេះ ត្រូវបន្ថយមកត្រឹម ១ (មួយ) ថ្ងៃ ។

៥-អប្បបរមានៃទោសពិន័យ ត្រូវបន្ថយមកត្រឹមពាក់កណ្តាល ។

**មាត្រា ៩៥.-** ទោសដាក់ពន្ធនាគារអស់មួយជីវិត និងស្ថានសម្រាលទោស

កាលណាបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចៅក្រមដែលផ្តល់ស្ថានសម្រាលទោស អាចប្រកាសទោសដាក់ពន្ធនាគារ ក្នុងចន្លោះរវាង ១៥ (ដប់ប្រាំ) និង ៣០ (សាមសិប) ឆ្នាំ ។

## ជំពូកទី ៣

## របបនៃការប្រកាសទោស

### ផ្នែកទី ១

### របបទូទៅ

**មាត្រា ៩៦.-** គោលការណ៍ឯកត្តកម្មនៃទោស

តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ ចំពោះជនរងគ្រោះ ។

**មាត្រា ៩៧.-** ការប្រកាសមូលទោស

នៅក្នុងគ្រប់ករណីដែលបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យផង តុលាការអាចប្រកាស :

-ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ឬ

-ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ

-ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ ។

**មាត្រា ៩៨.-** ការប្រកាសទោសជំនួស

ទោសការងារសហគមន៍ជំនួសឱ្យមូលទោស ។ តុលាការដែលប្រកាសទោសការងារសហគមន៍នោះ មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ ។

ការស្ដីបន្ទោសជំនួសឱ្យមូលទោស ។ តុលាការដែលប្រកាសការស្ដីបន្ទោស មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ ។

**មាត្រា ៩៩.-** ការប្រកាសទោសបន្ថែមលើមូលទោស

កាលណាបទល្មើសមួយត្រូវផ្ដន្ទាទោសដោយទោសបន្ថែមមួយឬច្រើន ទោសបន្ថែមនេះត្រូវបន្ថែមទៅលើមូលទោស លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ១០០ (ការជំនួសមូលទោសដោយទោសបន្ថែម) នៃក្រមនេះ ចេញ ។

**មាត្រា ១០០.-** ការជំនួសមូលទោសដោយទោសបន្ថែម

តុលាការអាចសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយឬច្រើន នៅក្នុងករណីណាមួយដូចខាងក្រោម :

១-កាលណាជនជាប់ចោទទទួលទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់ ។

២-កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាស្មើ ឬតិចជាង ៣ (បី) ឆ្នាំ ។

កាលណាតុលាការសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬច្រើន តុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់បានទេ ។

**មាត្រា ១០១.-** វិធានដោយឡែកសម្រាប់ការប្រកាសទោសការងារសហគមន៍

ទោសការងារសហគមន៍នឹងអាចប្រកាសបាន លុះត្រាតែជនជាប់ចោទមានវត្តមាននៅពេលសវនាការ ហើយយល់ព្រមធ្វើការងារនេះ ។ តុលាការនៅមុនពេលប្រកាសសាលក្រម ឬសាលដីកា ត្រូវប្រាប់ជនជាប់ចោទថាសាមីខ្លួនមានសិទ្ធិប្រកែកមិនព្រមធ្វើការងារនេះ ។ ចម្លើយរបស់ជនជាប់ចោទ ត្រូវតែមានចុះនៅក្នុងសាលក្រម ឬសាលដីកា ។

**មាត្រា ១០២.-** ចិរវេលា និងអំឡុងពេលនៃការងារសហគមន៍

តុលាការដែលប្រកាសទោសការងារសហគមន៍ ត្រូវកំណត់អំពីចិរវេលានៃ

ការងារ និងរយៈពេលដែលត្រូវបំពេញ ។ រយៈពេលនេះមិនអាចលើសពី ១ (មួយ) ឆ្នាំ ទេ ។

**មាត្រា ១០៣.-** បែបបទនៃការអនុវត្តទោសការងារសហគមន៍

បែបបទនៃការអនុវត្តទោសការងារសហគមន៍ ត្រូវកំណត់ដោយព្រះរាជអាជ្ញា ។

ព្រះរាជអាជ្ញាចង្អុលប្រាប់ឈ្មោះនីតិបុគ្គល ដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះ ។

ទោសនេះត្រូវអនុវត្តនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ។

## ផ្នែកទី ២

## ការព្យួរទោសធម្មតា

### កថាភាគទី ១

### បទប្បញ្ញត្តិរួម

**មាត្រា ១០៤.-** ការប្រកាសការព្យួរទោស

នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងផ្នែកនេះ តុលាការអាចបង្គាប់ថា ត្រូវព្យួរការអនុវត្តនូវមូលទោស ។

**មាត្រា ១០៥.-** របបនៃការព្យួរទោស

ដើម្បីអនុវត្តបទប្បញ្ញត្តិស្ដីពីការព្យួរទោស ត្រូវគិតតែអំពីការផ្ដន្ទាទោសជាស្ថាពរខាងបណ្ដឹងអាជ្ញាប៉ុណ្ណោះ ។

### កថាភាគទី ២

### ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម

**មាត្រា ១០៦.-** លក្ខខណ្ឌទាក់ទងនឹងការផ្ដន្ទាទោសពីមុន

ក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ការព្យួរទោសធម្មតាអាចត្រូវផ្ដល់ឱ្យបាន ប្រសិនបើជនជាប់ចោទមិនទាន់មានការផ្ដន្ទាទោស

ជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ មុនអំពើល្មើស ។

**មាត្រា ១០៧.-** ទោសអាចនាំឱ្យមានការព្យួរទោស

ការព្យួរទោសធម្មតា ត្រូវអនុវត្តទៅលើទោសដូចតទៅ :

១-ទោសដាក់ពន្ធនាគារ កាលបើទោសដែលប្រកាសនោះតិចជាង ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ ។

២-ទោសពិន័យជាប្រាក់ ។

**មាត្រា ១០៨.-** ការព្យួរទោសមួយផ្នែក

តុលាការអាចសម្រេចថា ការព្យួរទោសធម្មតានេះអាចនឹងអនុវត្តទៅលើមួយផ្នែកនៃទោសពន្ធនាគារ ដែលតុលាការជាអ្នកកំណត់ចិរវេលា ឬលើមួយផ្នែកនៃប្រាក់ពិន័យដែលតុលាការជាអ្នកកំណត់ចំនួនទឹកប្រាក់ ។

**មាត្រា ១០៩.-** ការដកហូតការព្យួរទោស

ប្រសិនបើក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីការផ្ដន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតា ហើយមានការផ្ដន្ទាទោសថ្មីជាស្ថាពរមួយទៀតពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ការព្យួរទោសធម្មតានេះ ត្រូវដកហូតចេញដោយពេញច្បាប់ ។

ទោសទី ១ ត្រូវអនុវត្តដោយមិនអាចស្រូបចូលជាមួយទោសទី ២ បានឡើយ ។

**មាត្រា ១១០.-** ការមិនដកហូតការព្យួរទោស

ជាបដិប្បញ្ញត្តិទៅនឹងមាត្រា ១០៩ (ការដកហូតការព្យួរទោស) នៃក្រមនេះ តុលាការអាចសម្រេចថា ការផ្ដន្ទាទោសថ្មីមិននាំឱ្យមានការដកហូតនូវការព្យួរទោសធម្មតាដែលបានសម្រេចពីមុននោះទេ។ សេចក្ដីសម្រេចរបស់តុលាការត្រូវតែមានសំអាងហេតុជាពិសេស ។

**មាត្រា ១១១.-** ការទុកជាអសារបង់នូវការផ្ដន្ទាទោស

ប្រសិនបើរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីការផ្ដន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ

ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតា ហើយគ្មានការផ្ដន្ទាទោសថ្មីជាស្ថាពរមួយទៀត ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះទេ ការផ្ដន្ទាទោសដោយមានព្យួរនេះត្រូវចាត់ទុកថាជាអសារបង់ ។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ ។

កាលណាបើការព្យួរទោសត្រូវបានប្រកាសទៅលើតែផ្នែកមួយនៃទោសនោះ ការផ្ដន្ទាទោសត្រូវចាត់ទុកជាអសារបង់ទាំងស្រុង ។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ ។

## កថាភាគទី ៣
## ការចោទប្រកាន់ចំពោះបទលហុ

**មាត្រា ១១២.–** លក្ខខណ្ឌទាក់ទងទៅនឹងការផ្ដន្ទាទោសពីមុន

ក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសធម្មតាអាចត្រូវបានប្រកាស ប្រសិនបើជនជាប់ចោទ មិនទាន់ត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារជាស្ថាពរនៅឡើយ នៅក្នុងរយៈពេល ១ (មួយ) ឆ្នាំ មុនបទល្មើសនេះ ។

**មាត្រា ១១៣.–** ទោសអាចនាំឱ្យមានការព្យួរទោស

ក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសធម្មតាត្រូវអនុវត្តទៅលើទោសដូចតទៅនេះ :

១-ទោសដាក់ពន្ធនាគារ ។

២-ទោសពិន័យជាប្រាក់ ។

**មាត្រា ១១៤.–** ការដកហូតការព្យួរទោស

ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំ ក្រោយការផ្ដន្ទាទោសជាស្ថាពរពីបទលហុដោយមានការព្យួរទោសធម្មតាផង រួចកើតមានការផ្ដន្ទាទោសថ្មីជាស្ថាពរពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការព្យួរទោសធម្មតានេះ ត្រូវដកហូតចេញដោយពេញច្បាប់។ ទោសទី ១ ត្រូវអនុវត្តដោយគ្មានស្រួបជាមួយទោសទី ២ ឡើយ ។

**មាត្រា ១១៥.-** ការមិនដកហូតការព្យួរទោស

ជាបដិប្បញ្ញត្តិនៃមាត្រា ១១៤ (ការដកហូតការព្យួរទោស) នៃក្រមនេះ តុលាការអាចសម្រេចថា ការផ្តន្ទាទោសថ្មីមិនអាចនាំឱ្យមានការដកហូតនូវការព្យួរទោសធម្មតានេះដែលសម្រេចពីមុននោះទេ។ សេចក្តីសម្រេចនេះត្រូវតែមានសំអាងហេតុជាពិសេស។

**មាត្រា ១១៦.-** ការចាត់ទុកជាអសារបង់នូវការផ្តន្ទាទោស

ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទលហុដែលមានការព្យួរទោសធម្មតា គ្មានការផ្តន្ទាទោសថ្មីណាមួយបានកើតឡើងពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការផ្តន្ទាទោសដែលព្យួរនោះ ត្រូវទុកជាអសារបង់ ។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ ។

## ផ្នែកទី ៣

## ការព្យួរទោសសាកល្បង

**មាត្រា ១១៧.-** និយមន័យ និងលក្ខខណ្ឌនៃការព្យួរទោសសាកល្បង

តុលាការអាចសម្រេចព្យួរសាកល្បងនូវទោសដែលបានសម្រេចដាក់ពន្ធនាគារដែលមានរយៈពេលពី ៦ (ប្រាំមួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ ។

ការព្យួរទោសសាកល្បង មានអានុភាពដាក់ឱ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើនក្នុងរយៈពេលសាកល្បង ។

**មាត្រា ១១៨.-** រយៈពេលនៃការសាកល្បង

តុលាការកំណត់រយៈពេលនៃការសាកល្បង។ រយៈពេលនេះមិនអាចតិចជាង ១ (មួយ) ឆ្នាំ និងមិនលើសពី ៣ (បី) ឆ្នាំ ទេ ។

**មាត្រា ១១៩.-** វិធានការត្រួតពិនិត្យ

វិធានការត្រួតពិនិត្យដែលតម្រូវទៅលើទណ្ឌិត មានដូចតទៅ :

១-ទណ្ឌិតត្រូវតែគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬរបស់បុគ្គលដែល

ព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ ។

២-ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ ។

៣-ទណ្ឌិតត្រូវប្រគល់ដល់ព្រះរាជអាជ្ញា ឬដល់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ នូវគ្រប់ឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឱ្យទៅរស់នៅក្នុងសង្គមវិញ ។

៤-ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្លួន ។

៥-ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរមុខរបររបស់ខ្លួន ។

៦-ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស ។

**មាត្រា ១២០.-** កាតព្វកិច្ចដោយឡែកដែលអាចដាក់ទៅលើទណ្ឌិត

កាតព្វកិច្ចដោយឡែកដែលអាចតម្រូវទៅលើទណ្ឌិតមានដូចតទៅ :

១-បំពេញសកម្មភាពខាងវិជ្ជាជីវៈ ។

២-ទទួលការបង្ហាត់បង្រៀន ឬទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

៣-រស់នៅក្នុងទីកន្លែងណាមួយជាកំណត់ ។

៤-ទទួលឱ្យពេទ្យធ្វើការពិនិត្យ ឬការព្យាបាល ។

៥-បញ្ជាក់ថាខ្លួនរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ ។

៦-ធ្វើការជួសជុលការខូចខាតដែលបណ្តាលមកពីបទល្មើស តាមលទ្ធភាពនៃធនធានរបស់ខ្លួន ។

៧-បញ្ជាក់ថាខ្លួនបានបង់ប្រាក់ជូនរដ្ឋបន្ទាប់ពីការផ្តន្ទាទោស តាមលទ្ធភាពធនធានរបស់ខ្លួន ។

៨-មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈឬសង្គមដែលអនុញ្ញាត ឬសម្រួលដល់ការប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីសកម្មភាពដែលហាមឃាត់ ។

៩-មិនត្រូវមានមុខនៅទីកន្លែងខ្លះ។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីទីកន្លែងដែលហាមឃាត់ ។

១០-មិនត្រូវសេពគប់បនល្បែង ។

១១-មិនត្រូវសេពគប់គៀមភេសជ្ជៈស្រវឹង ។

១២-មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ពិសេស ចារី សហចារី អ្នកផ្ដើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីបុគ្គលដែលមិនត្រូវសេពគប់ជាមួយ ។

១៣-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន តុលាការត្រូវចែងអំពីកាតព្វកិច្ចដោយឡែកដែលតម្រូវទៅលើទណ្ឌិត ។

**មាត្រា ១២១.-** ការកែប្រែកាតព្វកិច្ចដោយឡែកដោយយុត្តាធិការ

នៅគ្រប់ពេលវេលា តុលាការអាចកែប្រែកាតព្វកិច្ចដោយឡែកដែលតម្រូវលើទណ្ឌិតបាន ។

តុលាការត្រូវបានទទួលបណ្ដឹងនៅក្នុងលក្ខខណ្ឌដែលបានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១២២.-** ការដកហូតការព្យួរទោសសាកល្បង

ការព្យួរទោសសាកល្បងអាចត្រូវដកហូតដោយតុលាការ នៅក្នុងករណីដូចខាងក្រោមនេះ :

១-ប្រសិនបើក្នុងរយៈពេលសាកល្បង ទណ្ឌិតមិនគោរពតាមវិធានការត្រួតពិនិត្យ ឬកាតព្វកិច្ចដោយឡែកទេ ។

២-ប្រសិនបើក្នុងរយៈពេលសាកល្បង ទណ្ឌិតត្រូវបានផ្ដន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាថ្មីទៀត ។

តុលាការអាចបង្គាប់ឱ្យដកហូតការព្យួរទោសសាកល្បងនេះទាំងមូល ឬមួយផ្នែក ។ នៅក្នុងករណីនេះ ទោសត្រូវយកមកអនុវត្តទាំងមូល ឬមួយផ្នែក ។

តុលាការត្រូវបានទទួលបណ្តឹងនៅក្នុងលក្ខខណ្ឌដែលមានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១២៣.-** ការផ្តន្ទាទោសដែលត្រូវចាត់ទុកជាអសារបង់

ការផ្តន្ទាទោសត្រូវចាត់ទុកជាអសារបង់ ប្រសិនបើមុនការផុតរយៈពេលសាកល្បង ការផ្តន្ទាទោសមិនមែនជាកម្មវត្ថុនៃពាក្យសុំដកហូតដែលមានសេចក្តីសម្រេចដកហូតទេ ។

## ផ្នែកទី ៤

## ការផ្អាកការប្រកាសទោស

**មាត្រា ១២៤.-** លក្ខខណ្ឌនៃការផ្អាកការប្រកាសទោស

ក្នុងករណីចោទប្រកាន់ពីបទមជ្ឈិម តុលាការក្រោយពីបានប្រកាសថា ជនជាប់ចោទមានពិរុទ្ធ អាចផ្អាកការប្រកាសទោស ប្រសិនបើលក្ខខណ្ឌដូចតទៅនេះ ត្រូវបានបំពេញ :

-ភាពច្របូកច្របល់នៃសណ្តាប់ធ្នាប់សាធារណៈ ដែលបង្កឡើងដោយបទល្មើសត្រូវបានបញ្ឈប់

-ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ និង

-ជនជាប់ចោទសុំរយៈពេលដើម្បីជួសជុលការខូចខាត ។

**មាត្រា ១២៥.-** សេចក្តីសម្រេចនៃការផ្អាកការប្រកាសទោស

ការផ្អាកការប្រកាសទោសអាចត្រូវបង្គាប់បាន លុះត្រាតែជនជាប់ចោទមានវត្តមានក្នុងសវនាការ ។

តុលាការកំណត់នៅក្នុងសាលក្រម ឬសាលដីកានូវកាលបរិច្ឆេទដែលត្រូវសម្រេចអំពីទោស ។

សេចក្តីសម្រេចអំពីទោសត្រូវតែធ្វើឡើងយ៉ាងយូរបំផុត ១ (មួយ) ឆ្នាំ ក្រោយសេចក្តីសម្រេចផ្អាក ។

**មាត្រា ១២៦.-** សវនាការពិនិត្យរឿងដែលបង្អង់

នៅពេលសវនាការពិនិត្យរឿងដែលបង្អង់នេះ តុលាការសម្រេចអំពីទោស ។

## ផ្នែកទី ៥
## របបពាក់កណ្ដាលសេរីភាព

**មាត្រា ១២៧.-** លក្ខខណ្ឌនៃរបបពាក់កណ្ដាលសេរីភាព

កាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ៦ (ប្រាំមួយ) ខែ តុលាការអាចសម្រេចថា ទោសត្រូវអនុវត្តក្រោមរបបពាក់កណ្ដាលសេរីភាព ដើម្បីអនុញ្ញាតឱ្យទណ្ឌិតអាចបំពេញសកម្មភាពវិជ្ជាជីវៈ ទទួលការសិក្សា ឬការបណ្ដុះបណ្ដាល ឬការពិនិត្យព្យាបាលជំងឺ ឬជួយឧបត្ថម្ភដល់សេចក្ដីត្រូវការរបស់គ្រួសារ ។

**មាត្រា ១២៨.-** បែបបទនៃរបបពាក់កណ្ដាលសេរីភាព

ទណ្ឌិតដែលស្ថិតនៅក្រោមរបបពាក់កណ្ដាលសេរីភាព ត្រូវបានអនុញ្ញាតឱ្យចាកចេញពីពន្ធនាគារ ក្នុងរយៈពេលជាកំណត់ ។

តុលាការកំណត់នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនអំពីថ្ងៃ និងម៉ោងដែលទណ្ឌិតត្រូវបានអនុញ្ញាតឱ្យមានអវត្តមាននៅក្នុងពន្ធនាគារ ។

**មាត្រា ១២៩.-** ការគិតបញ្ចូលរយៈពេលនៃពាក់កណ្ដាលសេរីភាពទៅក្នុងទោស

រយៈពេលនៃពាក់កណ្ដាលសេរីភាព ត្រូវគិតបញ្ចូលទៅក្នុងថិរវេលានៃទោសដែលកំពុងអនុវត្ត ។

**មាត្រា ១៣០.-** ការរៀបចំ និងការលុបចោលនៃរបបពាក់កណ្ដាលសេរីភាព

នៅគ្រប់ពេល តុលាការអាចរៀបចំរយៈពេលនៃពាក់កណ្ដាលសេរីភាព ឬក៏លុបចោលនូវរបបពាក់កណ្ដាលសេរីភាព តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា ។

តុលាការត្រូវបានទទួលដំណឹងនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១៣១.-** ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនវិលត្រឡប់មកពន្ធនាគារវិញ នៅពេលផុតកំណត់រយៈពេលនៃពាក់កណ្ដាលសេរីភាព ។

## ផ្នែកទី ៦

## ការបែងចែកទោសជាប្រភាគ

**មាត្រា ១៣២.-** លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ

កាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ១ (មួយ) ឆ្នាំ តុលាការអាចសម្រេចថា ទោសនោះត្រូវអនុវត្តជាប្រភាគ ដោយមូលហេតុធ្ងន់ធ្ងរដែលមានលក្ខណៈជាគ្រួសារ ជាវេជ្ជសាស្ត្រ ជាវិជ្ជាជីវៈ ឬជាសង្គម។

**មាត្រា ១៣៣.-** បែបបទនៃការបែងចែកទោសជាប្រភាគ

ប្រភាគនៃទោសនីមួយៗ មិនត្រូវតិចជាង ១ (មួយ) ខែ ទេ ។ ចិរវេលាសរុបនៃការអនុវត្តទោសមិនអាចលើសពី ២ (ពីរ) ឆ្នាំ ទេ ដោយរាប់បញ្ចូលទាំងការផ្អាកការអនុវត្តទោស ។

តុលាការកំណត់ក្នុងសេចក្ដីសម្រេចរបស់ខ្លួនអំពីបែបបទនៃការបែងចែកទោសជាប្រភាគ ។

**មាត្រា ១៣៤.-** ការកែប្រែរបបនៃការបែងចែកទោសជាប្រភាគ

នៅគ្រប់ពេលវេលា តុលាការអាចរៀបចំបែបបទនៃការបែងចែកទោសជាប្រភាគ ឬលុបចោលរបបនៃការបែងចែកទោសជាប្រភាគ តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា ។

តុលាការត្រូវបានទទួលបណ្ដឹងនៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១៣៥.-** ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនវិលត្រឡប់មក

ពន្ធនាគារវិញ នៅពេលផុតកំណត់រយៈពេលនៃការផ្អាកការអនុវត្តទោស ។

# ជំពូកទី ៤
# វិធានអនុវត្តនៅក្នុងករណីបទល្មើសត្រួតគ្នា
## ផ្នែកទី ១
## វិធានទូទៅ

**មាត្រា ១៣៦.-** បទល្មើសត្រួតគ្នា

មានបទល្មើសត្រួតគ្នាកើតឡើង កាលបើបទល្មើសមួយត្រូវបានប្រព្រឹត្តដោយបុគ្គលម្នាក់ មុនពេលដែលបុគ្គលនេះត្រូវបានផ្តន្ទាទោសជាស្ថាពរចំពោះបទល្មើសមួយផ្សេងទៀត ។

**មាត្រា ១៣៧.-** ការចោទប្រកាន់តែមួយ

កាលបើនៅក្នុងពេលចោទប្រកាន់តែមួយ ជនជាប់ចោទត្រូវបានគេរកឃើញថាមានពិរុទ្ធពីបទល្មើសច្រើន ទោសនីមួយៗអាចត្រូវប្រកាសឡើង ។ ប៉ុន្តែ កាលបើទោសត្រូវទទួលមានច្រើន ហើយមានប្រភេទដូចគ្នា តុលាការត្រូវប្រកាសទោសតែមួយនៃប្រភេទនេះ នៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ។

ទោសនីមួយៗ ដែលប្រកាសត្រូវចាត់ទុកថាជាទោសរួម ចំពោះបទល្មើសដែលត្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ អនុវត្តទៅលើបទល្មើសនីមួយៗ ។

**មាត្រា ១៣៨.-** ការចោទប្រកាន់ដាច់ពីគ្នា

នៅក្នុងពេលចោទប្រកាន់ដាច់ពីគ្នា កាលបើជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធពីបទល្មើសច្រើន ទោសដែលត្រូវប្រកាស ត្រូវអនុវត្តត្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ។ ប៉ុន្តែ តុលាការចុងក្រោយដែលត្រូវសម្រេច អាចប្រកាសឱ្យអនុវត្តទោសស្រូបបញ្ចូលគ្នាទាំងមូល ឬមួយផ្នែកនៃទោសដែលមានប្រភេទដូចគ្នា ។

ដើម្បីអនុវត្តមាត្រានេះ នៅក្នុងករណីទោសដែលច្បាប់កំណត់ ជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ត្រូវបានកំណត់ដាក់ពន្ធនាគារត្រឹម ៣០ (សាមសិប) ឆ្នាំ ប្រសិនបើជនជាប់ចោទមិនទាន់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតទេ ។

ការព្យួរទោសទាំងមូល ឬមួយផ្នែកនៃទោសដែលប្រកាសចំពោះបទល្មើសដែលត្រួតគ្នានេះ មិនអាចជាឧបសគ្គដល់ការអនុវត្តទោសនៃប្រភេទដូចគ្នាដែលគ្មានការព្យួរទោសទេ ។

## ផ្នែកទី ២

## វិធានដោយឡែក

**មាត្រា ១៣៩.-** អានុភាពនៃការលើកលែងទោស និងការបន្ធូរបន្ថយទោសលើការស្រូបទោស

កាលបើទោសជាកម្មវត្ថុនៃវិធានការលើកលែងទោស និងបន្ធូរបន្ថយទោសដូចមានចែងក្នុងមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវតែគិតគូរអំពីទោសដែលជាលទ្ធផលនៃការលើកលែងទោស និងបន្ធូរបន្ថយទោស ដើម្បីអនុវត្តវិធានស្តីពីការស្រូបបញ្ចូលគ្នានៃទោស ។

ចិរវេលានៃការបន្ធូរបន្ថយទោស ត្រូវរាប់បញ្ចូលទៅក្នុងចិរវេលានៃទោសទៅថ្ងៃមុខ ក្រោយការស្រូបទោស ។

**មាត្រា ១៤០.-** ការបូកបញ្ចូលគ្នានៃទោសពិន័យ

ជាបដិប្បញ្ញត្តិទៅលើបទប្បញ្ញត្តិមុន ការពិន័យដែលបានប្រកាសឡើង ចំពោះបទលហុច្រើននោះ ត្រូវបូកបញ្ចូលគ្នា ហើយត្រូវបូកផងដែរជាមួយទោសពិន័យដែលប្រកាសឡើងចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម ។

**មាត្រា ១៤១.-** ការមិនស្រូបចូលនៃទោសដែលត្រូវបានប្រកាសចំពោះករណីរត់ចេញពីពន្ធនាគារ

ក្នុងករណីផ្តន្ទាទោសពីបទរត់ចេញពីពន្ធនាគារ ទោសដែលប្រកាសពីបទនេះ

ត្រូវរួបរួមជាមួយនឹងទោសដែលប្រកាសឡើង ចំពោះបទល្មើសដែលនាំឱ្យមានការឃុំខ្លួនជននោះ ដោយមិនអាចមានការស្រូបចូលគ្នា ។

## ជំពូកទី ៥

## មូលហេតុទូទៅដែលមានផលប៉ះពាល់ដល់ការអនុវត្តទោស

## ផ្នែកទី ១

## អាជ្ញាយុកាលនៃទោស

**មាត្រា ១៤២.-** អានុភាពនៃអាជ្ញាយុកាល

នៅពេលផុតអាជ្ញាយុកាលហើយ ទោសលែងអនុវត្តបានទៀតហើយ ។

**មាត្រា ១៤៣.-** ភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះបទឧក្រិដ្ឋមួយចំនួន

ទោសដែលប្រកាសពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម មិនអាចផុតរលត់អាជ្ញាយុកាលទេ ។

ក្រៅពីបទល្មើសខាងលើ ច្បាប់ពិសេសអាចកំណត់អំពីភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះបទឧក្រិដ្ឋផ្សេងទៀតបាន ។

**មាត្រា ១៤៤.-** អាជ្ញាយុកាលនៃទោស

ទោសដែលប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ (ម្ភៃ) ឆ្នាំ ។

ទោសដែលប្រកាសពីបទមជ្ឈិមមានអាជ្ញាយុកាល ៥ (ប្រាំ) ឆ្នាំ ។

ទោសដែលប្រកាសពីបទលហុមានអាជ្ញាយុកាល ១ (មួយ) ឆ្នាំ ។

**មាត្រា ១៤៥.-** ចំណុចចាប់ផ្តើមនៃថិរវេលា

ថិរវេលា ២០ (ម្ភៃ) ឆ្នាំ ៥ (ប្រាំ) ឆ្នាំ និង ១ (មួយ) ឆ្នាំ ខាងលើ ដែលមានចែងនៅក្នុងមាត្រា ១៤៤ (អាជ្ញាយុកាលនៃទោស) នៃក្រមនេះ ចាប់គិតពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោស បានក្លាយទៅជាស្ថាពរ ។

**មាត្រា ១៤៦.-** អាជ្ញាយុកាលនៃកាតព្វកិច្ចរដ្ឋប្បវេណីដែលកើតចេញពីសេចក្តីសម្រេចព្រហ្មទណ្ឌ

កាតព្វកិច្ចដែលមានប្រភេទជារដ្ឋប្បវេណី និងដែលមានប្រភពចេញមកពីសេចក្តីសម្រេចព្រហ្មទណ្ឌដែលក្លាយជាស្ថាពរ ផុតអាជ្ញាយុកាលតាមវិធាននៃក្រមរដ្ឋប្បវេណី ។

## ផ្នែកទី ២

## ការអនុគ្រោះទោស

**មាត្រា ១៤៧.-** អានុភាពនៃការអនុគ្រោះទោស

ការអនុគ្រោះទោសដោយការបន្ធូរបន្ថយទោស ឬការលើកលែងទោសដោយអនុលោមតាមមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លើកលែងឱ្យទណ្ឌិតរួចផុតពីការអនុវត្តទោសដែលអនុគ្រោះនោះ ។

**មាត្រា ១៤៨.-** ការជួសជុលការខូចខាតដល់ជនរងគ្រោះក្នុងករណីនៃការអនុគ្រោះទោស

ការអនុគ្រោះទោសមិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលសំណងជួសជុលការខូចខាតទេ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយនៃព្រះរាជក្រឹត្យដែលពាក់ព័ន្ធនឹងការអនុគ្រោះទោសនោះ។

## ផ្នែកទី ៣

## ការលើកលែងទោសជាទូទៅ

**មាត្រា ១៤៩.-** អានុភាពនៃការលើកលែងទោសជាទូទៅ

ការលើកលែងទោសជាទូទៅដូចមានចែងក្នុងមាត្រា ៩០ ថ្មី (ពីរ) វាក្យខណ្ឌទី ៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លុបបំបាត់ចោលនូវទណ្ឌកម្មដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

ទោសមិនអាចយកមកអនុវត្តទេ ។

ទោសដែលកំពុងអនុវត្ត ត្រូវបានបញ្ចប់ ។

ប៉ុន្តែ ចំពោះប្រាក់ពិន័យ និងប្រាក់ប្រដាប់ក្តី ដែលបានបង់រួចហើយ មិនអាចទារសំណងពីរដ្ឋវិញបានទេ ។

**មាត្រា ១៥០.-** ការលើកលែងទោសជាទូទៅ និងការដកការព្យួរទោស

កាលបើការព្យួរទោសពីមុន ត្រូវបានដកហូតដោយអានុភាពនៃការផ្តន្ទាទោសខាងក្រោយ ការលើកលែងទោសជាទូទៅចំពោះទោសខាងក្រោយនេះ បង្កើតឡើងវិញនូវផលប្រយោជន៍នៃការព្យួរទោសដែលមានពីមុន ។

**មាត្រា ១៥១.-** ការជួសជុលការខូចខាតដល់ជនរងគ្រោះក្នុងករណីនៃការលើកលែងទោសជាទូទៅ

លើកលែងតែបទប្បញ្ញត្តិផ្ទុយនៃច្បាប់ ការលើកលែងទោសជាទូទៅ មិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលសំណងការជួសជុលនៃការខូចខាតឡើយ ។

## ផ្នែកទី ៤
## ការរៀបចំទោស និងការលុបចោលទោសបន្ថែមខ្លះៗ

**មាត្រា ១៥២.-** លក្ខខណ្ឌនៃការកែប្រែទោសបន្ថែមខ្លះៗ

ក្នុងករណីផ្តន្ទាទោសបន្ថែមដែលមានចែងនៅក្នុងចំណុច ១, ២, ៣, ៤, ៥, ៦, ៧, ១៤, ១៥ និង ១៦ នៃមាត្រា ៥៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមនេះ តុលាការអាចបង្គាប់ឱ្យរៀបចំកែប្រែ ឬលុបចោលទោសមួយ ឬច្រើន ប្រសិនបើលក្ខខណ្ឌដូចតទៅនេះ ត្រូវបានបំពេញ :

-ភាពច្របូកច្របល់ដល់សណ្តាប់ធ្នាប់សាធារណៈ ដែលបណ្តាលមកពីបទល្មើសបានបញ្ឈប់

-ព្យសនកម្ម ត្រូវបានជួសជុល និង

-សេចក្តីសម្រេចរៀបចំកែប្រែ ឬលុបចោល មានលក្ខណៈអនុគ្រោះឱ្យធ្វើការបញ្ចូលជនល្មើសទៅរស់នៅក្នុងសង្គមវិញ ។

តុលាការទទួលពាក្យប្តឹងពីអយ្យការតាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ឬតាមពាក្យប្តឹងរបស់ទណ្ឌិត ។ តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្តាប់យោបល់របស់តំណាងអយ្យការ ទណ្ឌិត និងជាយថាហេតុ មេធាវីរបស់ជននេះ ។

**មាត្រា ១៥៣.-** ការធ្វើឱ្យមានឡើងវិញនូវសិទ្ធិពលរដ្ឋទាំងអស់ ឬខ្លះៗ

ក្នុងករណីដកសិទ្ធិពលរដ្ឋ តុលាការអាចធ្វើឱ្យមានឡើងវិញនូវសិទ្ធិពលរដ្ឋទាំងអស់ដែលរៀបរាប់នៅមាត្រា ៩៥ (សិទ្ធិពលរដ្ឋដែលអាចដកបាន) នៃក្រមនេះ ឬក៏សិទ្ធិខ្លះក្នុងចំណោមសិទ្ធិទាំងនេះ ។

**មាត្រា ១៥៤.-** ការរៀបចំកែប្រែ ឬការលុបចោលនូវការហាមឃាត់

តុលាការអាចរៀបចំកែប្រែ ឬលុបចោលនូវ :

១-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ ឬសកម្មភាពសង្គម ។

២-ការហាមឃាត់ចំពោះការបើកបរយានយន្ត ។

**មាត្រា ១៥៥.-** ការប្រគល់ឱ្យវិញនូវលិខិតបើកបរ

ក្នុងករណីព្យួរលិខិតបើកបរ តុលាការអាចបង្គាប់ឱ្យប្រគល់លិខិតបើកបរនេះទៅម្ចាស់វិញ ។

**មាត្រា ១៥៦.-** ការកែប្រែវិធានការនៃការហាមឃាត់ចំពោះការស្នាក់នៅ

ក្នុងករណីផ្តន្ទាទោសហាមឃាត់ចំពោះការស្នាក់នៅ តុលាការអាចកែប្រែបែបបទនៃវិធានការតាមដាន ។

ក្នុងករណីបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យស្នាក់នៅជាបណ្តោះអាសន្នសម្រាប់រយៈពេលដែលមិនអាចលើសពី ៨ (ប្រាំបី) ថ្ងៃ នៅក្នុងទីកន្លែងដែលហាមឃាត់ ។ ព្រះរាជអាជ្ញាជូនព័ត៌មានអំពីកិច្ចនេះដល់តុលាការ ។

សេចក្តីសម្រេចរបស់តុលាការ និងព្រះរាជអាជ្ញា ត្រូវបានជូនដំណឹងដល់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ។

**មាត្រា ១៥៧.-** ការកែប្រែការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា

តុលាការអាចលុបចោលការហាមឃាត់ ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ តុលាការអាចគ្រោងទុកនូវលក្ខខណ្ឌខ្លះៗ ប្រសិនបើយល់ឃើញថាជាការចាំបាច់ ។

**មាត្រា ១៥៨.-** ការកែប្រែការហាមឃាត់ការចូលមកក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា

តុលាការអាចលុបចោលការហាមឃាត់ចំពោះការស្នាក់នៅ និងការចូលក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាដល់ទណ្ឌិតបរទេស ។

ប៉ុន្តែ ជាបឋម ព្រះរាជអាជ្ញាត្រូវតែទទួលយោបល់ពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជូនដំណឹងអំពីយោបល់នេះទៅតុលាការ ។

យោបល់នេះមិនបង្ខំឱ្យតុលាការត្រូវតែអនុវត្តតាមទេ ។

**មាត្រា ១៥៩.-** ការកែប្រែការបណ្តេញចេញ ការបិទ ការហាមឃាត់ការធ្វើអាជីវកម្ម

តុលាការអាចរៀបចំកែប្រែទោស ឬបញ្ចប់នូវទោសដូចខាងក្រោមនេះ :

១-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

២-ការបិទគ្រឹះស្ថាន ។

៣-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន ។

# ជំពូកទី ៦
# ទោសដែលអាចអនុវត្តចំពោះអនីតិជន
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦០.-** មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ

កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ :

១-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។

២-ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ ។

៣-អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ ។

៤-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមចិរវេលាមួយស្មើ ឬតិចជាង ៥ (ប្រាំ) ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល ។

**មាត្រា ១៦១.-** ទោសបន្ថែម

មានតែទោសបន្ថែមដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជន :

១-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

២-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

**មាត្រា ១៦២.-** ទោសការងារសហគមន៍

ទោសដែលជាការងារសហគមន៍ អាចអនុវត្តទៅលើអនីតិជនដែលមានអាយុយ៉ាងតិច ១៦ (ដប់ប្រាំមួយ) ឆ្នាំ ប៉ុន្តែ ចិរវេលានៃការងារមិនអាចលើសពី ១០០ (មួយរយ) ម៉ោង ។

ការងារសហគមន៍ត្រូវតែសម្របសម្រួលទៅលើអនីតិជន មានលក្ខណៈជាការបណ្ដុះបណ្ដាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ ។

**មាត្រា ១៦៣.-** ការមិនអនុវត្តបទប្បញ្ញត្តិស្ដីពីការមិនរាងចាល

បទប្បញ្ញត្តិស្ដីពីការមិនរាងចាល មិនអនុវត្តទៅលើអនីតិជនទេ ។

**មាត្រា ១៦៤.-** ការទទួលប្រយោជន៍នៃស្ថានសម្រាលទោស

ស្ថានសម្រាលទោសត្រូវអនុវត្តទៅលើអនីតិជន ។

កាលបើតុលាការបានសម្រេចឱ្យមានស្ថានសម្រាលទោស អប្បបរមានៃមូលទោស លើអនីតិជនពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវបន្ថយតាមខ្នាតដោយឡែកដូចតទៅ :

១-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកនៅត្រឹម ១ (មួយ) ឆ្នាំ ។

២-ប្រសិនបើអប្បបរមានៃទោសជាប់ពន្ធនាគារស្មើ ឬលើសពី ៥ (ប្រាំ) ឆ្នាំ និងតិចជាង ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ ។

៣-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២ (ពីរ) ឆ្នាំ និងតិចជាង ៥ (ប្រាំ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៣ (បី) ខែ ។

# ឧបសម្ព័ន្ធទី២

# ក្រមនីតិវិធីព្រហ្មទណ្ឌ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

# ព្រះរាជក្រម

នស/រកម/០៨០៧/០២៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១៩៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាម ទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ព្រះរាជអាជ្ញាប្រើប្រាស់អំណាចទាំងអស់ដែលក្រមនេះបានទទួលស្គាល់ ឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត ។

ព្រះរាជអាជ្ញាអាចចុះទៅកាន់កន្លែងស៊ើបអង្កេត និងធ្វើគ្រប់ការណែនាំដែលមានប្រយោជន៍ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ។ ក្នុងករណីចាំបាច់ពិសេស ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំជំនួសមន្ត្រី និងភ្នាក់ងារនេះ ។

ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលា នៅអង្គភាពនគរបាលយុត្តិធម៌ ។ ព្រះរាជអាជ្ញាអាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេសគឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន ។

**មាត្រា ៣៨.** – អំណាចរបស់ព្រះរាជអាជ្ញារង

ព្រះរាជអាជ្ញារងដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើស ។

**មាត្រា ៣៩.** – សមត្ថកិច្ចតាមដែនដីរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចគឺ ៖

-ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តិបទល្មើស

-ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនដែលគេសង្ស័យថា បានប្រព្រឹត្តបទល្មើស

-ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថា បានប្រព្រឹត្តបទល្មើស ។

## ផ្នែកទី ២
## ការអនុវត្តបណ្តឹងអាជ្ញា

**មាត្រា ៤០.** – ជម្រើសនៃការចោទប្រកាន់

ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹង និងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ។

ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ។ មុននឹងសម្រេចព្រះរាជអាជ្ញាបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម ។

ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរ ព្រះរាជអាជ្ញារាយការណ៍ជូនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដែលត្រូវរាយការណ៍បន្តជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៤១.** – ការតម្កល់រឿងទុកឥតចាត់ការ

កាលណាបណ្តឹងណាមួយត្រូវបានតម្កល់ទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងដល់អ្នកប្តឹង

អំពីសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃចុះពាក្យប្តឹងក្នុងបញ្ជីដែលមានចែងក្នុងមាត្រា ៥០ (បញ្ជីនៃពាក្យប្តឹង) នៃក្រមនេះ ។

ការតម្កល់រឿងទុកឥតចាត់ការ ត្រូវតែមានសំអាងច្បាប់ និងសំអាងហេតុ ។ ការតម្កល់ទុកឥតចាត់ការនេះគ្មានអាជ្ញាអស់ជំនុំទេ ។

ព្រះរាជអាជ្ញាអាចសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនវិញ ក្នុងខណៈដែលបណ្តឹងអាជ្ញាមិនទាន់ផុតរលត់នៅឡើយ ។

ប្រសិនបើអ្នកប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការទេ សាមីខ្លួនអាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន ។

ការតវ៉ានេះត្រូវធ្វើនៅក្នុងរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃទទួលដំណឹងអំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ ។ ការតវ៉ានេះត្រូវធ្វើតាមបណ្តឹងសាមញ្ញ នៅអង្គការអយ្យការដែលពាក់ព័ន្ធ ។ បន្ទាប់មកសំណុំរឿងត្រូវបានបញ្ជូនភ្លាម ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដោយតំណាងអយ្យការអមសាលាដំបូង ។

ប្រសិនបើយល់ឃើញថា ការតវ៉ានេះមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចេញអធិបញ្ញាដល់ព្រះរាជអាជ្ញាអមសាលាដំបូង ឱ្យធ្វើការចោទប្រកាន់ ។ អគ្គព្រះរាជអាជ្ញាធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរ ។ នៅក្នុងករណីផ្ទុយពីនេះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកជាបានការ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវឱ្យដំណឹងអំពីសេចក្តីសម្រេចនេះ ដល់អ្នកប្តឹងតវ៉ា ។

### មាត្រា ៤២. – កាតព្វកិច្ចធ្វើបណ្តឹងបរិហារចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម

អាជ្ញាធរសាធារណៈ ឬមន្ត្រីគ្រប់រូបដែលនៅក្នុងការបំពេញមុខងាររបស់ខ្លួន បានដឹងអំពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា ឬដល់មន្ត្រីនគរបាលយុត្តិធម៌ ដោយត្រូវបញ្ជូននូវព័ត៌មាន កំណត់ហេតុ លិខិត និងវត្ថុតាងទាំងអស់ ដែលទាក់ទងនឹងបទល្មើសនោះភ្ជាប់ជាមួយផង ។

មិនអាចមានការលើកលែងផ្សេងៗណា ក្រៅពីការលើកលែងស្តីអំពីអាថិកំបាំងខាងវិជ្ជាជីវៈក្នុងករណីដែលច្បាប់បានចែងយ៉ាងជាក់លាក់នោះទេ ។

### មាត្រា ៤៣. – ការចោទប្រកាន់

ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌអាចធ្វើតាម :

-ការបើកធ្វើការស៊ើបសួរ

-ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ

-តាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ។

**មាត្រា ៤៤.** - ការបើកការស៊ើបសួរ

ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ ។

ការស៊ើបសួរត្រូវបានបើកតាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ដែលត្រូវប្ដឹងទៅចៅក្រមស៊ើបសួរ ។ ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន ។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួររួមមាន :

-សេចក្ដីសង្ខេបនៃអង្គហេតុ

-ការកំណត់ឈ្មោះបទល្មើស

-ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង

-ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន ។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ។

ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ ។

**មាត្រា ៤៥.** - ការចោទប្រកាន់ក្នុងករណីបទមជ្ឈិម

ក្នុងករណីបទមជ្ឈិម ព្រះរាជអាជ្ញាអាច :

-បើកការស៊ើបសួរដោយធ្វើដូចដែលបានចែងដោយមាត្រា ៤៤ (ការបើកការស៊ើបសួរ) នៃក្រមនេះ

-បញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់ នៅមុខតុលាការជាន់ដំបូង ដោយធ្វើដូចបានចែងនៅក្នុងមាត្រា ៤៦ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់) នៃក្រមនេះ ឬ

-បង្គាប់ឱ្យនាំជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូង ដោយធ្វើដូចដែលបានចែងក្នុងមាត្រា ៤៧ (ការបង្ហាញខ្លួនភ្លាម) និងមាត្រា ៤៨ (នីតិវិធីនៃការបង្ហាញខ្លួនភ្លាម) នៃក្រមនេះ ។

**មាត្រា ៤៦.** - ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាបញ្ជាឱ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង ។ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់រួមមាន :

-អត្តសញ្ញាណនៃជនជាប់ចោទ

-សេចក្ដីសង្ខេបនៃអង្គហេតុ

-ឈ្មោះបទល្មើស

-អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស ។

ដីកានេះត្រូវចង្អុលប្រាប់ពីតុលាការ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការ ។ ដីកានេះត្រូវបញ្ជាក់ថា ជនជាប់ចោទអាចពឹងមេធាវីឱ្យអមខ្លួនបាន ។

**មាត្រា ៤៧. - ការបង្ហាញខ្លួនភ្លាម**

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាម នៅមុខតុលាការជាន់ដំបូង ប្រសិនបើមានគ្រប់លក្ខខណ្ឌដូចតទៅ :

-បទល្មើសជាបទល្មើសជាក់ស្តែង តាមអត្ថន័យនៃមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) និងមាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ

-បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ (មួយ) ឆ្នាំ និងយ៉ាងច្រើន ៥ (ប្រាំ) ឆ្នាំ

-ជនជាប់ចោទជានីតិជន

-រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន ។

**មាត្រា ៤៨. - នីតិវិធីនៃការបង្ហាញខ្លួនភ្លាម**

កាលណាសម្រេចថា ត្រូវប្រើនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ព្រះរាជអាជ្ញាត្រូវ :

-ពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឱ្យខ្លួន

-ឱ្យដំណឹងដល់ជននោះ អំពីរឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើស

-ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ

-ធ្វើកំណត់ហេតុស្តីអំពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ។

ព្រះរាជអាជ្ញាប្រាប់ជនជាប់ចោទថា ខ្លួនមានសិទ្ធិសុំពឹងមេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

មេធាវីជ្រើសរើស ឬចាត់តាំង ត្រូវបានទទួលដំណឹងភ្លាម ។ មេធាវីអាចពិនិត្យសំណុំរឿង និងទាក់ទងជាមួយជនជាប់ចោទបាន ។

និទ្ទេសនៃទម្រង់ការទាំងនេះ ត្រូវចុះនៅក្នុងកំណត់ហេតុ បើពុំដូច្នោះទេ នីតិវិធីត្រូវទុកជាមោឃៈ ។

តុលាការជាន់ដំបូងត្រូវបានទទួលបណ្តឹងតាមកំណត់ហេតុ ស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ។

ជនជាប់ចោទត្រូវបង្ខាំងទុកដោយមានកងកម្លាំងការពារ រហូតដល់ពេលសាមីខ្លួនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការដែលត្រូវបើកសវនាការនៅក្នុងថ្ងៃនោះតែម្តង ។

នៅពេលបង្ហាញខ្លួននេះ តុលាការក្រោយពីបានផ្ទៀងផ្ទាត់មើលអត្តសញ្ញាណរបស់ជនជាប់ចោទ និងធ្វើរបាយការណ៍សង្ខេបរឿងរ៉ាវដែលបានចោទប្រកាន់ ត្រូវប្រាប់ដល់ជនជាប់ចោទថា សាមីខ្លួនអាចមានរយៈពេលដើម្បីរៀបចំការពារខ្លួន ។

ប្រសិនបើជនជាប់ចោទសុំរយៈពេល ឬប្រសិនបើតុលាការយល់ឃើញថា រឿងក្ដីនោះមិនទាន់អាចជំនុំជម្រះភ្លាមៗបានទេនោះ សំណុំរឿងត្រូវលើកទៅពេលសវនាការក្រោយ ។

តុលាការអាចបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្ន ដោយសាលក្រមដែលមានបញ្ជាក់ពីសំអាងហេតុ ។ នៅក្នុងសាលក្រមនោះ តុលាការត្រូវយោងតាមលក្ខខណ្ឌនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន) នៃក្រមនេះ ។ តុលាការចេញដីកាសម្រេចបង្គាប់ឱ្យឃុំខ្លួន ។

សាលក្រមលើអង្គសេចក្ដី ត្រូវតែប្រកាសក្នុងរយៈពេល ដែលមិនអាចលើសពី ២ (ពីរ) សប្ដាហ៍ គិតពីថ្ងៃចូលទៅបង្ហាញខ្លួននៅមុខតុលាការ ។ ការឃុំខ្លួនបណ្ដោះអាសន្នត្រូវតែបញ្ឈប់ដោយពេញច្បាប់ ក្រោយពីផុតរយៈពេល ២ (ពីរ) សប្ដាហ៍ ។

ប្រសិនបើតុលាការដែលបានទទួលបណ្ដឹងតាមនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម យល់ឃើញថាលក្ខខណ្ឌនៃមាត្រា ៤៧ (ការបង្ហាញខ្លួនភ្លាម) នៃក្រមនេះ មិនបានបំពេញទេ ឬក៏ដោយភាពស៊ាំញ៉ាំនៃសំណុំរឿង តម្រូវជាចាំបាច់ឱ្យធ្វើការស្រាវជ្រាវឱ្យបានជ្រាលជ្រៅបន្ថែម តុលាការត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរ ។ ជនជាប់ចោទត្រូវតែនាំទៅបង្ហាញខ្លួននៅថ្ងៃនោះតែម្ដងនៅចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នោះទេ ជនជាប់ចោទត្រូវតែដោះលែងឱ្យមានសេរីភាពវិញដោយឯកឯង ។

### មាត្រា ៤៩. - ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ក្នុងករណីបទលហុ

ប្រសិនបើរឿងនោះជាបទលហុ ព្រះរាជអាជ្ញាត្រូវកោះជនជាប់ចោទឱ្យចូលខ្លួនទៅមុខតុលាការជំនុំជម្រះដោយផ្ទាល់ ដូចបានចែងនៅក្នុងមាត្រា ៤៦ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់) នៃក្រមនេះ ។

### មាត្រា ៥០. - បញ្ជីនៃពាក្យប្ដឹង

នៅតាមតុលាការជាន់ដំបូងនីមួយៗ ត្រូវបង្កើតឱ្យមានបញ្ជីអយ្យការមួយសម្រាប់ចុះបណ្ដឹងដែលប្ដឹងដោយផ្ទាល់ដល់ព្រះរាជអាជ្ញា ឬដែលបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ ។

គ្រប់បណ្ដឹងទាំងអស់ត្រូវតែចុះក្នុងបញ្ជីដោយមានខ្លឹមសារដូចតទៅ :

-អត្តសញ្ញាណរបស់អ្នកប្ដឹង

-កាលបរិច្ឆេទដែលអយ្យការបានទទួលពាក្យប្ដឹង

ក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូប នៅសាលាដំបូងខុសៗគ្នា ហើយទទួលបណ្តឹងទាំងអស់គ្នា អំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា ទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីសម្រេច ។

វិវាទសមត្ថកិច្ចដែនដី រវាងសភាស៊ើបសួរច្រើនត្រូវសម្រេចដោយប្រធានតុលាការកំពូល ។

ការសម្រេចនេះបិទផ្លូវតវ៉ា ។

## មាត្រា ១២៨.- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ការស៊ើបសួរត្រូវបានបើកដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ដោយអនុលោមតាមមាត្រា ៤៤ (ការបើកការស៊ើបសួរ) នៃក្រមនេះ ។

ការស៊ើបសួរអាចបើកប្រឆាំងនឹងបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬប្រឆាំងនឹងអញ្ញាតជន ដោយអនុលោមតាមវាក្យខ័ណ្ឌទី ២ នៃមាត្រា ៤៤ (ការបើកការស៊ើបសួរ) នៃក្រមនេះ ។

ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបាន ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ ។

កាលបើចៅក្រមស៊ើបសួរទទួលពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវធ្វើតាមនីតិវិធីដូចដែលមានចែងនៅមាត្រា ១៣៩ (ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា) និងមាត្រា ១៤០ (ការបង់ប្រាក់តម្កល់ទុក) នៃក្រមនេះ ។

កាលណាទទួលពាក្យប្តឹងសាមញ្ញ ចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យប្តឹងនោះទៅព្រះរាជអាជ្ញា ។

## មាត្រា ១២៩.- វិសាលភាពនៃការប្តឹង

ចៅក្រមស៊ើបសួរទទួលបណ្តឹងអំពីអង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ។ ចៅក្រមស៊ើបសួរត្រូវស៊ើបសួរតែអំពីអង្គហេតុនោះប៉ុណ្ណោះ ។

ប្រសិនបើមានលេចអង្គហេតុថ្មី ដែលអាចជាបទល្មើសព្រហ្មទណ្ឌ នៅក្នុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ។ បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ ។

ប៉ុន្តែ ចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ប្រសិនបើអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសទៅលើអង្គហេតុ ដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង ។

ដើម្បីបំពេញកិច្ចនេះ សភាស៊ើបសួរត្រូវចាត់តាំងសមាជិកម្នាក់របស់សភា ឬក៏ចៅក្រមស៊ើបសួរណាម្នាក់ដែលខ្លួនប្រគល់អំណាចឱ្យ ។

ចៅក្រមដែលទទួលភារកិច្ចស៊ើបសួរបំពេញនោះ ប្រើប្រាស់អំណាចរបស់ចៅក្រមស៊ើបសួរនៅក្នុងព្រំដែនកំណត់ដោយសភាស៊ើបសួរ ។

កាលណាកិច្ចស៊ើបសួរត្រូវបានបំពេញរួចហើយ សំណុំរឿងនៃនីតិវិធីត្រូវយកមកតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ ។ ប្រធានសភាស៊ើបសួរកំណត់កាលបរិច្ឆេទនៃសវនាការថ្មី ។ បទប្បញ្ញត្តិនៃមាត្រា ២៥៩ (ការពិគ្រោះសំណុំរឿង និងសារណា) នៃក្រមនេះ ត្រូវយកមកអនុវត្ត ។

**មាត្រា ២៦៣.** - ការពន្លាតការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ដល់បទល្មើសដែលទាក់ទងគ្នា

សភាស៊ើបសួរដោយឯកឯង ឬតាមសេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចបង្គាប់ឱ្យពន្លាតការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ដល់បទល្មើសដែលទាក់ទងគ្នានឹងបទល្មើសដែលចង្អុលដោយចៅក្រមស៊ើបសួរ កាលណាបទល្មើសនោះលេចចេញពីសំណុំរឿងនៃនីតិវិធី ។

បទល្មើសដែលទាក់ទងគ្នាគឺ :

-កាលណាបទល្មើសបានប្រព្រឹត្តក្នុងពេលជាមួយគ្នា ដោយបុគ្គលច្រើនរួមគ្នា

-កាលណាបទល្មើសបានប្រព្រឹត្តដោយបុគ្គលផ្សេងគ្នា បន្ទាប់ពីមានការព្រមព្រៀងគ្នា ទោះបីជាការប្រព្រឹត្តិនៅក្នុងពេល ឬនៅទីកន្លែងផ្សេងក៏ដោយ ឬ

-កាលណាវត្ថុដែលលួច តែបំបាត់ ឬបានមកពីបទល្មើសណាមួយនោះ ត្រូវបានលាក់បំបាត់ដោយបុគ្គលផ្សេងទៀត ។

**មាត្រា ២៦៤.** - ការពន្លាតការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ រហូតដល់បុគ្គលផ្សេងទៀត

សភាស៊ើបសួរអាចបង្គាប់ឱ្យចោទប្រកាន់បុគ្គលផ្សេងក្រៅពីបុគ្គល ដែលចែងដោយចៅក្រមស៊ើបសួរ លើកលែងតែបទប្បញ្ញត្តិនៅមាត្រា ១២ (អាជ្ញាអស់ជំនុំ) នៃក្រមនេះ ។

**មាត្រា ២៦៥.** - ការបើកជាថ្មីនូវការស៊ើបសួរលើបន្ទុកថ្មីទៀត

ក្រោយពេលដែលដីការបស់ចៅក្រមស៊ើបសួរ ឬសាលដីការបស់សភាស៊ើបសួរដែលលើកលែងចោទប្រកាន់បានចូលជាស្ថាពរ ហើយមានលេចឡើងនូវបន្ទុកថ្មី ការស៊ើបសួរអាចត្រូវបានបើកឡើងវិញតាមគំនិតផ្តើមរបស់ព្រះរាជអាជ្ញា ។

ដែលព្រះរាជអាជ្ញាមិនបានកោះហៅដោយខ្លួនជាអ្នកចេញសោហ៊ុយ ។ ការកោះហៅនេះត្រូវធ្វើតាមបែបបទដែលមានចែងនៅក្នុងមាតិកាទី ៣ គន្ថីទី ៧ នៃក្រមនេះ ។

**មាត្រា ២៩៩.** - ការបញ្ចូលនីតិវិធី

កាលណាតុលាការបានទទួលនីតិវិធីច្រើន ដែលមានអង្គហេតុច្រើនជាប់ទាក់ទងគ្នា តុលាការអាចបង្គាប់ឱ្យបញ្ចូលនីតិវិធីទាំងនោះជាមួយគ្នាបាន ។

## ជំពូកទី ២

## ការចូលខ្លួនរបស់ភាគី

### ផ្នែកទី ១

### ការចូលខ្លួនរបស់ជនជាប់ចោទ

**មាត្រា ៣០០.** - ការចូលខ្លួនរបស់ជនជាប់ចោទ

ជនជាប់ចោទត្រូវចូលបង្ហាញខ្លួននៅពេលសវនាការរបស់តុលាការដោយផ្ទាល់ ។

ជនជាប់ចោទត្រូវអមដោយមេធាវីម្នាក់ដែលខ្លួនជ្រើសរើស ។ ជនជាប់ចោទក៏អាចសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួនបានដែរ នៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

**មាត្រា ៣០១.** - ជំនួយរបស់មេធាវី

ជំនួយពីមេធាវីត្រូវតែមានជាចំខាតនៅក្នុងករណីដូចតទៅ :

១-ករណីបទឧក្រិដ្ឋ ។

២-កាលណាជនជាប់ចោទជាអនីតិជន ។ បើគ្មានការជ្រើសរើសដោយជនជាប់ចោទទេ មេធាវីត្រូវបានចាត់តាំងតាមគំនិតផ្តើមរបស់ប្រធានតុលាការ នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

**មាត្រា ៣០២.** - ការបង្ហាញខ្លួនដោយសេរីរបស់ជនជាប់ចោទ

នៅក្នុងករណីបញ្ជូនទៅជំនុំជម្រះផ្ទាល់ ជនជាប់ចោទចូលទៅបង្ហាញខ្លួនដោយខ្លួនឯងនៅពេលសវនាការ ។

**មាត្រា ៣០៣.** - ការបង្ហាញខ្លួនរបស់ជនជាប់ចោទដោយមានកងកម្លាំងអម

នៅក្នុងករណីនីតិវិធីចូលបង្ហាញខ្លួនភ្លាម ជនជាប់ចោទត្រូវឃុំគ្រងដោយកងការពាររហូតដល់សាមីខ្លួនចូលបង្ហាញខ្លួននៅមុខតុលាការ ។

តុលាការអាចសម្រេចឱ្យឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្នបាន ដូចដែលបានចែងនៅក្នុង

ការអនុវត្តទោសអាចត្រូវបានព្យួរដោយតុលាការ ។

**មាត្រា ៥០១.** – ពាក្យសុំឱ្យស្រូបទោសបញ្ចូលគ្នា

ពាក្យសុំឱ្យស្រូបទោសបញ្ចូលគ្នា ត្រូវលើកនៅមុខតុលាការដែលបានសម្រេចចុងក្រោយគេ ។

តុលាការនេះទទួលបណ្តឹង តាមពាក្យប្តឹងរបស់អយ្យការ ឬរបស់ភាគីពាក់ព័ន្ធ ។ តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្តាប់អយ្យការ ភាគីពាក់ព័ន្ធ និងជាយថាហេតុមេធាវីរបស់ភាគីនេះ ។

## មាតិកាទី ២

## ការប្រតិបត្តិការឃុំខ្លួនបណ្តោះអាសន្ន និងទោសដកហូតសេរីភាព

## ជំពូកទី ១

## វិធាននាក់ទងនឹងការឃុំខ្លួន

**មាត្រា ៥០២.** – ការគណនាថិរវេលានៃការដាក់ពន្ធនាគារ

ទោសដាក់ពន្ធនាគារក្នុង ១ (មួយ) ថ្ងៃ មានថិរវេលា ២៤ (ម្ភៃបួន) ម៉ោង ។

ទោសដាក់ពន្ធនាគារ ក្នុង ១ (មួយ) ខែ មានថិរវេលា ៣០ (សាមសិប) ថ្ងៃ ។

ទោសដាក់ពន្ធនាគារលើសពី ១ (មួយ) ខែ ត្រូវគិតតាមលេខរៀងនៃថ្ងៃក្នុងខែទី ១ (មួយ) ទៅលេខរៀងនៃថ្ងៃក្នុងខែមួយទៀត ។

ទណ្ឌិតដែលបានអនុវត្តទោសរបស់ខ្លួនរួចហើយ ត្រូវដោះលែងនៅក្នុងចន្លោះពីម៉ោង ៦ (ប្រាំមួយ) ព្រឹក ដល់ម៉ោង ១៨ (ដប់ប្រាំបី) ល្ងាច ។

**មាត្រា ៥០៣.** – ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោសដែលបានប្រកាស ឬជាយថាហេតុនៃថិរវេលាសរុបនៃទោសដែលត្រូវទទួលរង បន្ទាប់ពីការស្រូបទោសបញ្ចូលគ្នា ។

**មាត្រា ៥០៤.** – ការរៀបចំពន្ធនាគារ

ការរៀបចំ និងរបបផ្ទៃក្នុងនៃពន្ធនាគារ និងមណ្ឌលឃុំខ្លួន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងដែលគ្រប់គ្រងពន្ធនាគារ ។

ប្រកាសនេះកំណត់ផងដែរ អំពីលក្ខខណ្ឌនៃការបែងចែកទណ្ឌិតនៅតាមពន្ធនាគារ និងមណ្ឌលឃុំខ្លួននានា អំពីបែបបទអនុវត្តទោសដកហូតសេរីភាព និងអំពីរបបឃុំខ្លួន ។

# ឧបសម្ព័ន្ធទី៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ : ០២ កយណ.សរ/១៤

# សារាចរ
# ស្តីពី
# ការអនុវត្តបទប្បញ្ញត្តិ នៃការព្យួរទោសសាកល្បង

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្តីពីការអនុវត្តរបបនៃការព្យួរទោសសាកល្បង ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌចាប់ពីមាត្រា ១១៧ ដល់ មាត្រា ១២៣ និងមាត្រា ១៦៥ មិនទាន់អនុវត្តឲ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឲ្យការអនុវត្តនៃការព្យួរទោសសាកល្បង មិនទាន់បានល្អប្រសើរ។

ដើម្បីអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឲ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចខាងក្រោម ៖

**ក-ចៅក្រមជំនុំជម្រះ**

១-យោងតាមមាត្រា ១១៧ នៃក្រមព្រហ្មទណ្ឌ ចៅក្រមគប្បីត្រូវពិចារណាសម្រេចព្យួរសាកល្បងនៃទោស ឲ្យបានជាអតិបរិមានូវទោស ដែលបានសម្រេចដាក់ពន្ធនាគារ ក្នុងបទល្មើសមជ្ឈឹម។

២-តុលាការត្រូវចេញសម្រង់សាលក្រមស្តារពរចំនួនបីច្បាប់។ ចំនួនពីរច្បាប់ប្រគល់ជូនព្រះរាជអាជ្ញា និងមួយច្បាប់ទៀតប្រគល់ឲ្យទៅទណ្ឌិតដើម្បីអនុវត្ត។

**ខ-ព្រះរាជអាជ្ញា**

១-ត្រូវដឹកនាំសម្របសម្រួល ការអនុវត្តសេចក្តីសម្រេចព្យួរទោសសាកល្បងរបស់តុលាការគ្រប់ជាន់ថ្នាក់ ឲ្យមានប្រសិទ្ធភាព។

២-ត្រូវចាត់តាំងបុគ្គលនៅក្នុងមូលដ្ឋានដែលទណ្ឌិតរស់នៅ ឬ បំពេញកាតព្វកិច្ច ឲ្យតាមដានសកម្មភាពរបស់ទណ្ឌិត។ បុគ្គលដែលគប្បីចាត់តាំង ដូចជានគរបាលប៉ុស្តិ៍រដ្ឋបាល សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ត្រីទទួលបន្ទុកអប់រំ និងស្តារនីតិសម្បទា...។

៣-ត្រូវបង្គាប់ណែនាំដល់ទណ្ឌិត ឲ្យទៅបង្ហាញខ្លួននៅចំពោះមុខបុគ្គលដែលត្រូវបានចាត់តាំងឲ្យតាមដាន។

៤-ត្រូវប្រគល់សម្រង់សាលក្រម ឬ សម្រង់សាលដីកាស្ពាពរដល់បុគ្គលដែលត្រូវបានចាត់តាំងឲ្យតាមដានទណ្ឌិត និងធ្វើការដឹកនាំសម្របសម្រួលការអនុវត្ត។

៥-ក្នុងករណីចាំបាច់ ត្រូវបង្គាប់ទៅអង្គភាពនគរបាលយុត្តិធម៌ ឲ្យចាត់វិធានការជួយតាមដានរាល់សកម្មភាពរបស់ទណ្ឌិត និងត្រូវធ្វើរបាយការណ៍តាមការកំណត់ ពីការកត់សម្គាល់ឃើញរបស់ខ្លួនចំពោះសកម្មភាពរបស់ទណ្ឌិតជូនទៅព្រះរាជអាជ្ញា ដើម្បីស្នើសុំយោបល់ ឬ ចាត់វិធានការ។

សូមលោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា គ្រប់ស្ថាប័នតុលាការ និងអយ្យការត្រូវអនុវត្តសារាចរនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី..២២...ខែ...... ឆ្នាំ..២០១៤..

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍនា

<u>ចម្លងជូន ៖</u>
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-តុលាការ និងមហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
-សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត
-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៤

# វិធានអនុវត្តក្នុងករណីបទល្មើសត្រួតគ្នា[1]

*(មាត្រា ១០៩, មាត្រា ១១៤, មាត្រា ១២២, មាត្រា ១៣៦ ដល់មាត្រា ១៤១ នៃក្រមព្រហ្មទណ្ឌ និង មាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)*

**I. សញ្ញាណនៃ "បទល្មើសត្រួតគ្នា"** : យោងតាមមាត្រា ១៣៦ នៃក្រមព្រហ្មទណ្ឌ "បទល្មើសត្រួតគ្នា" កើតឡើង កាលបើបទល្មើសមួយត្រូវបានប្រព្រឹត្តដោយបុគ្គលម្នាក់ មុនពេលដែលបុគ្គលនេះ ត្រូវបានផ្ដន្ទាទោស ជាស្ថាពរចំពោះបទល្មើសមួយផ្សេងទៀត។ យោងតាមបទប្បញ្ញត្តិនៃមាត្រានេះ **"បទល្មើសត្រួតគ្នា"** សំដៅដល់ស្ថានភាពដែលបទល្មើសច្រើនត្រូវបានប្រព្រឹត្តដោយបុគ្គលម្នាក់ ឬដោយរួមគ្នាជាមួយបុគ្គលផ្សេងទៀតហើយដែលពេលវេលានៃការប្រព្រឹត្តបទល្មើសទាំងនេះ មិនអាចបែងចែកគ្នាដោយសេចក្ដីសម្រេចផ្ដន្ទាទោសជាស្ថាពររបស់តុលាការឡើយ។ ស្ថានភាពនៃ "**បទល្មើសត្រួតគ្នា**" នេះ គឺខុសគ្នាពីស្ថានភាពនៃ "**ការមិនរាងចាល**" ។ "**ការមិនរាងចាល**" សំដៅដល់ស្ថានភាពដែលបុគ្គលម្នាក់បន្ទាប់ពីត្រូវបានផ្ដន្ទាទោសជាស្ថាពររួចហើយពីបទល្មើសមួយ ហើយបុគ្គលបានប្រព្រឹត្តបទល្មើសមួយទៀត។ *ឧទាហរណ៍* :បុគ្គលម្នាក់ត្រូវបានតុលាការសម្រេចផ្ដន្ទាទោសជាស្ថាពររួចហើយពី "**បទលួច**" តាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ប៉ុន្តែ ៣ ឆ្នាំក្រោយមកបន្ទាប់ពីសេចក្ដីសម្រេចរបស់តុលាការបានចូលជាស្ថាពរ បុគ្គលដដែលនេះ បានប្រព្រឹត្ត "**បទលួច**" ថ្មីមួយទៀត ។ ស្ថានភាពនៃ "**ការមិនរាងចាល**" នេះ ត្រូវកំណត់ និងគ្រប់គ្រងដោយវិធានដែលមានចែងចាប់ពីមាត្រា ៨៣ ដល់មាត្រា ៩២ នៃក្រមព្រហ្មទណ្ឌ។

**II. វិធានអនុវត្តនៅក្នុងករណី "បទល្មើសត្រួតគ្នា" ដោយយោងតាមក្រមព្រហ្មទណ្ឌ** : យោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ កាលពីថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ គេពិនិត្យឃើញមានវិធានចំនួន ៣ ដែលអាចយកមកអនុវត្តក្នុងករណី "**បទល្មើសត្រួតគ្នា**" គឺ : (១) វិធានស្រូបទោស , (២) វិធានត្រួតទោស និង (៣) វិធានបូកទោស ។ ការជ្រើសរើសយកវិធានណាមួយយកមកអនុវត្ត ពេលខ្លះ អាស្រ័យទៅលើនីតិវិធីនៃការចោទប្រកាន់ចំពោះបទល្មើសដែលត្រួតគ្នា ពេលខ្លះ អាស្រ័យទៅលើប្រភេទនៃបទល្មើសដែលត្រួតគ្នា។

**១- វិធានស្រូបទោស** : វិធាននេះ អាចយកទៅអនុវត្តបានសម្រាប់បទល្មើសត្រួតគ្នា ទាំងក្នុងនីតិវិធីនៃការចោទប្រកាន់តែមួយ ទាំងក្នុងនីតិវិធីនៃការចោទប្រកាន់ដាច់ពីគ្នា។ វិធាននេះ មានចែងកំណត់ក្នុងមាត្រា ១៣៧ និងមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ។

**១.១-វិធានស្រូបទោសតាមបញ្ញត្តិមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌ :**

**-លក្ខខណ្ឌនៃការអនុវត្តវិធាន :** វិធានស្រូបទោសតាមបទប្បញ្ញត្តិមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌ ត្រូវយកទៅអនុវត្តនៅក្នុងនីតិវិធីនៃការចោទប្រកាន់តែមួយចំពោះបទល្មើសត្រួតគ្នាទាំងអស់។

[1] ការបកស្រាយក្នុងឯកសារនេះ គឺជាការបកស្រាយក្រៅផ្លូវការ និងមានលក្ខណៈជាទ្រឹស្ដីសម្រាប់ជាជំនួយស្មារតីឱ្យដល់អ្នកដែលមានបំណងចង់សិក្សាស្វែងយល់បន្ថែមអំពីបទប្បញ្ញត្តិមួយចំនួនក្នុងក្រមព្រហ្មទណ្ឌប៉ុណ្ណោះ។

ការចោទប្រកាន់តែមួយនេះ សំដៅដល់ស្ថានភាពនៃនីតិវិធី ដែលក្នុងនោះ បទល្មើសត្រួតគ្នាទាំងអស់ ត្រូវបានចោទប្រកាន់នៅក្នុងលិខិតចោទប្រកាន់តែមួយ ដូចជាការចោទប្រកាន់បទល្មើសត្រួតគ្នា នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែមួយ នៅក្នុងកំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាមតែមួយ ឬនៅក្នុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះតែមួយ។ ទន្ទឹមនឹងនេះ ត្រូវបានចាត់ទុកជាការចោទប្រកាន់តែមួយផងដែរនៅក្នុងករណីដូចខាងក្រោម÷

-នៅក្នុងដំណាក់កាលស៊ើបសួរ ចៅក្រមស៊ើបសួរបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីអយ្យការសម្រាប់អង្គហេតុនៃបទល្មើសថ្មីផ្សេង[2] ដែលចៅក្រមស៊ើបសួរបានរកឃើញថា មានការពាក់ព័ន្ធនឹងជនត្រូវចោទ ហើយចៅក្រមស៊ើបសួរបានសម្រេចបិទការស៊ើបសួរតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះសម្រាប់អង្គហេតុដែលបង្កើតបានជាបទល្មើសត្រួតគ្នាទាំងនោះ។ ដូចគ្នាផងដែរ នៅក្នុងករណីដែលសភាស៊ើបសួរពន្លាតការស៊ើបសួររបស់ខ្លួន ទៅដល់បទល្មើសពាក់ព័ន្ធផ្សេងទៀត ស្របតាមបទប្បញ្ញត្តិនៃមាត្រា ២៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយបិទបញ្ចប់ការស៊ើបសួររបស់ខ្លួនតាមសាលដីកាបញ្ជូនទៅជំនុំជម្រះ សម្រាប់អង្គហេតុដែលបង្កើតបានជាបទល្មើសត្រួតគ្នាទាំងនោះ។

-នៅក្នុងករណីដែលតុលាការសម្រេចបញ្ចូលសំណុំរឿងព្រហ្មទណ្ឌច្រើនជាមួយគ្នា ហើយនៅក្នុងសំណុំរឿងទាំងនេះ មានអង្គហេតុបង្កើតបានជាស្ថានភាពនៃបទល្មើសត្រួតគ្នា (មាត្រា ២៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។

នៅក្នុងករណីដែលមានការចោទប្រកាន់តែមួយសម្រាប់បទល្មើសត្រួតគ្នាដូចបានរៀបរាប់ខាងលើនេះ តុលាការត្រូវអនុវត្តវិធាននៃការស្រូបទោស ដោយស្វ័យប្រវត្តិស្របតាមបទប្បញ្ញត្តិនៃមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌ បើទោះបីជាពុំមានបណ្តឹងសុំពីអយ្យការ ឬភាគីពាក់ព័ន្ធក៏ដោយ។

**-ខ្លឹមសារនៃការអនុវត្តវិធាន :** មាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌ ចែងថា : *"កាលបើនៅក្នុងពេលចោទប្រកាន់តែមួយ ហើយជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធពីបទល្មើសច្រើន ទោសនីមួយៗអាចត្រូវបានប្រកាសឡើង។ ប៉ុន្តែ កាលបើទោសត្រូវទទួលមានច្រើន ហើយមានប្រភេទដូចគ្នា តុលាការត្រូវប្រកាសទោសតែមួយនៃប្រភេទនេះ នៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ។ ទោសនីមួយៗដែលប្រកាស ត្រូវចាត់ទុកថា ជាទោសរួមចំពោះបទល្មើសដែលត្រួតគ្នា នៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់អនុវត្តទៅលើបទល្មើសនីមួយៗ។"* យោងតាមបញ្ញត្តិនៃមាត្រានេះ យើងឃើញថា ក្នុងសម្មតិកម្មខ្លះ តុលាការត្រូវប្រកាសទោសនីមួយៗសម្រាប់បទល្មើសត្រួតគ្នា ហើយក្នុងសម្មតិកម្មខ្លះទៀត តុលាការមិនអាចប្រកាសទោសនីមួយៗសម្រាប់បទល្មើសត្រួតគ្នាឡើយ ប៉ុន្តែ តុលាការត្រូវប្រកាសទោសតែមួយរួមគ្នាសម្រាប់បទល្មើសត្រួតគ្នាទាំងអស់ ។

**សម្មតិកម្មទី ១ : ករណីដែលតុលាការត្រូវប្រកាសទោសនីមួយៗសម្រាប់បទល្មើសត្រួតគ្នា :** វិធាននេះ ត្រូវយកទៅអនុវត្ត នៅក្នុងករណីដែលទោសដែលត្រូវប្រកាសសម្រាប់បទល្មើសត្រួតគ្នា មានប្រភេទខុសគ្នា ដូចជា ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ គឺជាទោសដែលមានប្រភេទខុសគ្នា។

[2] មាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ឧទាហរណ៍ : ឈ្មោះ "ក" បានប្រព្រឹត្តបទល្មើសក្នុងស្ថានភាពជាបទល្មើសត្រួតគ្នា រួមមាន ÷

- "បទរំលោភសេពសន្ថវៈ" : មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ចែងផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ឆ្នាំ ទៅ ១០ ឆ្នាំ
- "បទបរិហារកេរ្តិ៍" : មាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ចែងផ្តន្ទាទោសពិន័យជាប្រាក់ពី ១ សែន រៀល ទៅ ១០ លាន រៀល

ឧទាហរណ៍នេះ គឺជាសម្មតិកម្មដែលតុលាការត្រូវប្រកាសទោសនីមួយៗសម្រាប់បទល្មើសត្រួតគ្នា មានន័យថា តុលាការត្រូវប្រកាសទោសដាក់ពន្ធនាគារសម្រាប់បទរំលោភសេពសន្ថវៈ និងទោសពិន័យជាប្រាក់សម្រាប់បទបរិហារកេរ្តិ៍ ។

**សម្មតិកម្មទី ២ : ករណីដែលតុលាការមិនអាចប្រកាសទោសនីមួយៗសម្រាប់បទល្មើសត្រួតគ្នា ប៉ុន្តែតុលាការត្រូវប្រកាសទោសតែមួយរួមគ្នាសម្រាប់បទល្មើសត្រួតគ្នា** : វិធាននេះ ត្រូវយកទៅអនុវត្ត នៅក្នុងករណីដែលទោសដែលត្រូវប្រកាសសម្រាប់បទល្មើសត្រួតគ្នា មានប្រភេទដូចគ្នា ។ ត្រូវចាត់ទុកថា មានប្រភេទដូចគ្នា ដូចជា ទោសដាក់ពន្ធនាគារដូចគ្នា ឬទោសពិន័យជាប្រាក់ដូចគ្នា។ នៅក្នុងករណីនេះ ចំពោះទោសដែលមានប្រភេទដូចគ្នា តុលាការត្រូវប្រកាសទោសតែមួយរួមគ្នាសម្រាប់បទល្មើសត្រួតគ្នាទាំងអស់ ហើយទោសដែលប្រកាសនេះ ត្រូវចាត់ទុកជាទោសរួម សម្រាប់ប្រភេទនៃទោសនីមួយៗ នៅក្នុងព្រំដែនអតិបរមាស្របច្បាប់ អនុវត្តទៅបទល្មើសនីមួយៗ។

ឧទាហរណ៍ : ឈ្មោះ "ក" បានប្រព្រឹត្តបទល្មើសក្នុងស្ថានភាពជាបទល្មើសត្រួតគ្នា រួមមាន ÷

- "បទរំលោភសេពសន្ថវៈ" : មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ចែងផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ឆ្នាំ ទៅ ១០ ឆ្នាំ
- "បទកំហែងយក" : មាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ ចែងផ្តន្ទាទោសដាក់ពន្ធនាគារពី ២ ឆ្នាំ ទៅ ៥ ឆ្នាំ និងពិន័យជាប្រាក់ពី ៤ លាន រៀល ទៅ ១០ លាន រៀល
- "បទឆបោក" : មាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ចែងផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ខែ ទៅ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ១ លាន រៀល ទៅ ៦ លាន រៀល

នៅក្នុងឧទាហរណ៍នេះ ប្រសិនបើតុលាការយល់ឃើញថា ត្រូវសម្រេចផ្តន្ទាទោស ÷

- ចំពោះបទរំលោភសេពសន្ថវៈ : ដាក់ពន្ធនាគារកំណត់ចំនួន ៧ ឆ្នាំ
- ចំពោះបទកំហែងយក : ដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ និងពិន័យជាប្រាក់ ៨ លាន រៀល
- ចំពោះបទឆបោក : ដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ និងពិន័យជាប្រាក់ ៤ លាន រៀល

យោងតាមមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌ តុលាការត្រូវប្រកាសទោសតែមួយ ចំពោះប្រភេទនៃទោសដាក់ពន្ធនាគារ និងប្រកាសទោសតែមួយចំពោះប្រភេទនៃទោសពិន័យជាប្រាក់ នៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ មានន័យថា តុលាការអាចប្រកាសទោសដាក់ពន្ធនាគារអតិបរមាច្រើនបំផុតត្រឹម ១០ ឆ្នាំ និងពិន័យជាប្រាក់អតិបរមាច្រើនបំផុតត្រឹម ១០ លាន រៀល សម្រាប់បទល្មើសទាំង ៣ ខាងលើ។ ទោសដាក់ពន្ធនាគារ ១០ ឆ្នាំ និងទោសពិន័យជាប្រាក់ ១០ លាន រៀល ដែលតុលាការ

ប្រកាសនោះ ត្រូវចាត់ទុកថា ជាទោសរួមចំពោះបទល្មើសដែលត្រួតគ្នា នៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ អនុវត្តទៅលើបទល្មើសនីមួយៗ មានន័យថា នៅក្នុងឧទាហរណ៍ខាងលើ បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ១០ ឆ្នាំ បទកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ៥ ឆ្នាំ និងពិន័យជាប្រាក់ ១០ លាន រៀល និងបទឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ៣ ឆ្នាំ និងពិន័យជាប្រាក់ ៦ លាន រៀល។

### ១.២-វិធានស្របទោស តាមបញ្ញត្តិមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ

**-លក្ខខណ្ឌនៃការអនុវត្តវិធាន :** យោងតាមបញ្ញត្តិមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ វិធានស្របទោសក៏អាចយកទៅអនុវត្តបានផងដែរ នៅក្នុងនីតិវិធីនៃការចោទប្រកាន់ដាច់ពីគ្នាចំពោះបទល្មើសត្រួតគ្នា។ យោងតាមបញ្ញត្តិនៃមាត្រានេះ និងយោងតាមបញ្ញត្តិមាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការដែលអាចសម្រេចអំពីការស្របទោសបញ្ចូលគ្នាបាន គឺតុលាការដែលត្រូវសម្រេចចុងក្រោយគេ ឬតុលាការដែលបានសម្រេចចុងក្រោយគេ។ ប្រសិនបើសំណុំរឿងកំពុងស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួននៅឡើយ តុលាការអាចសម្រេចដោយឯកឯងបានអំពីការស្របទោសបញ្ចូលគ្នា។ ក្រៅពីនេះ តុលាការអាចសម្រេចបាន លុះត្រាតែបានទទួលបណ្តឹងសុំ ពីអយ្យការ ឬពីភាគីពាក់ព័ន្ធ (មាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ក្នុងករណីចុងក្រោយនេះ តុលាការត្រូវសម្រេចក្នុងពេលសវនាការជាសាធារណៈ ក្រោយពីបានស្តាប់អយ្យការ ភាគីពាក់ព័ន្ធ និងជាយថាហេតុ មេធាវីរបស់ភាគីនេះ។ ក្នុងគ្រប់ករណីទាំងអស់ ការស្របទោសបញ្ចូលគ្នា ត្រូវធ្វើតាមសាលក្រម ឬសាលដីការបស់តុលាការ។

**-ខ្លឹមសារនៃការអនុវត្តវិធាន :** ក្នុងករណីដែលតុលាការសម្រេចអនុវត្តវិធានស្របទោស តុលាការអាចសម្រេចឱ្យអនុវត្តទោសស្របបញ្ចូលគ្នាទាំងមូល ឬមួយផ្នែកនៃទោសដែលមានប្រភេទដូចគ្នាបាន ស្របតាមរបៀបនៃការស្របទោសដែលមានចែងក្នុងមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌ។ ប៉ុន្តែនៅក្នុងករណីដែលច្បាប់ចែងផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចំពោះបទល្មើសត្រួតគ្នាណាមួយ ហើយប្រសិនបើជនជាប់ចោទមិនទាន់ត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតទេ អតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ នៅក្នុងការអនុវត្តវិធានស្របទោសនេះ ត្រូវបានកំណត់ដាក់ពន្ធនាគារមិនឱ្យលើសពី ៣០ ឆ្នាំ។ វិធាននេះត្រូវអនុវត្តដូចគ្នាផងដែរ ចំពោះទណ្ឌិត ប្រសិនបើទណ្ឌិតនេះ មិនត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតទេ។ ការព្យួរទោសទាំងមូល ឬមួយផ្នែកនៃទោសដែលប្រកាសចំពោះបទល្មើសដែលត្រួតគ្នានេះ មិនអាចជាឧបសគ្គដល់ការអនុវត្តទោសនៃប្រភេទដូចគ្នាដែលគ្មានការព្យួរទោសទេ។

**២-វិធានត្រួតទោស** : វិធាននេះ មានចែងកំណត់ក្នុងមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ។ ជាទូទៅវិធាននេះត្រូវយកមកអនុវត្តក្នុងករណីនៃការចោទប្រកាន់ដាច់ពីគ្នាចំពោះបទល្មើសត្រួតគ្នា។ មាត្រា ១៣៨ វាក្យខណ្ឌទី ១ នៃក្រមព្រហ្មទណ្ឌចែងថា : "*នៅក្នុងពេលចោទប្រកាន់ដាច់ពីគ្នា កាលបើជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធពីបទល្មើសច្រើន ទោសដែលត្រូវប្រកាស ត្រូវអនុវត្តត្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ។*" នៅក្នុងករណីដែលច្បាប់ចែងផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចំពោះបទល្មើសត្រួតគ្នាណាមួយ ហើយប្រសិនបើជនជាប់ចោទមិនទាន់ត្រូវបានតុលាការសម្រេច

ផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតទេ អតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ត្រូវបានកំណត់ដាក់ពន្ធនាគារត្រឹម ៣០ ឆ្នាំ។ ការព្យួរទោសទាំងមូល ឬមួយផ្នែកនៃទោសដែលប្រកាសចំពោះបទល្មើសដែលត្រួតគ្នានេះ មិនអាចជាឧបសគ្គដល់ការអនុវត្តទោសនៃប្រភេទដូចគ្នាដែលគ្មានការព្យួរទោសទេ។

ឧទាហរណ៍ទី ១ : ឈ្មោះ "ក" បានប្រព្រឹត្តបទល្មើសក្នុងស្ថានភាពជាបទល្មើសត្រួតគ្នា រួមមាន ÷

- "បទរំលោភសេពសន្ថវៈ" : មានចែងផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ឆ្នាំ ទៅ ១០ ឆ្នាំ តាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ
- "បទកំហែងយក" : មានចែងផ្តន្ទាទោសដាក់ពន្ធនាគារពី ២ ឆ្នាំ ទៅ ៥ ឆ្នាំ និងពិន័យជាប្រាក់ពី ៤ លាន រៀល ទៅ ១០ លាន រៀល តាមមាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ
- "បទឆបោក" : មានចែងផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ខែ ទៅ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ១ លាន រៀល ទៅ ៦ លាន រៀល តាម មាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ

នៅក្នុងឧទាហរណ៍នេះ ឈ្មោះ "ក" ត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿងចំនួន ០៣ ដាច់ពីគ្នា ហើយតុលាការបានសម្រេចផ្តន្ទាទោសតាមសាលក្រម ឬសាលដីកាស្ថាពរចំនួន ០៣ ដាច់ពីគ្នា ដោយសម្រេចផ្តន្ទាទោស ÷

- ចំពោះបទរំលោភសេពសន្ថវៈ : ដាក់ពន្ធនាគារកំណត់ចំនួន ៧ ឆ្នាំ
- ចំពោះបទកំហែងយក : ដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ និងពិន័យជាប្រាក់ ៨ លាន រៀល
- ចំពោះបទឆបោក : ដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ និងពិន័យជាប្រាក់ ៤ លាន រៀល

យោងតាមមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ ទោសដែលតុលាការបានប្រកាសផ្តន្ទាទោស ត្រូវអនុវត្តត្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ មានន័យថា ទណ្ឌិតត្រូវទទួលរងការអនុវត្តទោសដាក់ពន្ធនាគារ ជាអតិបរមាត្រឹម ១០ ឆ្នាំ និងពិន័យជាប្រាក់ជាអតិបរមា ត្រឹម ១០ លាន រៀល សម្រាប់បទល្មើសទាំង ៣ ខាងលើ។

ឧទាហរណ៍ទី ២ : ឈ្មោះ "ក" បានប្រព្រឹត្តបទល្មើសក្នុងស្ថានភាពជាបទល្មើសត្រួតគ្នា រួមមាន ÷

- "បទក្លែងបន្លំរូបិយវត្ថុដែលមានតម្លៃនីត្យានុកូល" : មានចែងផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ ឆ្នាំ ទៅ ៣០ ឆ្នាំ ឬអស់មួយជីវិត តាមមាត្រា ៦៤៥ នៃក្រមព្រហ្មទណ្ឌ
- "បទឃាតកម្ម" : មានចែងផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ ឆ្នាំ ទៅ ១៥ ឆ្នាំ តាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ
- "បទកំហែងយក" : មានចែងផ្តន្ទាទោសដាក់ពន្ធនាគារពី ២ ឆ្នាំ ទៅ ៥ ឆ្នាំ និងពិន័យជាប្រាក់ពី ៤ លាន រៀល ទៅ ១០ លាន រៀល តាមមាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ

នៅក្នុងឧទាហរណ៍នេះ ឈ្មោះ "ក" ត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿងចំនួន ០៣ ដាច់ពីគ្នា ហើយតុលាការបានសម្រេចផ្តន្ទាទោសតាមសាលក្រម ឬសាលដីកាស្ថាពរចំនួន ០៣ ដាច់ពីគ្នា ដោយសម្រេចផ្តន្ទាទោស ÷

- ចំពោះបទក្លែងបន្លំរូបិយវត្ថុដែលមានតម្លៃទីត្យានុកូល : ដាក់ពន្ធនាគារកំណត់ចំនួន ១៧ ឆ្នាំ
- ចំពោះឃាតកម្ម : ដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ
- ចំពោះបទឆបោក : ដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ

យោងតាមមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ ទណ្ឌិតត្រូវទទួលរងការអនុវត្តទោសដាក់ពន្ធនាគារជាអតិបរមាត្រឹម ៣០ ឆ្នាំ និងពិន័យ សម្រាប់បទល្មើសទាំង ៣ ខាងលើ[3]។

៣-**វិធានបូកទោស** : វិធានបូកទោសនេះ មានចែងកំណត់ក្នុងមាត្រា ១៤០ នៃក្រមព្រហ្មទណ្ឌ។ វិធាននេះត្រូវយកមកអនុវត្តចំពោះបទល្មើសត្រួតគ្នា ទោះក្នុងនីតិវិធីនៃការចោទប្រកាន់ដាច់តែមួយក្ដី ទោះក្នុងនីតិវិធីនៃការចោទប្រកាន់ដាច់ពីគ្នាក្ដី ។ មាត្រា ១៤០ នៃក្រមព្រហ្មទណ្ឌចែងកំណត់អំពីវិធាននៃការបូកទោសនេះ យ៉ាងច្បាស់ថា "ជាបដិប្បញ្ញត្តិទៅលើបទប្បញ្ញត្តិមុន ការពិន័យដែលបានប្រកាសឡើង ចំពោះបទលហុច្រើននោះ ត្រូវបូកបញ្ចូលគ្នា ហើយត្រូវបូកផងដែរជាមួយទោសពិន័យដែលប្រកាសឡើងចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម។"

ការបូកបញ្ចូលគ្នានៃទោសនេះ ក៏ត្រូវបានយកទៅអនុវត្តផងដែរ ចំពោះទោសដាក់ពន្ធនាគារ។ យោងតាមបទប្បញ្ញត្តិនៃមាត្រា ១៤១ នៃក្រមព្រហ្មទណ្ឌ ទោសដែលតុលាការប្រកាសផ្ដន្ទាពីបទរត់ចេញពីពន្ធនាគារ[4] ត្រូវបូកបញ្ចូលគ្នាជាមួយនឹងទោសដែលប្រកាសឡើងចំពោះបទល្មើសដែលនាំឲ្យមានការឃុំខ្លួនជននោះ ដោយមិនអាចមានការស្រូបចូលគ្នា ឬត្រួតគ្នាតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១៣៧ និងមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌបានឡើយ ។ គួរកត់សម្គាល់ផងដែរថា ការបូកបញ្ចូលគ្នានៃទោសក៏ត្រូវយកទៅអនុវត្តផងដែរ នៅក្នុងករណីក្រៅពីស្ថានភាពនៃបទល្មើសត្រួតគ្នា ជាអាទិ៍ នៅក្នុងករណីដែលមានការដកហូតការព្យួរទោស (ទោះព្យួរទោសធម្មតាក្ដី ព្យួរទោសសាកល្បងក្ដី) ដោយសារមានការផ្ដន្ទាទោសថ្មីតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១០៩ មាត្រា ១១៤ និងមាត្រា ១២២ នៃក្រមព្រហ្មទណ្ឌ។ នៅក្នុងករណីទាំងនេះ ទោសទី ១ ត្រូវអនុវត្តដោយបូកបញ្ចូលគ្នាជាមួយទោសទី ២ ដោយគ្មានការស្រូបចូលគ្នា ឬត្រួតគ្នាតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១៣៧ និងមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌឡើយ។

*ឯកសារនេះត្រូវបានរៀបចំឡើងដោយ÷*
*-ឯកឧត្ដម **ឃុី សោភា** រដ្ឋលេខាធិការក្រសួងយុត្តិធម៌*
*-ឯកឧត្ដម **កើត រិទ្ធ** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌*

[3] យោងតាមស្មារតីនៃមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ទោសដែលតុលាការបានប្រកាសផ្ដន្ទាទោសត្រូវអនុវត្តត្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ប៉ុន្តែ នៅក្នុងករណីដែលច្បាប់ចែងផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចំពោះបទល្មើសត្រួតគ្នាណាមួយ ហើយប្រសិនបើទណ្ឌិតមិនត្រូវបានតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតទេ អតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ត្រូវបានកំណត់ដាក់ពន្ធនាគារត្រឹម ៣០ ឆ្នាំ សម្រាប់អនុវត្តវិធាននៃការស្រូបទោស។

[4] បទរត់ចេញពីពន្ធនាគារនេះ មានចែង និងផ្ដន្ទាទោសក្នុងក្រមព្រហ្មទណ្ឌ ចាប់ពីមាត្រា ៥៦០ ដល់មាត្រា ៥៧០។

# ឧបសម្ព័ន្ធទី៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ ..............

ចុះថ្ងៃទី ........ ខែ ........ ឆ្នាំ ..........

លេខ : ........................ អ.យ

## ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

យើង ........................ តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញសំណុំរឿងលេខ ............................... ចុះថ្ងៃទី ............... ខែ ............... ឆ្នាំ ...............

របស់[១] ..................................................................................................................... ។

### ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា មានតម្រុយសន្និដ្ឋានបានថា :

១- នាម-គោត្តនាម ........................ ហៅ .................... ភេទ ☐ប្រុស-☐ស្រី អាយុ ........ ឆ្នាំ

ជាតិ ................... របររកស៊ី ..........................................................................................

ទីកន្លែងកំណើត ............... ឃុំ-សង្កាត់ ............... ស្រុក-ខណ្ឌ ............... ខេត្ត-ក្រុង ...............

ទីលំនៅបច្ចុប្បន្ន ..........................................................................................................

ទោសពីមុន ......... ឪពុកឈ្មោះ ..................... "☐រ-☐ស" ម្តាយឈ្មោះ ..................... "☐រ-☐ស"

ប្តី ឬ ប្រពន្ធឈ្មោះ ..................... "☐រ-☐ស" មានកូន ........... ឬ ☐នៅលីវ - ☐អនីតិជន ឬ ☐នីតិជន ។

២- នាម-គោត្តនាម ........................ ហៅ .................... ភេទ ☐ប្រុស-☐ស្រី អាយុ ........ ឆ្នាំ

ជាតិ ................... របររកស៊ី ..........................................................................................

ទីកន្លែងកំណើត ............... ឃុំ-សង្កាត់ ............... ស្រុក-ខណ្ឌ ............... ខេត្ត-ក្រុង ...............

ទីលំនៅបច្ចុប្បន្ន ..........................................................................................................

ទោសពីមុន ......... ឪពុកឈ្មោះ ..................... "☐រ-☐ស" ម្តាយឈ្មោះ ..................... "☐រ-☐ស"

ប្តី ឬ ប្រពន្ធឈ្មោះ ..................... "☐រ-☐ស" មានកូន ........... ឬ ☐នៅលីវ - ☐អនីតិជន ឬ ☐នីតិជន ។

បានប្រព្រឹត្តអំពើដូចតទៅ[២] :

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

---

[១] លេខសំណុំរឿងរបស់អង្គភាពនគរបាលយុត្តិធម៌

[២] សេចក្តីសង្ខេបអង្គហេតុ

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

អំពើខាងលើជាបទល្មើស ..........................................................................................

ប្រព្រឹត្តនៅ ..........................................................................................................

កាលពីថ្ងៃទី .................. ខែ .................. ឆ្នាំ .................. តាមបញ្ញត្តិមាត្រា ..................

នៃច្បាប់ .......................................................................................................... ។

បានឃើញមាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## សម្រេច

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង :

☐ ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ[៣] : ..........................................................

..........................................................................................................

..........................................................................................................

☐ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[៤] : ....................................

..........................................................................................................

..........................................................................................................

☐ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន[៥] : ..............................................

..........................................................................................................

..........................................................................................................

រាជធានីភ្នំពេញ , ថ្ងៃទី ......... ខែ ........... ឆ្នាំ

**តំណាងអយ្យការ**

---

[៣] ឈ្មោះជនត្រូវចោទ

[៤] កាតព្វកិច្ចណាមួយដែលបានចែងនៅក្នុងមាត្រា ២២៣

[៥] មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលបានចែងនៅក្នុងមាត្រា ២០៥

# ឧបសម្ព័ន្ធទី៦

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

យ្យការអម

ំបូងរាជធានីភ្នំពេញ

ព្រហ្មទណ្ឌលេខ ...............

...... ខែ .......... ឆ្នាំ ............

........................ អ.យ

## ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម

**យើង** ........................... **តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញនីតិវិធីស៊ើបសួរលើឈ្មោះ ........................................................................ ជាជនត្រូវចោទ

ពីបទ ..............................................................................[២]។

យល់ឃើញថា អង្គហេតុ :

☐ ដែលត្រូវបានចៅក្រមស៊ើបសួររកឃើញ ហើយបានបញ្ជូនមកអោយយើង តាមដីកាបញ្ជូនយើងឆ្លើយ ចុះថ្ងៃទី ............ ខែ ............ ឆ្នាំ ............។

☐ ដែលត្រូវបានដឹងតាមសំណុំលិខិតនីតិវិធីដែលមានភ្ជាប់មកជាមួយ[៣] ជាអង្គហេតុថ្មី ដែលមិនមានចង្អុលបង្ហាញនៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លេខ ..................... ចុះថ្ងៃទី ............ ខែ ............ ឆ្នាំ ............។

យល់ឃើញថា យោងតាមអង្គហេតុថ្មីនេះ មានតម្រុយសន្មត់ថា :

១- នាម-គោត្តនាម ................................ ហៅ ........................ ភេទ ☐ប្រុស-☐ស្រី អាយុ ......... ឆ្នាំ

ជាតិ ........................ របររកស៊ី ..............................................................

ទីកន្លែងកំណើត ................ ឃុំ-សង្កាត់ ................ ស្រុក-ខណ្ឌ ................ ខេត្ត-ក្រុង ................

ទីលំនៅបច្ចុប្បន្ន ..............................................................................

ទោសពីមុន ............ ឪពុកឈ្មោះ ........................ "☐រ-☐ស" ម្តាយឈ្មោះ ........................ "☐រ-☐ស"

ប្តី ឬ ប្រពន្ធឈ្មោះ ........................ "☐រ-☐ស" មានកូន ............ ឬ ☐នៅលីវ - ☐អនីតិជន ឬ ☐នីតិជន។

បានប្រព្រឹត្តអំពើ ដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ............... នៃច្បាប់ ..............................
..............................................................................................។

បានឃើញមាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

---

[១] លេខសំណុំរឿងអយ្យការ ដែលចៅក្រមស៊ើបសួរកំពុងស៊ើបសួរ

[២] ឈ្មោះបទល្មើស

[៣] ព័ត៌មានអំពីអង្គហេតុថ្មីពាក់ព័ន្ធនឹងជនត្រូវចោទ ដែលអយ្យការដឹងតាមរយៈបណ្តឹងរបស់ពលរដ្ឋ ឬ សំណុំរឿងរបស់នគរបាលយុត្តិធម៌ ( ករណីនេះ អយ្យការមិនត្រូវចុះលេខសំណុំរឿងថ្មីទេ)

## សម្រេច

បើកការស៊ើបសួរបន្ថែមចំពោះករណីនេះ តាមនីតិវិធីនៃច្បាប់ នឹងស្នើសុំឱ្យ :

☐ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ[៤] : ........................................................................................
........................................................................................................................
........................................................................................................................

☐ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[៥] : ...........................................................
........................................................................................................................
........................................................................................................................

☐ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្ន[៦] : .......................................................................
........................................................................................................................
........................................................................................................................

រាជធានីភ្នំពេញ , ថ្ងៃទី .......... ខែ .......... ឆ្នាំ

**តំណាងអយ្យការ**

---

[៤] ឈ្មោះជនត្រូវចោទ

[៥] កាតព្វកិច្ចណាមួយដែលបានចែងនៅក្នុងមាត្រា ២២៣

[៦] មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្នដែលបានចែងនៅក្នុងមាត្រា ២០៥

# ឧបសម្ព័ន្ធទី៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

[សា]លាដំបូងរាជធានីភ្នំពេញ

[ស]ំណុំរឿងព្រហ្មទណ្ឌលេខ ..............

[ចុះ]ថ្ងៃទី .......... ខែ .......... ឆ្នាំ ..........

[លេ]ខ : .......................... អ.យ

## ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

យើង .......................... តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ

បញ្ជាឱ្យចូលទៅបង្ហាញខ្លួននៅសវនាការ :

១- នាម-គោត្តនាម .......................... ហៅ .................... ភេទ ☐ប្រុស-☐ស្រី អាយុ .......... ឆ្នាំ

ជាតិ .................... របររកស៊ី ..........................................................

ទីកន្លែងកំណើត .............. ឃុំ-សង្កាត់ .............. ស្រុក-ខណ្ឌ .............. ខេត្ត-ក្រុង ..............

ទីលំនៅបច្ចុប្បន្ន ..........................................................................

ទោសពីមុន .......... ឪពុកឈ្មោះ .................... ☐រ-☐ស ម្តាយឈ្មោះ .................... ☐រ-☐ស

ប្តី ឬ ប្រពន្ធឈ្មោះ .................... ☐រ-☐ស មានកូន .......... ឬ ☐នៅលីវ - ☐អនីតិជន ឬ ☐នីតិជន។

២- នាម-គោត្តនាម .......................... ហៅ .................... ភេទ ☐ប្រុស-☐ស្រី អាយុ .......... ឆ្នាំ

ជាតិ .................... របររកស៊ី ..........................................................

ទីកន្លែងកំណើត .............. ឃុំ-សង្កាត់ .............. ស្រុក-ខណ្ឌ .............. ខេត្ត-ក្រុង ..............

ទីលំនៅបច្ចុប្បន្ន ..........................................................................

ទោសពីមុន .......... ឪពុកឈ្មោះ .................... ☐រ-☐ស ម្តាយឈ្មោះ .................... ☐រ-☐ស

ប្តី ឬ ប្រពន្ធឈ្មោះ .................... ☐រ-☐ស មានកូន .......... ឬ ☐នៅលីវ - ☐អនីតិជន ឬ ☐នីតិជន។

អ្នកត្រូវបានចោទប្រកាន់ពីអង្គហេតុ[1] :

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

[1] សេចក្តីសង្ខេបអង្គហេតុ

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

ជាបទល្មើស ..............................................................................................

ប្រព្រឹត្តនៅ ..............................................................................................

កាលពីថ្ងៃទី .................. ខែ .................. ឆ្នាំ .................. តាមបញ្ញត្តិមាត្រា ..................................

នៃច្បាប់ .............................................................................................. ។

សវនាការនេះ នឹងប្រព្រឹត្តទៅនៅថ្ងៃទី .................. ខែ .................. ឆ្នាំ ..................វេលាម៉ោង ..................

នៅ .............................................................................................. ។

· សាមីខ្លួនអាចពឹងមេធាវីឱ្យអមខ្លួនបាន ។

សាមីខ្លួនត្រូវបង្ហាញខ្លួនឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទង នឹងជីវភាពសាមីខ្លួន ឬ ដំណើររឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

រាជធានីភ្នំពេញ , ថ្ងៃទី .......... ខែ .......... ឆ្នាំ

**តំណាងអយ្យការ**

# ឧបសម្ព័ន្ធទី៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

យ្យការអម

បូងរាជធានីភ្នំពេញ

ព្រហ្មទណ្ឌលេខ ..........

...... ខែ ........ ឆ្នាំ ........

.................. អ.យ

## កំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម[១]

ឆ្នាំពីរពាន់ .................. ខែ ............ ថ្ងៃទី .......................... វេលាម៉ោង ........................................... ។

**យើង** .................................. **តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ**

បានឃើញសំណុំរឿងលេខ ........................................ ចុះថ្ងៃទី .................. ខែ .................. ឆ្នាំ ................ របស់

........................................................................................................................................................ ។

បុគ្គលដែលនៅចំពោះមុខយើង បានផ្តល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម :

១- នាម-គោត្តនាម ........................................ ហៅ .......................... ភេទ □ប្រុស-□ស្រី អាយុ .......... ឆ្នាំ

ជាតិ .................................. របររកស៊ី ........................................................................................

ទីកន្លែងកំណើត .................... ឃុំ-សង្កាត់ .................... ស្រុក-ខណ្ឌ .................... ខេត្ត-ក្រុង ...............

ទីលំនៅបច្ចុប្បន្ន ..............................................................................................................................

ទោសពីមុន .............. ឪពុកឈ្មោះ .............................. "□រ-□ស" ម្តាយឈ្មោះ .............................. "□រ-□ស"

ប្តី ឬ ប្រពន្ធឈ្មោះ ............................ "□រ-□ស" មានកូន ............... ឬ □នៅលីវ - □អនីតិជន ឬ □នីតិជន ។

យើងប្រាប់ដល់បុគ្គលនេះនូវអង្គហេតុដែលខ្លួនត្រូវបានចោទប្រកាន់មានដូចតទៅ : ............................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

អង្គហេតុនេះជាបទល្មើស ..........

ប្រព្រឹត្តនៅ ..........

កាលពីថ្ងៃទី .......... ខែ .......... ឆ្នាំ .......... តាមបញ្ញត្តិមាត្រា ..........

នៃច្បាប់ ..........។

យើងបានទទួលចម្លើយពីជននេះដូចតទៅ : ..........

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

យើងបានប្រាប់ដល់ជននេះថា : ខ្លួនមានសិទ្ធិសុំពឹងមេធាវី តាមការជ្រើសរើសរបស់ខ្លួន ឬស្នើសុំឱ្យមានការចាត់តាំងមេធាវីដោយអនុលោមតាមបញ្ញត្តិច្បាប់ ។

ជននេះបានឆ្លើយថា :

- ☐ ខ្ញុំជ្រើស លោក/លោកស្រីមេធាវី .................................................................................. ។
- ☐ ខ្ញុំសូមស្នើសុំឱ្យមានការចាត់តាំងមេធាវីស្របតាមបញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។
- ☐ ខ្ញុំមិនត្រូវការមេធាវីទេក្នុងពេលនេះ ។

យើងបានបញ្ជាក់ថា :

- ☐ លោក/លោកស្រីមេធាវី .................................................. អាចពិនិត្យសំណុំរឿងនិងទាក់ទងជាមួយជនជាប់ចោទ ។
- ☐ យោងលើសំណើសុំ ឱ្យមានការចាត់តាំងមេធាវី ស្របតាមបញ្ញត្តិច្បាប់ ស្តីពីលក្ខន្តិកៈមេធាវីតំណាងគណៈមេធាវីត្រូវបានជូនដំណឹងភ្លាម ។
- ☐ លោក/លោកស្រីមេធាវី ............................................................................................ អវត្តមាន ។

បានឃើញមាត្រា ៤៧ មាត្រា ៤៨ និងមាត្រា ៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## <u>សម្រេច</u> :

បញ្ជូនជនជាប់ចោទឈ្មោះ ..................................................................................................................
ទៅតុលាការដើម្បីធ្វើការជំនុំជម្រះ តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ចំពោះអង្គហេតុ និងបទល្មើសដូចខាងលើ ។

ក្រោយពីបានអាន ជនជាប់ចោទបានចុះហត្ថលេខាជាមួយយើង ។

**ជនជាប់ចោទ** | **តំណាងអយ្យការ**